# សិក្សាប្រៀបធៀបអំពីតុលាការកំពូល

កុយ នាម*

## សេចក្តីផ្តើម

ពាក្យតុលាការកំពូលបានលេចឡើង នៅប្រទេសកម្ពុជានៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅពេលមានការអនុម័ត "ច្បាប់ស្តីពី ការបង្កើតតុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល" នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៨៥។ ពាក្យតុលាការកំពូលបានប្រើជាប់ជារៀងរហូតមកទល់សព្វថ្ងៃ ថ្វីបើប្រទេសកម្ពុជាបានយកប្រព័ន្ធច្បាប់តាមគម្រូប្រព័ន្ធច្បាប់បារាំងក្តី។ ជាទូទៅ គេតែងតែឮពាក្យតុលាការកំពូល នៅក្នុងប្រព័ន្ធផ្សេងពីបារាំង ដូចជាតុលាការកំពូលរបស់សហរដ្ឋអាមេរិកជាដើម[1]។

ថ្វីបើនៅក្នុងប្រព័ន្ធបារាំង តុលាការដែលហៅថា cour de cassation ជាតុលាការមានឋានៈខ្ពស់ជាងគេនៅក្នុងផ្នែកយុត្តាធិការ (ordre de justice) និងតុលាការកំពូលរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាដែលមានឋានៈខ្ពស់ជាងគេដែរនោះ តុលាការទាំងពីរនេះមិនមានបេសកកម្មដូចគ្នាទេ។ តុលាការ cour de cassation នៃប្រទេសបារាំងមានបេសកកម្មធានា តាមរយៈសេចក្តីសម្រេចរបស់ខ្លួន ដើម្បីធ្វើឱ្យ "បានសម្រេចនូវភាពឯកសណ្ឋានក្នុងការបកស្រាយច្បាប់ក្នុងទិសដៅអភិវឌ្ឍយុត្តិសាស្ត្រដែលតុលាការដទៃត្រូវគោរពតាម...។ គោលបំណងរបស់តុលាការនេះមិនមែនវិនិច្ឆ័យលើអង្គសេចក្តីទេ ប៉ុន្តែត្រូវប្រកាសថា ច្បាប់ដែលត្រូវបានអនុវត្តរួចហើយនោះត្រូវឬខុស ដោយផ្អែកលើអង្គហេតុដែលវាយតម្លៃដាច់ស្រេចហើយនោះ"[2]។ ចំណែកឯតុលាការកំពូលរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាមានតួនាទីដោះស្រាយជម្លោះ។ នេះមានន័យថា cour de cassation បារាំងមិនកាត់សេចក្តីលើវិវាទសម្រេចឱ្យភាគីណាមួយខុស ឬត្រូវទេ តែគាត់សម្រេចថាតើតុលាការក្រោមសម្រេចស្របទៅតាមច្បាប់ដែរឬទេ។ ផ្ទុយទៅវិញ តុលាការកំពូលនៃសាធារណរដ្ឋកម្ពុជាជាតុលាការសម្រេចលើវិវាទទាំងមូល[3]។ ភាពខុសគ្នារវាង

---

* អ្នកនិពន្ធជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈត្តករពាណិជ្ជកម្ម និងសាស្ត្រាចារ្យច្បាប់។

[1] មានប្រទេសជាច្រើននៅអឺរ៉ុបដែលប្រើពាក្យ cour de cassation ឬតុលាការបដិសេធក្នុងពាក្យសាមញ្ញជាជាងពាក្យតុលាការកំពូល។

[2] http://www.courdecassation.fr/about_the_court_9256.html

[3] ច្បាប់ស្តីពីការបង្កើតតុលាការប្រជាជនកំពូល...មាត្រា៣ ចែងថា "តុលាការប្រជាជនកំពូលមានសមត្ថកិច្ចដូចតទៅ ៖ -ជំនុំជម្រះជាលើកទី ១ និងជាលើកចុងក្រោយបង្អស់នូវរឿងក្តីទាំងឡាយដែលច្បាប់កំណត់ថា ជាសមត្ថកិច្ចរបស់ខ្លួន។ ..." នេះមានន័យថា តុលាការនេះ លើកយករឿងវិវាទទាំងមូលមកជំនុំជម្រះដោយខ្លួនឯង មិនមែនពិនិត្យមើលតែសាលក្រមរបស់តុលាការថ្នាក់ក្រោមទេ។

បេសកកម្មទាំងពីរនេះមានវិបាកខុសគ្នាស្រឡះដល់ប្រតិបត្តិការនៃតុលាការ។ នៅក្រោយឆ្នាំ ១៩៩៣ តុលាការកំពូលកម្ពុជាបានវិវត្តមួយកម្រិតទៀតឆ្ពោះទៅរកបេសកកម្មមួយស្រដៀងគ្នានឹងតុលាការ cour de cassation ។

អត្ថបទនេះនឹងលើកយកប្រវត្តិនៃការកកើត និងការវិវត្តនៃតុលាការ cour de cassation របស់បារាំងដើម្បីឆ្លុះបញ្ចាំងមកខាងដៃគូតុលាការខ្មែរ និងលើកយកប្រវត្តិនៃការវិវត្តន៍នៃតុលាការខ្មែរពីសម័យមុនមកទល់សព្វថ្ងៃនេះ។

## ក. សាលាវិនិច្ឆ័យរបស់បារាំង (Tribunal de cassation)

នៅទីនេះពាក្យ "សាលាវិនិច្ឆ័យ" ជាពាក្យដែលអ្នកនិពន្ធខ្ញុំប្រើសិន ដើម្បីកុំឱ្យច្រឡំនឹងពាក្យផ្សេងទៀតក្នុងអត្ថបទនេះ។ ឈ្មោះជាផ្លូវការរបស់តុលាការនេះ ហៅថា Tribunal de cassation ដែលជាតុលាការជាន់ខ្ពស់បំផុតដែលត្រូវបានបង្កើតមុនគេនៅប្រទេសបារាំង នៅឆ្នាំ១៧៩០ ក្នុងខណៈដែលប្រទេសបារាំងកំពុងធ្វើបដិវត្តន៍។ រដ្ឋសភាបារាំងអនុម័តច្បាប់ស្តីពីការបង្កើតសាលានេះនៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៧៩០។ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៧៩១ សាលានេះបានចាប់ផ្តើមការងាររបស់ខ្លួនបន្ទាប់ពីការបោះឆ្នោតលើកទីមួយដើម្បីជ្រើសរើសសមាជិកចំនួន៤២នាក់ ឱ្យធ្វើជាសមាជិកនៃសាលាវិនិច្ឆ័យដែលត្រូវបានធ្វើឡើងនៅឆ្នាំ១៧៩១។

ច្បាប់ឆ្នាំ១៧៩០ ស្តីពីការរៀបចំលើកដំបូងនូវសាលាវិនិច្ឆ័យចែងថា "សភាជាតិអនុម័តថាសាលាវិនិច្ឆ័យមានតែមួយ និងមានអសនៈនៅអមអង្គនីតិបញ្ញត្តិ"។ ដូច្នេះ សាលាជម្រះបដិសេធក្តីនេះជាផ្នែកមួយនៃអង្គនីតិបញ្ញត្តិបារាំងក្នុងសម័យនោះ។

សាលាវិនិច្ឆ័យនេះមានភារកិច្ចប្រកាសសម្រេចលើ ពាក្យបណ្តឹងសុំឱ្យបដិសេធសាលក្រម (Demandes en cassation) ទាំងឡាយដែលសម្រេចជាចុងក្រោយ[4] (jugements en dernier ressort) ។ ក្រៅពីជម្រះបដិសេធសាលក្រមរបស់តុលាការនានា សាលានេះធ្វើការវិនិច្ឆ័យលើរឿងដិតចិត្តចៅក្រម ឬសាលាជម្រះក្តីណាមួយ និងរឿងទំនាស់សមត្ថកិច្ចរវាងតុលាការនានា។ មាត្រា ១ នៃច្បាប់ខាងលើចែងថា ៖

> មុខងាររបស់សាលាជម្រះបដិសេធក្តី... វិនិច្ឆ័យលើពាក្យបណ្តឹងដែលសុំឱ្យបញ្ជូនរឿងពីសាលាជម្រះក្តីមួយ ទៅសាលាជម្រះក្តីមួយទៀត

[4] យោងតាមប្រព័ន្ធបារាំង សាលក្រមសម្រេចជាចុងក្រោយគឺជា សាលក្រម ឬសាលដីកាមួយដែលគេមិនអាចប្តឹងឧទ្ធរណ៍បានតទៅទៀត លើកលែងតែផ្លូវតវ៉ាវិសាមញ្ញ ដូចជាបណ្តឹងសាទុក្ខ ឬបណ្តឹងសើរើ (Lexique de terms juridiques, 8e edition, Dalloz, 1990)។ បណ្តឹងសាទុក្ខនេះ គេមិនរាប់ចូលជាបណ្តឹងឧទ្ធរណ៍ ដូចក្នុងប្រព័ន្ធច្បាប់អាមេរិកាំងទេ។ ពាក្យ Pourvoi ជាពាក្យបច្ចេកទេសមានន័យថា "ការប្តឹងតវ៉ាលើចំណុចច្បាប់"(ប្រើក្នុងវែបសាយ http://www.courdecassation.fr/about_the_court_9256.html)។ ចំណែកឯពាក្យ "ឧទ្ធរណ៍" សំដៅដល់ការតវ៉ាលើរឿងក្តីមួយទាំងលើចំណុចច្បាប់ និងអង្គហេតុ នៅក្នុងយុត្តាធិការមួយទៀតដែលមានឋានៈខ្ពស់ជាង។

(demandes de renvoi) លើរឿងទាក់ទងនឹងការសង្ស័យជាធម្មានុរូប[5] (suspicion légitime) លើរឿងវិវាទយុត្តាធិការ (conflits de juridiction) លើរឿងវិវាទសមត្ថកិច្ចរវាងតុលាការពីរលើរឿងក្តីតែមួយ ឬលើរឿងក្តីពីរដែលទាក់ទងគ្នា (règlement de judges) លើពាក្យសុំដិតចិត្ត (prise à partie) លើតុលាការណាមួយទាំងមូល[6]។

នៅក្នុងការវិនិច្ឆ័យបដិសេធ សាលាជម្រះវិនិច្ឆ័យធ្វើសេចក្តីសម្រេចទុកជាអសារសូន្យលើរឿងនីតិវិធី និងលើសាលក្រមទាំងមូល។ នៅក្នុងការសម្រេចទុកជាអសារសូន្យនូវនីតិវិធី សាលាជម្រះពិនិត្យមើលទម្រង់ដែលត្រូវបានរំលោភ។ បើទម្រង់ណាមួយដែលប្រើនៅក្នុងនីតិវិធីហើយដែលច្បាប់កំណត់ថា បើមិនគោរពតាមទម្រង់នោះទេនឹងត្រូវទុកជាមោឃៈ (violation sous peine de nullité) បើទម្រង់នោះត្រូវបានរំលោភនៅពេលដំណើរការនីតិវិធី នោះនីតិវិធីនឹងត្រូវបានប្រកាសបដិសេធ និងទុកជាឥតបានការ[7]។

ចំពោះការវិនិច្ឆ័យបដិសេធសាលក្រមវិញ សាលាវិនិច្ឆ័យនេះបើកផ្លូវឱ្យភាគីប្តឹងដើម្បីសុំបដិសេធសាលក្រមណាដែលសម្រេចផ្ទុយនឹងច្បាប់ណាមួយ[8]។

**រចនាសម្ព័ន្ធនៃសាលាវិនិច្ឆ័យ** ៖ សាលា Tribunal de cassation ជាស្ថាប័នរណបអង្គនីតិបញ្ញត្តិ[9]។ ដូចបានពោលខាងលើ សាលានេះមានសមាសភាពចៅក្រមដំបូង៤២រូប ដែលត្រូវបានជ្រើសតាំងតាមការបោះឆ្នោត ចេញពីខេត្តនានាសម្រាប់អាណត្តិម្នាក់ៗ ៤ឆ្នាំ។ នៅឆ្នាំ ១៧៩៥ ចំនួននេះត្រូវបានតម្លើងដល់ទៅ ៥០រូប។

នៅក្នុងដំណាក់កាលដំបូង សាលានេះចែកចេញជាពីរផ្នែក។ ផ្នែកទីមួយជាការិយាល័យពិនិត្យពាក្យបណ្តឹង ដើម្បីចម្រាញ់បណ្តឹងណាដែលមានមូលហេតុសម្រាប់សុំសាទុក្ខ និងសម្រេចលើបណ្តឹងសុំដិតចិត្តលើតុលាការទាំងមូល បណ្តឹងសុំបញ្ជូនរឿងក្តីពីតុលាការមួយទៅតុលាការមួយទៀត បណ្តឹងស្តីពីទំនាស់យុត្តាធិការ និងបណ្តឹងដិតចិត្តចៅក្រម។ ផ្នែកទីពីរជាផ្នែកវិនិច្ឆ័យលើពាក្យបណ្តឹងសាទុក្ខលើសាលក្រមដែលត្រូវបានចោទថា បានសម្រេចឡើងដោយរំលោភច្បាប់។

---

[5] សង្ស័យ ឬមានភស្តុតាងថា ចៅក្រមមានភាពលំអៀង ឬបង្ហាញពីអមិត្តភាពរបស់ខ្លួនទៅលើភាគីណាមួយ។

[6] Guichard (Editeur), Code et Mémorial du Tribunal de Cassation, Tome Premier (1797), p.(2)។ កំរងអត្ថបទ ច្បាប់នេះត្រូវបានដកស្រង់ពីបណ្ណាល័យអេឡិចត្រូនិចជាតិបារាំង http://gallica.bnf.fr ។

[7] ប្រភពដូចខាងលើ។

[8] ប្រភពដូចខាងលើ។

[9] មាត្រាដំបូងនៃច្បាប់ស្តីពីការបង្កើតជាលើកដំបូងនូវសាលាវិនិច្ឆ័យចែងថា « Il y aura un tribunal de cassation établi auprès du corps législatif. »

នៅឆ្នាំ១៧៩៥ សាលាវិនិច្ឆ័យចែកចេញជាបីផ្នែកគឺ ផ្នែកពិនិត្យពាក្យបណ្តឹងសាទុក្ខ ផ្នែកខាងសម្រេចបណ្តឹងសាទុក្ខ និងបណ្តឹងដិតចិត្ត និងផ្នែកសម្រេចបណ្តឹងសាទុក្ខរឿងព្រហ្ម-ទណ្ឌ។ ផ្នែកពិនិត្យពាក្យបណ្តឹងមានចៅក្រម១៦រូប ហើយផ្នែកនីមួយៗផ្សេងទៀតមានចៅក្រម ១៧រូប ដោយមានប្រធាន និងអនុប្រធាន។ បន្ទាប់មកនៅឆ្នាំ១៨០០ ចំនួនចៅក្រមត្រូវបាន ទម្លាក់មកនៅ ៤៨រូបវិញ[10]។

នៅអមសាលានេះ មានស្នងការព្រះមហាក្សត្រមួយរូបដែលតែងតាំង ដោយព្រះមហា-ក្សត្រដែលទទួលបន្ទុកឃ្លាំមើលការអនុវត្តន៍ច្បាប់របស់តុលាការ និងចាត់ការធ្វើបណ្តឹងទៅសាលាវិនិច្ឆ័យដើម្បីឱ្យមានការគោរពច្បាប់ត្រឹមត្រូវ ថ្វីបើភាគីបានចរចាស្រុះស្រួលគ្នាជាថ្នូរនឹងការមិនប្តឹងសាទុក្ខក្តី។

**ការប្តឹងសាទុក្ខ** ៖ ប្រព័ន្ធយុត្តិធម៌បារាំងចាត់ទុកថា ការប្តឹងសុំបដិសេធ ឬការប្តឹងសាទុក្ខ គឺជាឧបាស្រ័យចុងក្រោយបង្អស់។ គេមិនត្រូវធ្វើឱ្យការតវ៉ានេះស្រួលពេកទេ បើមិនដូច្នោះទេ ទាំងអស់គ្នានឹងចាត់ទុកសាលាវិនិច្ឆ័យនេះដូចជាសាលាថ្នាក់ឧទ្ធរណ៍ដែរ[11]។

នៅសម័យមុនបដិវត្តន៍ គេតម្រូវឱ្យមាននាយពិនិត្យពាក្យសុំសាទុក្ខ (maîtres des requêtes) នៃក្រុមប្រឹក្សាភាគី[12] (Conseils des parties) ដើម្បីពិនិត្យមើលថា តើពាក្យសុំសាទុក្ខមួយគួរទទួល ឬមិនទទួលយក ដើម្បីដាក់ឱ្យក្រុមប្រឹក្សានេះធ្វើការវិនិច្ឆ័យ។ មានច្បាប់ចែងថា ក្នុងករណីដែលពាក្យសុំសាទុក្ខមានលក្ខណៈមិនអាចទទួលយកទៅវិនិច្ឆ័យបាន ឬក៏ពាក្យសុំនោះគ្មានមូលដ្ឋានត្រឹមត្រូវ (mal fondé) ក្រុមប្រឹក្សានោះត្រូវចេញដីកាមួយដែលបញ្ជាក់ថា ពាក្យសុំនោះត្រូវបានបដិសេធ ហើយដីកានោះត្រូវប្រកាសពិន័យជាប្រាក់១៥០ លីវ[13] ដូច្នេះ ពាក្យបណ្តឹងត្រូវតែមានមូលហេតុជាក់លាក់។

មានមនុស្សជាច្រើនដែលវែកញែកពីមូលហេតុជាច្រើនដែលត្រូវធ្វើសំអាង ដើម្បីអាចឱ្យគេប្តឹងសាទុក្ខទល់នឹងសាលដីកា ឬសាលក្រមជំនុំជម្រះជាចុងក្រោយបាន។ មូលហេតុមួយដែលគេយល់ស្របគ្នាគឺ ការសុំប្តឹងសាទុក្ខ ត្រូវតែឈរលើមូលហេតុនៃការរំលោភច្បាប់។ គំនិត

---

[10] មាត្រា ៥៨ ច្បាប់ស្តីពីការរៀបចំសាលាជម្រះក្តីចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៨០០។

[11] Henri BARDOT, Etude sur le Pourvoi devant la Cour de Cassation, (thèse pour le doctorat, 1873), p. 172

[12] នៅសម័យនោះរាជាណាចក្របារាំងត្រូវបានគ្រប់គ្រងដោយ ក្រុមប្រឹក្សាព្រះមហាក្សត្រ ដែលមានក្រុមប្រឹក្សា ៥ នៅក្នុងនោះ មានក្រុមប្រឹក្សាភាគីដែលមានភារកិច្ចទទួលពាក្យសុំបដិសេធសាលដីកា ឬសាលក្រមដែលជំនុំជម្រះជាចុងក្រោយ ដែលរំលោភលើព្រះរាជក្រឹត្យ។ល។ ក្រុមប្រឹក្សាភាគីជាបុព្វការីរបស់សាលាវិនិច្ឆ័យដែលសម្រេចលើបណ្តឹងសាទុក្ខពីរឿងក្តីទូទៅ និងរឿងក្តីរដ្ឋបាល។ រដ្ឋមន្ត្រីយុត្តិធម៌ជាទម្លាប់ធ្វើជាអធិបតីលើអង្គជំនុំជម្រះនៃក្រុមប្រឹក្សាភាគី។

[13] T. Crépon, Du Pourvoi en Cassation en Matière Civile, Tome Premier (Librairie de Recueil Général des Lois et des Arrêts, 1892), p.27.

នេះអាចសង្ខេបបានថា ការបើកផ្លូវបណ្ដឹងសាទុក្ខទាមទារឱ្យមានការរំលោភច្បាប់នៅក្នុងសាលក្រម ក៏ប៉ុន្តែការរំលោភច្បាប់ទាំងអស់មិនមែនសុទ្ធតែនាំឱ្យមានការបើកផ្លូវឱ្យប្ដឹងសាទុក្ខនោះទេ[14]។ ការរឹតបន្តឹងដល់ការដាក់ពាក្យសុំប្ដឹងសាទុក្ខនេះគឺ ដើម្បីកាត់បន្ថយចំនួនបណ្ដឹងចូលសាលានេះ ព្រោះសាលានេះមិនមែនជាសាលាដែលជម្រះរឿងវិវាទរវាងភាគីទេ តែជាសាលាដែលផ្ដោតតែលើផលប្រយោជន៍នៃការអនុវត្តច្បាប់ដោយស្មោះស្ម័គ្រ ជាជាងផលប្រយោជន៍របស់ភាគី[15] ព្រោះការដោះស្រាយវិវាទជាភារកិច្ចរបស់សាលាថ្នាក់ក្រោម។

ពាក្យសុំប្ដឹងសាទុក្ខក្នុងរឿងរដ្ឋប្បវេណីមិនបង្អង់ការអនុវត្តសាលក្រមទេ[16]។ ផ្ទុយទៅវិញនៅក្នុងរឿងព្រហ្មទណ្ឌ ជនជាប់ចោទមានពេលបីថ្ងៃ ដើម្បីប្ដឹងសាទុក្ខចំពោះសាលក្រមព្រហ្មទណ្ឌទៅសាលាវិនិច្ឆ័យ ហើយការប្ដឹងនេះនាំឱ្យមានការផ្អាកការអនុវត្តសាលក្រម[17]។ ក្រោយពីដាក់ពាក្យប្ដឹងរួចហើយ ជនជាប់ចោទមានពេល ១៥ថ្ងៃទៀត ដើម្បីរៀបចំមធ្យោបាយការពាររបស់ខ្លួន។ នៅក្នុងរយៈពេលនេះ ការអនុវត្តសាលក្រមត្រូវបន្តផ្អាកតទៅទៀត។ ជនជាប់ចោទត្រូវដាក់ពាក្យសុំប្ដឹងសាទុក្ខទៅសាលាវិនិច្ឆ័យ ដោយដាក់ពាក្យប្ដឹងទៅក្រឡាបញ្ជីនៃសាលានេះ។ ក្រឡាបញ្ជីបញ្ជូនពាក្យប្ដឹងទៅស្នងការព្រះមហាក្សត្រដែលនៅអមសាលាវិនិច្ឆ័យ។ ស្នងការព្រះមហាក្សត្របញ្ជូនពាក្យបណ្ដឹងនោះតទៅទៀតទៅរដ្ឋមន្ត្រីយុត្តិធម៌។ រដ្ឋមន្ត្រីត្រូវបញ្ជូនពាក្យនោះទៅសាលាវិនិច្ឆ័យតទៅទៀត។

ចំពោះការប្ដឹងសុំសាទុក្ខបដិសេធតែលើសាលក្រមវិញ គេអាចតវ៉ាបានតែពីបញ្ហាច្បាប់តែប៉ុណ្ណោះ ដោយមិនលើកពីរឿងនីតិវិធីមកនិយាយទេ ហើយភាគី ឬតំណាងរបស់គេ ក៏មិនអាចលើកយកចំណុចដែលបានដោះស្រាយរួចហើយនៅក្នុងសាលក្រមដំបូងនោះរួចហើយដែរ។ ហើយទោះបីសាលក្រមថ្មីនៅតែស្របទៅតាមសាលក្រមដែលបានបដិសេធរួចហើយ ដោយសាលាវិនិច្ឆ័យក្ដី ភាគីអាចប្ដឹងសាទុក្ខបានជាថ្មីទៀត[18]។ ដូច្នេះពាក្យប្ដឹងសាទុក្ខនេះ ត្រូវតែមានមូលហេតុត្រឹមត្រូវ ដោយអ្នកប្ដឹងត្រូវចែង និងបង្ហាញនូវមធ្យោបាយរបស់ខ្លួនទាក់ទងនឹងមូលហេតុមោឃភាពដែលប្រកាសដោយច្បាប់ ដូចជាមោឃភាពនៅក្នុងកិច្ចស៊ើបសួរនៅក្នុងសាលក្រម ឬក៏សាលក្រមនោះអនុវត្តច្បាប់ដោយខុសនឹងបទបញ្ញត្តិនៃច្បាប់ណាមួយ។

[14] Henri BARDOT, Etude sur le Pourvoi devant la Cour de Cassation, (thèse pour le doctorat, 1873), p. 121.

[15] ប្រភពដូចខាងលើ ទ. ១០២។

[16] មាត្រា ១៦ ច្បាប់ស្ដីពីការបង្កើតសាលាវិនិច្ឆ័យលើកដំបូងនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៧៩០។

[17] មាត្រា ១៤ ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌថ្មី ទាក់ទងនឹងការតវ៉ាទៅសាលាវិនិច្ឆ័យ,១៦-២៩ កញ្ញា ១៧៩១។

[18] មាត្រា ២១ ច្បាប់ស្ដីពីការបង្កើតសាលាវិនិច្ឆ័យលើកដំបូងចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៧៩០។

គម្រូសាមញ្ញនៃពាក្យបណ្ដឹងត្រូវចែងពីអង្គហេតុ មធ្យោបាយ ឬការវែកញែកគាំទ្រ ជំហររបស់ខ្លួន និងសេចក្ដីសន្និដ្ឋានរបស់អ្នកប្ដឹង ព្រមទាំងរាយបញ្ជាក់ពីឯកសារនានាដែលភ្ជាប់មកជាមួយរួមមាន សេចក្ដីចម្លងសាលក្រមដែលរងបណ្ដឹងសាទុក្ខផងដែរ[19]។

**ការចម្រាញ់បណ្ដឹងសាទុក្ខ៖** ដូចបានពោលខាងលើ មិនមែនបណ្ដឹងសាទុក្ខទាំងអស់សុទ្ធតែត្រូវបានវិនិច្ឆ័យដោយសាលាវិនិច្ឆ័យនោះទេ។ នៅក្នុងអំឡុងពេលបដិវត្តន៍ ច្បាប់ឆ្នាំ១៧៩០ចែងថា សាលាវិនិច្ឆ័យត្រូវពិនិត្យមើលពាក្យសុំប្ដឹងសាទុក្ខជាមុនសិនមុននឹងទទួលយក និងដាក់ឱ្យធ្វើការវិនិច្ឆ័យ។ ដើម្បីពិនិត្យពាក្យបណ្ដឹង សាលានេះតែងតាំងរៀងរាល់ប្រាំមួយខែម្ដង នៅការិយាល័យមួយឈ្មោះហៅថា "ការិយាល័យពិនិត្យបណ្ដឹង" (Bureau des requêtes) ដែលមានសមាជិក២០រូប ចេញពីបណ្ដាសមាជិកសាលាវិនិច្ឆ័យ។ ការិយាល័យនេះពិនិត្យមើល និងសម្រេចថាតើពាក្យសុំប្ដឹងសាទុក្ខ ឬពាក្យសុំដិតចិត្តត្រូវទទួលយក ឬត្រូវច្រានចោល។ សេចក្ដីសម្រេចត្រូវទទួល ឬច្រានចោលពាក្យសុំប្ដឹងសាទុក្ខអាចធ្វើបាន លុះត្រាណាតែមានសម្លេងបីភាគបួន(១៥នាក់) នៃការិយាល័យពិនិត្យបណ្ដឹង។ បើការិយាល័យពិនិត្យបណ្ដឹងសម្រេចទទួលបណ្ដឹង នោះបណ្ដឹងត្រូវដាក់ទៅក្នុងសវនាដើម្បី ធ្វើការវិនិច្ឆ័យលើកម្មវត្ថុនៃបណ្ដឹង។

បើសមាជិកបីភាគបួនមិនប្រកាសច្រានចោល ឬទទួលយកបណ្ដឹងទេនោះពាក្យបណ្ដឹងនោះត្រូវដាក់ជូនសមាសភាពពេញអង្គនៃសាលាជម្រះបដិសេធក្ដី ដែលនឹងត្រូវធ្វើសេចក្ដីសម្រេចច្រានចោល ឬទទួលយកដោយ សម្លេងភាគច្រើនដាច់ខាត។

នៅពេលដែលការិយាល័យទទួលយកពាក្យសុំសាទុក្ខហើយ ផ្នែកខាងសាទុក្ខនៃសាលានេះធ្វើការវិនិច្ឆ័យ។ សវនាការធ្វើការវិនិច្ឆ័យនេះត្រូវមានចៅក្រមយ៉ាងតិច១៥រូប ហើយសេចក្ដីសម្រេចតម្រូវឱ្យមានសម្លេងភាគច្រើនដាច់ខាតគឺ លើសពី៥០ភាគរយ។

**មូលហេតុដែលអាចប្ដឹងសាទុក្ខបាន៖** គោលការណ៍ទីមួយគឺ សាលាវិនិច្ឆ័យមិនទទួលយកបណ្ដឹងសាទុក្ខ ដែលសុំឱ្យជម្រះរឿងវិវាទរបស់ភាគីឡើងវិញទេ។ មានន័យថាសាលានេះមិនពិនិត្យអង្គសេចក្ដីនៃរឿងក្ដីឡើយ។ តមកទៀត សាលាវិនិច្ឆ័យទទួលយកបណ្ដឹងសាទុក្ខទល់នឹងសាលក្រមដែលសម្រេចដោយផ្អែកលើនីតិវិធីណាមួយ ហើយនៅក្នុងនីតិវិធីដែលចោទជាបញ្ហានោះ មានការរំលោភទម្រង់សម្រាប់ដំណើរការនីតិវិធី។ រួចមក សាលាវិនិច្ឆ័យទទួលយកបណ្ដឹងសាទុក្ខទល់នឹងសាលក្រមដែលមានផ្អែកសំអាងហេតុដែលផ្ទុយនឹងច្បាប់។

**១.ការរំលោភនីតិវិធី៖** មូលហេតុនៃការបដិសេធសាលក្រមដែលរំលោភលើនីតិវិធីកើតចេញពីគំនិតដែលថា ទម្រង់សម្រាប់គាំទ្រដំណើរការនីតិវិធី (formalités de la justice) គឺជាគ្រឿងសម្រាប់ការពារគូវិវាទ ហើយការគោរពតាមទម្រង់នៃនីតិវិធីគឺជាការសន្មតថា នឹងមាន

[19] Guichard (Editeur), Code et Mémorial du Tribunal de Cassation, Tome Premier (1797), p.viii.

សច្ចធម៌ដែលមានមកជាមួយសាលក្រម ហើយបើគ្មានការធានានូវដំណើរការនីតិវិធីឱ្យបាន ត្រឹមត្រូវទេ ការធានាសច្ចធម៌នៅក្នុងសាលក្រមក៏គ្មានដែរ[20]។

បញ្ហាដែលចោទឡើងនោះគឺថា តើការរំលោភទំហំប៉ុនណាដែលនាំឱ្យសាលាវិនិច្ឆ័យ ត្រូវរំលាយ ឬធ្វើមោឃភាពសាលក្រមចោល។ នៅក្នុងច្បាប់ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៧៩០ ស្តីពី ការបង្កើតជាដំបូងនូវសាលាវិនិច្ឆ័យ មាត្រា ១.៣ ចែងថា ៖

> ...ការរំលោភលើទម្រង់ដែលបញ្ញត្តិមកសម្រាប់ដំណើរការនីតិវិធី ដែលត្រូវតែរងមោឃភាព បើមិនគោរពតាម...នឹងបើកផ្លូវឱ្យមាន ប្តឹងសាទុក្ខ។

ខនេះមានសេចក្តីថា សម្រាប់ទម្រង់ណាដែលសំខាន់ ហើយអ្នកតាក់តែងច្បាប់ចង់ដាក់ វិធានយ៉ាងតឹងរឹងនៅក្នុងបទបញ្ញត្តិនៃនីតិវិធីច្បាប់ថា ត្រូវតែគោរពតាម បើពុំដូច្នោះទេ នីតិវិធី នោះត្រូវចាត់ទុកជាមោឃៈ នោះបញ្ញត្តិនោះជាបញ្ញត្តិដាច់ខាត។ ការរំលោភលើទម្រង់ណា ដែលមិនមែនជាបញ្ញត្តិដាច់ខាតមិនមែនជាផ្លូវសម្រាប់ប្តឹងសាទុក្ខទេ។ មាន ១២៩ មាត្រានៅ ក្នុងក្រមបទល្មើសដែលការបំពានលើ ទម្រង់ដែលចែងនៅក្នុងមាត្រាទាំងនោះនាំឱ្យមានមោឃ-ភាព និងដែលបើកផ្លូវឱ្យមានបណ្តឹងសាទុក្ខលើនីតិវិធី[21]។ តែក្រោយមក នៅឆ្នាំ១៧៩៣ លក្ខខណ្ឌ នេះត្រូវបានរឹតបន្តឹងថែមទៀត ដោយនៅក្នុងរឿងរដ្ឋប្បវេណី ការរំលោភលើទម្រង់ណាក៏ដោយ ក៏គេអាចប្តឹងសាទុក្ខបានទាំងអស់[22]។ ក៏ប៉ុន្តែភាពមិនប្រក្រតីនៃទម្រង់ទាំងនោះមិនអាចជាមូល-ដ្ឋាននៃការប្តឹងសាទុក្ខបានទេ បើវាកើតចេញពីទង្វើរបស់ភាគីខ្លួនឯង។

នៅក្នុងបណ្តឹងសាទុក្ខចំពោះនីតិវិធី បើសាលាវិនិច្ឆ័យយល់ឃើញថា មានការរំលោភ នីតិវិធីដូចបានចោទនៅក្នុងពាក្យបណ្តឹងមែននោះ នោះសាលាវិនិច្ឆ័យនេះនឹងសម្រេចបដិសេធ នីតិវិធីនោះចោល ហើយប្រកាសបង្គាប់ឱ្យតុលាការថ្នាក់ក្រោមចាប់ផ្តើមសារជាថ្មីចាប់ពីកិច្ច (acte) ដំបូងគេដែលនាំឱ្យមានការរំលោភលើនីតិវិធីដែលចោទឡើងនោះ។ បន្ទាប់មក តុលាការនោះត្រូវ ជំនុំជម្រះរឿងទាំងមូលសារឡើងវិញ។ សាលក្រមដែលចេញលើក ក្រោយនេះនៅតែអាចរងការប្តឹងសុំ ឱ្យបដិសេធម្តងទៀតបាន[23]។

**២.សាលក្រមផ្ទុយនឹងច្បាប់៖** ការអនុញ្ញាតឱ្យប្តឹងសាទុក្ខដោយមូលហេតុសាលក្រម ចេញដោយផ្ទុយនឹងច្បាប់កើតចេញពីគំនិតដែលថា សេចក្តីសម្រេចលើអង្គហេតុ ទោះបីមកពី

[20] ប្រភពដូចខាងលើ ទំព័រ ១២២។

[21] Guichard (Editeur), Code et Mémorial du Tribunal de Cassation, Tome Premier (1797), p.182

[22] ច្បាប់នោះមានសេចក្តីថា "នៅក្នុងរឿងរដ្ឋប្បវេណី ការរំលោភ ឬការរំលងចោលនូវទម្រង់ដែលបញ្ញត្តិ ដោយ តំណាងប្រជាពលរដ្ឋ ចាប់ពីឆ្នាំ១៧៨៩ មក ទោះបីគ្មានការប្រកាសដោយចំៗថា ត្រូវទុកជាមោឃៈក្តី នឹងបើកផ្លូវឱ្យ មានការប្តឹងសាទុក្ខ។

[23] មាត្រា ១.២០ ច្បាប់ស្តីពីការបង្កើតសាលាវិនិច្ឆ័យលើកដំបូងចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៧៩០។

ការវិនិច្ឆ័យមិនត្រឹមត្រូវលើអង្គហេតុនោះក៏ដោយ ត្រូវរួចផុតពីការត្រួតពិនិត្យរបស់សាលាវិនិច្ឆ័យ ព្រោះការវិនិច្ឆ័យមិនត្រឹមត្រូវនេះធ្វើឱ្យប៉ះទង្គិចតែលើផលប្រយោជន៍ឯកជនប៉ុណ្ណោះ ក៏ប៉ុន្តែការធ្វើផ្ទុយនឹងច្បាប់ធ្វើឱ្យរលំរលាយដល់មូលដ្ឋាននៃសណ្តាប់ធ្នាប់ និងសេចក្តីស្ងប់សាធារណៈ[24]។

ច្បាប់ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៧៩០ អនុញ្ញាតឱ្យមានការប្តឹងសាទុក្ខតែចំពោះករណីដែលមាន"*ការរំលោភយ៉ាងច្បាស់*" ទៅលើអត្ថបទច្បាប់ (Contravention expresse au texte de la loi) ដែលមានន័យថា ខបញ្ញត្តិនៅក្នុងច្បាប់ និងនៅក្នុងសាលក្រមផ្ទុយគ្នាស្រឡះមិនអាចចូលគ្នាបាន[25]។ បញ្ញត្តិច្បាប់នេះមិនអនុញ្ញាតឱ្យចៅក្រមសាលាវិនិច្ឆ័យធ្វើការបកស្រាយដើម្បីធ្វើឱ្យបញ្ញត្តិច្បាប់មួយមានន័យសម្រាប់រឿងក្តីដែលប្តឹងសាទុក្ខមកទេ។ គេត្រូវតែអានសេចក្តីនៃច្បាប់ដូចដែលពាក្យនៃច្បាប់នោះបានបរិយាយ។

**៣. មូលហេតុផ្សេងៗទៀត៖** ក្រៅពីមូលហេតុខាងនីតិវិធី និងការរំលោភច្បាប់ សាលាវិនិច្ឆ័យទទួលពាក្យបណ្តឹងសុំឱ្យវិនិច្ឆ័យរឿងចៅក្រមប្រព្រឹត្តលំអៀង រឿងសុំបញ្ជូនរឿងពីតុលាការមួយទៅតុលាការមួយផ្សេងទៀត រឿងទំនាស់យុត្តាធិការ និងរឿងទំនាស់សមត្ថកិច្ចនៃតុលាការ ឬចៅក្រម។ តែបណ្តឹងទាំងនេះ ត្រូវវិនិច្ឆ័យជាស្ថាពរតែម្តង ដោយការិយាល័យពិនិត្យពាក្យបណ្តឹងសាទុក្ខដោយសម្លេងភាគច្រើន។

ចំណែករឿងដិតចិត្តលើតុលាការទាំងមូលក៏ត្រូវសម្រេចទទួល ដោយការិយាល័យពិនិត្យបណ្តឹងដែរ ដោយសម្លេងបីភាគបួន ឬបើមិនបានចំនួនសម្លេងនេះទេ រឿងនោះត្រូវលើកយកទៅឱ្យសាលាវិនិច្ឆ័យទាំងមូលជាអ្នកសម្រេច។

**ដំណើរការវិនិច្ឆ័យ៖** សាលាវិនិច្ឆ័យធ្វើការវិនិច្ឆ័យលើរបាយការណ៍។ ចៅក្រមម្នាក់នៃសាលាវិនិច្ឆ័យត្រូវបានចាត់តាំងដោយ ប្រធានផ្នែករបស់ខ្លួនដើម្បីធ្វើរបាយការណ៍។ នៅក្នុងសវនាការជាសាធារណៈ ចៅក្រមនោះឡើងថ្លែងដល់សវនាការអំពីអង្គហេតុ និងមធ្យោបាយ (ការវែកញែកអះអាង) របស់ភាគីដែលគាំទ្រជំហររបស់ខ្លួន។ ចៅក្រមនេះមិនបញ្ចេញយោបល់អ្វីរបស់ខ្លួននៅលើរឿងក្តីនេះទេ នៅពេលអានរបាយការណ៍នេះ ថ្វីបើគាត់មានសិទ្ធិបញ្ចេញមតិនៅក្នុងបន្ទប់ពិចារណាជាមួយចៅក្រមដទៃទៀតក្តី។ គូភាគី ឬអ្នកការពាររបស់គេ អាចពិភាក្សារឿងក្តី និងធ្វើសេចក្តីសន្និដ្ឋានបាន លុះត្រាតែចៅក្រមបានបញ្ចប់ការអានរបាយការណ៍នេះសិន។ បន្ទាប់ពីការវែកញែករបស់ភាគី តំណាងអយ្យការឡើងធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន។

សាលាវិនិច្ឆ័យប្រកាសសាលក្រមជាសាធារណៈក្រោយពីធ្វើការពិចារណារួចហើយ។

---

[24] Henri BARDOT, Etude sur le Pourvoi devant la Cour de Cassation, (thèse pour le doctorat, 1873), p. 132..

[25] ប្រភពដូចគ្នាខាងលើ, ទំព័រ ១៣៣។

សាលាវិនិច្ឆ័យមិនពិនិត្យដល់អង្គសេចក្តីនៃរឿងក្តីទេ។ ទីមួយ សាលានេះចេញសាលក្រមបដិសេធសាលក្រមតុលាការថ្នាក់ក្រោមដែលនៅក្នុងផ្នែកខាងសម្រេច (dispositif) មានការចែងសេចក្តីបង្គាប់ផ្ទុយច្បាស់ទែងនឹងច្បាប់។ ក្នុងករណីនេះ សាលាវិនិច្ឆ័យបញ្ជូនអង្គសេចក្តីនៃបណ្តឹងទៅឱ្យតុលាការមួយផ្សេងពីតុលាការដែលរងបណ្តឹងសាទុក្ខជាអ្នកជំនុំជម្រះម្តង។ ទីពីរ សាលាវិនិច្ឆ័យធ្វើមោឃភាពសាលក្រមដែលប្រកាសដោយ ឈរលើនីតិវិធីដែលរំលោភលើទម្រង់ដែលបានបញ្ញត្តិ[26]។ ក្នុងករណីនេះ សាលាវិនិច្ឆ័យបញ្ជូនរឿងក្តីទៅឱ្យតុលាការដដែលដោយចាប់ផ្តើមនីតិវិធីរបស់ខ្លួនឡើងវិញពីកិច្ចដំបូងដែលមានការរំលោភលើទម្រង់នៃនីតិវិធី។

**ការលើកឡើងទៅអង្គនីតិបញ្ញត្តិ** (référé législatif)៖ ការលើកឡើងទៅអង្គនីតិបញ្ញត្តិ គឺជាការយកបញ្ហាច្បាប់ទៅឱ្យអង្គនីតិបញ្ញត្តិស្រាយបំភ្លឺ នៅពេលដែលច្បាប់ណាមួយមានន័យមិនច្បាស់ ឬមានការខ្វះចន្លោះ ដែលធ្វើឱ្យការអនុវត្តច្បាប់នោះទៅលើរឿងក្តីមួយកើតជាភាពចម្រូងចម្រាស់។

វិធីនេះកើតចេញពីគោលការណ៍នៃការបែងចែកអំណាចនៅក្នុងប្រព័ន្ធបារាំង ដែលថាតុលាការជាអ្នកអនុវត្តច្បាប់ ហើយគ្មានសិទ្ធិបកស្រាយទេ ថ្វីបើខ្លួនឃើញមានការខ្វះចន្លោះនៅក្នុងច្បាប់ដែលអនុម័តដោយអង្គនីតិបញ្ញត្តិក៏ដោយ។ គេយល់ថា ការបកស្រាយច្បាប់ជាសកម្ម-ភាពដែលនាំទៅរកការបង្កើតនិយាម ឬហៅម៉្យាងទៀតថា ជាសកម្មភាពបង្កើតវិធាននៃច្បាប់ ហើយដូច្នេះ សកម្មភាពនេះត្រូវតែហាមឃាត់ និងត្រូវតែជាសកម្មភាពផ្តាច់មុខរបស់ពួកនីតិករ (អង្គនីតិបញ្ញត្តិ)[27]។

ការលើកឡើងទៅអង្គនីតិបញ្ញត្តិនេះមានពីរបែប។ បែបទីមួយ ជាការលើកឡើងទៅអង្គនីតិបញ្ញត្តិដោយបង្ខំ (référé obligatoire) និងបែបទីពីរជាការលើកឡើងដោយមិនបង្ខំ (référé facultatif)។ បែបទីមួយកើតឡើងពីមតិមិនស្របគ្នានៅលើចំណុចច្បាប់ដែលត្រូវអនុវត្តរវាងសាលាវិនិច្ឆ័យ និងសាលាដែលទទួលរឿងក្តីឱ្យមកកាត់សារជាថ្មី[28]។ ការលើកឡើងដោយមិនបង្ខំជាការស្នើសុំដោយចៅក្រមកាត់អង្គសេចក្តី នៅពេលដែលគាត់ជួបប្រទះការមិនច្បាស់ថា ត្រូវបកស្រាយច្បាប់មួយយ៉ាងណា ឬច្បាប់នោះមានការចន្លោះប្រហោង[29]។

---

[26] Guichard (Editeur), Code et Mémorial du Tribunal de Cassation, Tome Premier (1797), p.v.

[27] Paolo Alvazzi del Frate, Aux origins du référé législatif: interpretation et jurisprudence dans les cahiers de doléances de 1789, p. 225 (អត្ថបទបង្ហាញនៅក្នុងសន្និសិទថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៦ នៃ Société d'Histoire du Droit).

[28] ប្រភពដូចខាងលើ ទ.២៥៤។

[29] ដើមកំណើតនៃការលើកដោយមិនបង្ខំកើតចេញពីមាត្រា១២ នៃច្បាប់ ១៦-២៤ សីហា ១៧៩០ ដែលមានសេចក្តីថា "សាលាជម្រះក្តីមិនអាចធ្វើបទបញ្ញាបានដាច់ខាត ប៉ុន្តែ គេអាចលើកយកទៅអង្គនីតិបញ្ញត្តិ នៅគ្រប់ពេលដែលគេយល់ថា ជាការចាំបាច់ដើម្បីឱ្យអង្គនីតិបញ្ញត្តិបកស្រាយ ឬធ្វើច្បាប់ថ្មី"។

ចំពោះការលើកឡើងទៅអង្គនីតិបញ្ញត្តិបែបទីពីរ គេអាចធ្វើបានលុះត្រារឿងក្តីមួយត្រូវបានសាលាវិនិច្ឆ័យបានបដិសេធសាលក្រមថ្នាក់ក្រោមពីរដងរួចហើយ។ ហើយតុលាការដែលជំនុំជម្រះលើកទីបី និងចុងក្រោយនៅតែសម្រេចមិនស្របតាមមតិរបស់សាលាវិនិច្ឆ័យទៀត។ ម្តងនេះគេមិនអាចប្តឹងមកសាលាវិនិច្ឆ័យទៀតបានទេ តែគេត្រូវលើកយករឿងនោះមកខាងអង្គនីតិបញ្ញត្តិដើម្បីពិនិត្យ និងវិនិច្ឆ័យវិញ។ ក្រោយពីពិនិត្យរួចហើយ អង្គនីតិបញ្ញត្តិសម្រេចចេញក្រឹត្យមួយដើម្បីប្រកាសពីអត្ថន័យនៃច្បាប់ (décret déclaratoire de la loi) ដែលមានអនុភាពអនុវត្តមកលើរឿងក្តីនេះ[30]។

នៅពេលដែលក្រឹត្យនេះត្រូវបានប្រកាសអនុញ្ញាតដោយ ព្រះមហាក្សត្រហើយ សាលាវិនិច្ឆ័យត្រូវចេញសាលក្រមរបស់ខ្លួនឱ្យស្របជាមួយនឹងក្រឹត្យដែលចេញដោយ អង្គនីតិបញ្ញត្តិនេះ[31]។

ប្រព័ន្ធលើកទៅអង្គនីតិបញ្ញត្តិមានគុណវិបត្តិ ដោយសារវាធ្វើឱ្យដំណើរការបណ្តឹងយឺតយ៉ាវដោយ ការទាមទារឱ្យមានការបោះឆ្នោតពីសភាទាំងមូលលើ សេចក្តីព្រាងអត្ថបទក្រឹត្យបកស្រាយច្បាប់ ហើយនឹងធ្វើឱ្យសមត្ថកិច្ចរបស់អង្គនីតិបញ្ញត្តិក្លាយទៅជាអ្នកអារកាត់វិវាទបុគ្គល[32]។

ច្បាប់ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៨០០ គឺជាចំណុចបត់នៃការលើកទៅឱ្យអង្គការដទៃជាអ្នកបកស្រាយច្បាប់។ មាត្រា៧៨ នៃច្បាប់នេះចែងថា "*កាលណាក្រោយពីមានការបដិសេធមួយហើយ សាលក្រមលើកទីពីរលើអង្គសេចក្តី ដែលត្រូវបានប្តឹងតាមរយៈមធ្យោបាយដូចកាលសាទុក្ខលើកទីមួយដែរនោះ បញ្ហានោះត្រូវលើកទៅដោះស្រាយនៅក្នុងការប្រជុំរួមនៃផ្នែកទាំងអស់នៃសាលាវិនិច្ឆ័យ*"។ នៅក្នុងរយៈពេលនេះ ច្បាប់លែងតម្រូវឱ្យលើករឿងក្តីទៅអង្គនីតិបញ្ញត្តិទៀតហើយ។

---

[30] មាត្រា២១ នៃច្បាប់រៀបចំជាលើកដំបូងនូវសាលាជម្រះបដិសេធក្តី ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ១៧៩០។ មាត្រានេះមានសេចក្តីថា "ក្នុងករណីដែលមានតែសាលក្រមនឹងត្រូវបានបដិសេធ រឿងក្តីនឹងត្រូវលើកយកទៅសវនាការ។ នៅក្នុងសវនាការគេជជែកតែលើការអះអាងផ្នែកចំណុចច្បាប់ប៉ុណ្ណោះ ដោយមិនត្រូវទាក់ទងដល់រឿងទម្រង់នៃនីតិវិធីទេ ហើយភាគី ឬអ្នកការពាររបស់គេក៏មិនអាចជជែកលើចំណុចដែលត្រូវបានដោះស្រាយហើយនៅក្នុងសាលក្រមលើកទីមួយដែរ។ ហើយបើសាលក្រមថ្មីស្របតាមសាលក្រមដែលត្រូវបានបដិសេធ គេនៅតែអាចសុំសាទុក្ខបានទៀត។ ប៉ុន្តែ កាលណាសាលក្រមត្រូវបានបដិសេធពីរដង ហើយសាលាជម្រះទីបីវិនិច្ឆ័យជាលើកចុងក្រោយក្នុងរបៀបដូចគ្នានឹងការវិនិច្ឆ័យពីរដងមុនដែរនោះ បញ្ហានឹងលែងអាចយកមកសាលាវិនិច្ឆ័យបានទៀតហើយ គឺត្រូវលើកទៅអង្គនីតិបញ្ញត្តិ ដែលក្នុងករណីនេះ អង្គនីតិបញ្ញត្តិត្រូវចេញក្រឹត្យប្រកាសច្បាប់ ហើយនៅពេលក្រឹត្យនោះត្រូវបានអនុញ្ញាតដោយព្រះមហាក្សត្រ សាលាវិនិច្ឆ័យត្រូវប្រតិបត្តិ នៅក្នុងសាលក្រមរបស់ខ្លួនឱ្យស្របតាមក្រឹត្យនោះ។

[31] មាត្រា ២១ នៃច្បាប់រៀបចំជាលើកដំបូងនូវសាលាជម្រះបដិសេធក្តី ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៧៩០។

[32] BARDOT, Etude sur le Pourvoi devant la Cour de Cassation, (thèse pour le doctorat, 1873), p. 183-184.

ក្រៅពីអង្គនីតិបញ្ញត្តិមានអំណាចបង្គាប់ឱ្យតុលាការគោរពតាមសេចក្ដីសម្រេចរបស់ខ្លួន អង្គនីតិបញ្ញត្តិ នៅតម្រូវសាលាវិនិច្ឆ័យបញ្ជូនតំណាងរបស់ខ្លួន ៨រូប ជារៀងរាល់ឆ្នាំមកបង្ហាញខ្លួនចំពោះមុខរដ្ឋសភា ដើម្បីបង្ហាញបញ្ជីសាលក្រមដែលសាលាបានចេញក្នុងឆ្នាំកន្លងមក។ នៅលើរឹមសាលក្រមនីមួយៗគេត្រូវចុះពីឈ្មោះរឿងក្ដី និងអត្ថបទច្បាប់ដែលសាលាវិនិច្ឆ័យបានយកមកអនុវត្តមកលើរឿងក្ដីនោះ[33]។ នៅក្នុងរបាយការណ៍ មានផ្នែកមួយដែលសាលាវិនិច្ឆ័យរៀបរាប់ពីបទពិសោធន៍របស់ខ្លួនទាក់ទងនឹងគុណវិបត្តិ ឬភាពខ្វះខាតនៃច្បាប់ និងធ្វើអនុសាសន៍ស្ដីពី មធ្យោបាយទប់ស្កាត់បទល្មើស និងបង្ក្រាបជនល្មើស កែលំអរច្បាប់ និងក្រមនានា កែតម្រូវការបំពានដែលមាននៅក្នុងកិច្ចការគ្រប់គ្រងវិស័យយុត្តិធម៌ និងកែលំអរវិធានការវិន័យរបស់ចៅក្រម និងមន្ត្រីអយ្យការ[34]។

បើតាមច្បាប់រដ្ឋធម្មនុញ្ញ អង្គនីតិបញ្ញត្តិមានអំណាចលើអំណាចតុលាការ។ ថ្វីបើអង្គនេះមិនអាចធ្វើមោឃភាពសាលក្រមរបស់សាលាវិនិច្ឆ័យ តែគេអាចប្ដឹងចៅក្រមដែលវិនិច្ឆ័យខុស[35]។

## ខ. តុលាការវិនិច្ឆ័យបារាំង (Cour de cassation)

សាលាវិនិច្ឆ័យបានប្ដូរឈ្មោះពី Tribunal de cassation ទៅជា Cour de cassation នៅឆ្នាំ១៨០៤ តាមរយៈការអនុម័តអង្គការមួយចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៨០៤។ ទន្ទឹមនឹងការប្ដូរឈ្មោះនេះ តុលាការវិនិច្ឆ័យក៏រងការផ្លាស់ប្ដូរជាច្រើន ដូចជាស្ថេរភាពនៃតំណែងចៅក្រម, ការរៀបចំរចនាសម្ព័ន្ធ, ឯករាជ្យភាពពីអំណាចនីតិបញ្ញត្តិនិងប្រតិបត្តិជាដើម។

ចាប់តាំងពីឆ្នាំ១៧៩៩មក មានការផ្លាស់ប្ដូរក្នុងការតែងតាំងមុខងារចៅក្រមសាលាវិនិច្ឆ័យ ដោយប្ដូរពីការបោះឆ្នោតជ្រើសតាំងមកជាការតែងតាំងដោយ ព្រឹទ្ធសភាសម្រាប់អាណត្តិមួយជីវិត។ តមកទៀត នៅឆ្នាំ១៨០៧ មានច្បាប់មួយទៀតដែលអនុម័តដោយព្រឹទ្ធសភា ដោយកែប្រែការកាន់តំណែងមួយជីវិតតែមាន លក្ខខណ្ឌថាចៅក្រមត្រូវបម្រើការ ៥ឆ្នាំសិន ហើយបើអធិរាជ និងព្រះមហាក្សត្រទទួលស្គាល់ថាចៅក្រមនោះ បំពេញមុខងារគួរឱ្យទុកចិត្តបាន នោះ

---

[33] ប្រភពដូចខាងលើ, មាត្រា ២៤។

[34] T. Crépon, Du Pourvoi en Cassation en Matière Civile, Tome Premier (Librairie de Recueil Général des Lois et des Arrêts, 1892), p.77.

[35] ច្បាប់រដ្ឋធម្មនុញ្ញ មាត្រា CCLXIV ឆ្នាំ ១៧៩៤ (Guichard (Editeur), Code et Mémorial du Tribunal de Cassation, Tome Premier (1797), p. 117 ។ នៅមុននិងក្នុងឆ្នាំ១៧៩៤ យោងតាមសៀវភៅកំរងខាងមុខនេះ មានការធ្វើមោឃភាពសាលក្រមរបស់សាលាវិនិច្ឆ័យជាច្រើនដង។ ប្រហែលជាហេតុនេះទើបច្បាប់រដ្ឋធម្មនុញ្ញក្នុងឆ្នាំនេះហាមឃាត់ការធ្វើមោឃភាព។

ទើបមានការតែងតាំងមួយជីវិត[36]។ នៅឆ្នាំ១៨១៥ ព្រះចៅអធិរាជ ណាប៉ូឡេអុងចេញក្រឹត្យមួយដែលបញ្ជាក់ថាភាពមិនអាចដកហូតបាន គឺជាសិទ្ធិនៃចៅក្រម[37]។ ចាប់ពីពេលនោះមក ចៅក្រមទាំងឡាយណាដែលត្រូវបានដកពីតំណែងពីមុនមកត្រូវបានហៅមកកាន់តំណែងវិញ។

**ការលើកឡើងទៅអង្គនីតិបញ្ញត្តិ** (référé législatif) វិធីលើកបញ្ហាច្បាប់ទៅឱ្យអង្គនីតិបញ្ញត្តិបកស្រាយ ត្រូវបានលុបចោលដោយច្បាប់ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៨០៧ ដែលមានសេចក្តីថា ៖

> មាត្រា១៖ បើតុលាការវិនិច្ឆ័យធ្វើមោឃភាពសាលដីកាពីរ ឬសាលក្រមពីរដែលកាត់សេចក្តីជាចុងក្រោយ ដែលចេញទៅលើរឿងក្តីតែមួយរវាងភាគីដដែល ហើយដែលត្រូវប្តឹងសាទុក្ខដោយប្រើមធ្យោបាយដដែល នោះនឹងមានការបកស្រាយច្បាប់។
>
> មាត្រា២៖ ការបកស្រាយនោះត្រូវធ្វើនៅក្នុងទម្រង់ជាបទបញ្ជា រដ្ឋបាលសាធារណៈ។
>
> មាត្រា៣ ៖ ការបកស្រាយអាចត្រូវបានស្នើសុំដោយតុលាការវិនិច្ឆ័យមុននឹងសម្រេចប្រកាសសាលដីកាលើកទីពីរ។

នេះមានន័យថា ច្បាប់ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៨០៧ មិនបើកឱ្យមានការបកស្រាយច្បាប់នៅក្នុងសាលដីកាដំបូងទេ ហើយផ្តល់ជម្រើសពីរ។ ជម្រើសទីមួយ កាលណាតុលាការវិនិច្ឆ័យបានបដិសេធសាលក្រម ឬសាលដីកាមួយដងហើយ បន្ទាប់មកមានការប្តឹងសាទុក្ខជាលើកទីពីរ នោះតុលាការវិនិច្ឆ័យត្រូវសុំយោបល់ពីក្រុមប្រឹក្សារដ្ឋ[38]សិន មុននឹងប្រកាសសាលដីកាលើកទីពីរ។ ជម្រើសទីពីរ បើតុលាការវិនិច្ឆ័យមិនចង់សុំយោបល់ពីក្រុមប្រឹក្សារដ្ឋទេ តុលាការនេះអាចប្រកាសសាលដីកាជាលើកទីពីរ ក្រោយពីប្រជុំរួមផ្នែកទាំងអស់ក្រោមអធិបតីភាពនៃរដ្ឋមន្ត្រីយុត្តិធម៌ (នៅសម័យនោះគេហៅថា "មហាចៅក្រម")។ ប៉ុន្តែនៅក្នុងជម្រើសទីពីរនេះ បើមានការប្តឹងសាទុក្ខជាលើកទីបីទៀត នោះនឹងមានការបកស្រាយច្បាប់ដូចក្នុងជម្រើសទីមួយទៀត គឺថាតុលាការវិនិច្ឆ័យនឹងសុំយោបល់ទៅក្រុមប្រឹក្សារដ្ឋដើម្បីបកស្រាយ និងយកយោបល់នោះមកអនុវត្តក្នុងសាលដីកាលើកទីបី (មាត្រា៥)។ មូលហេតុដែលគេផ្តល់អំណាចបកស្រាយទៅឱ្យក្រុមប្រឹក្សារដ្ឋ ព្រោះក្រុមប្រឹក្សានេះ ជាស្ថាប័នតែមួយដែលតាក់តែងសេចក្តីព្រាងច្បាប់ស្ទើរតែទាំងអស់ និងដឹងន័យនៃច្បាប់ជាងស្ថាប័នណាទាំងអស់[39]។

---

[36] T. Crépon, Du Pourvoi en Cassation en Matière Civile, Tome Premier (Librairie de Recueil Général des Lois et des Arrêts, 1892), p.99.

[37] ប្រភពដូចគ្នាខាងលើ ទ. ១០២។

[38] Henri BARDOT, Etude sur le Pourvoi devant la Cour de Cassation, (thèse pour le doctorat, 1873), p. 184.

[39] ប្រភពដូចខាងលើ ទ. ១៨៥។

សរុបមក នៅក្នុងតំណាក់កាលនេះ ការលើកទៅអាជ្ញាធរដែលមានអំណាចបកស្រាយច្បាប់ គ្រាន់តែប្តូរពីអង្គនីតិបញ្ញត្តិមកនីតិប្រតិបត្តិប៉ុណ្ណោះ។

ច្បាប់ទាក់ទងនឹងការបកស្រាយច្បាប់ខាងលើត្រូវបាននិរាករណ៍ដោយច្បាប់មួយចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៨២៨ (មាត្រា៤)។ តែនេះមិនមានន័យថា តុលាការមានឯករាជ្យភាពក្នុងការបញ្ចេញមតិរបស់ខ្លួនឡើយ។ តុលាការវិនិច្ឆ័យតោងតែមានប្រភពខាងក្រៅមួយដើម្បីធ្វើការបកស្រាយច្បាប់។ ម្តងនេះ អាជ្ញាធរបកស្រាយច្បាប់រឹតតែស្មុគស្មាញជាងមុន ដោយគេរួមបញ្ចូលទាំងអំណាចប្រតិបត្តិទាំងអំណាចនីតិបញ្ញត្តិ។

ច្បាប់នេះចែងថា បើតុលាការវិនិច្ឆ័យបដិសេធជាលើកទីមួយនូវសាលដីកា ឬសាលក្រម នៅពេលសាទុក្ខលើកទីពីរ តុលាការវិនិច្ឆ័យសម្រេចដោយសភាពេញអង្គក្រោមអធិបតីភាពនៃចាងហ្វាងទីមួយ។ បើសាលាដែលទទួលការបញ្ជូនរឿងពីតុលាការវិនិច្ឆ័យ (បន្ទាប់ពីការបដិសេធជាលើកទីពីរ) នៅតែសម្រេចដូចគ្នានឹងសាលក្រមពីររបស់តុលាការថ្នាក់ក្រោមនោះ សាលដីកា ឬសាលក្រមរបស់តុលាការទីបីនេះមិនអាចប្តឹងសាទុក្ខបានទេ។ ប៉ុន្តែសាលាទីបីនេះត្រូវជូនដំណឹងទៅរដ្ឋាភិបាល ដើម្បីឱ្យរដ្ឋាភិបាលព្រាងច្បាប់បកស្រាយមួយ និងដាក់ឱ្យសភាបោះឆ្នោតអនុម័ត[40]នៅក្នុងសម័យប្រជុំបន្ទាប់ពីការបញ្ជូន។

ច្បាប់បកស្រាយនេះមិនបានផ្តល់ផលប្រយោជន៍ឱ្យភាគីនៃបណ្តឹងទេ ប៉ុន្តែក្លាយជាច្បាប់សម្រាប់អនុវត្ត នៅករណីក្រោយៗទៀតនៅពេលអនាគត[41]។ ក៏ប៉ុន្តែវិធីលើកទៅសភាតាមរយៈរដ្ឋាភិបាលនេះមិនបានទទួលជោគជ័យប៉ុន្មានទេ ព្រោះសភាជាប់រវល់ដោះស្រាយកិច្ចការនយោបាយ និងនីតិកម្មដែលនៅសល់ពីសម័យប្រជុំមុនៗ និងគ្មានពេលដោះស្រាយបញ្ហានេះទេ។ ចាប់ពីឆ្នាំ១៨២៨ ដល់ ឆ្នាំ១៨៣៧ មានរឿង៨០ករណី ដែលបានលើកទៅរដ្ឋាភិបាលដើម្បីធ្វើសេចក្តីព្រាងច្បាប់ មានតែ៤រឿងប៉ុណ្ណោះ ដែលត្រូវបានលើកទៅសភា ហើយមានតែ៤រឿងទេ ដែលត្រូវបានព្រាង ហើយក្នុងចំណោមសេចក្តីព្រាងបួននេះទៀតសោត មានតែពីរទេដែលត្រូវអនុម័តទៅជាច្បាប់[42]។

នៅឆ្នាំ១៨៣៧ ការលើកទៅឲ្យអាជ្ញាធរផ្សេងដើម្បីបកស្រាយច្បាប់ត្រូវបានលុបចោលទាំងស្រុង។ ច្បាប់ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៨៣៧ មានសេចក្តីដូច្នេះ៖

> មាត្រា១.- កាលណា ក្រោយពីការបដិសេធសាលដីកា ឬសាលក្រមទីមួយដែលជំនុំជម្រះជាចុងក្រោយ សាលដីកា ឬសាលក្រមទីពីរដែលចេញក្នុងរឿងក្តីដដែល រវាងភាគីដដែល ប្រព្រឹត្តទៅក្នុងគុណភាពដដែល ត្រូវបានប្តឹងជំទាស់ដោយ មធ្យោបាយដដែលដូច

[40] ប្រភពដូចខាងដើម ទ. ១៨៦។

[41] ប្រភពដូចខាងដើម។

[42] ប្រភពដូចខាងដើម ទ.១៨៧-១៨៨។

> លើកទីមួយ តុលាការវិនិច្ឆ័យប្រកាសសម្រេចក្នុងការប្រជុំរួមសភាទាំងអស់។
>
> មាត្រា ២.- បើសាលដីកា ឬសាលក្រមលើកទីពីរត្រូវបានបដិសេធផ្អែកលើសំអាងហេតុដូចគ្នានឹងលើកទីមួយ តុលាការ ឬសាលាជម្រះណាដែលត្រូវទទួលរឿងបញ្ជូន ត្រូវប្រតិបត្តិតាមសេចក្ដីសម្រេចរបស់តុលាការវិនិច្ឆ័យលើចំណុចច្បាប់ដែលវិនិច្ឆ័យដោយតុលាការនេះ។

នេះជាការចាប់ផ្ដើមនៃការអនុញ្ញាតឱ្យចៅក្រមធ្វើការបកស្រាយច្បាប់ ដែលពីមុនមកគេចាត់ទុកចៅក្រមគ្រាន់តែជា"មាត់នៃច្បាប់"ប៉ុណ្ណោះ[43] ព្រោះការបកស្រាយច្បាប់ជាការងារធ្វើច្បាប់ដោយប្រយោល និងជាសមត្ថកិច្ចរបស់អង្គនីតិបញ្ញត្តិ។

ការលើកទៅអង្គនីតិបញ្ញត្តិដើម្បីបកស្រាយច្បាប់លែងមានប្រសិទ្ធិភាពដោយសារហេតុផលជាច្រើន។ សភាមិនសូវយកចិត្តទុកដាក់ដោះស្រាយបញ្ហានេះ ដោយមកពីបញ្ហាច្បាប់ជារឿយៗមានលក្ខណៈបច្ចេកទេស ដែលគេគ្មានសមត្ថភាពនឹងឆ្លើយទៅនឹងបញ្ហាបានប្រសើរជាងសាលាវិនិច្ឆ័យ[44]។ អង្គនីតិបញ្ញត្តិមិនឆ្លើយតប ឬមិនអើពើនឹងដោះស្រាយពាក្យបណ្ដឹងដែលដាក់មកចំពោះខ្លួន ដោយក្នុងពាក្យបណ្ដឹងចំនួន១៨ អង្គនីតិបញ្ញត្តិឆ្លើយតបបានតែមួយ[45]។ មួយទៀតគឺថាសេចក្ដីសម្រេចដែលធ្វើដោយ អង្គនីតិបញ្ញត្តិត្រូវបានញ៉ាំងដោយ កត្តាពិចារណាខាងនយោបាយ[46]។ បន្ទាប់មកទៀត តុលាការរិះគន់វិធីនេះ ដោយទាញសេចក្ដីសន្និដ្ឋានថា ច្បាប់

---

[43] មាត្រា១០ នៃច្បាប់ ១៦-២៤ សីហា ១៧៩០ ចែងថា "សាលាជម្រះក្ដីមិនអាចរួមចំណែកដោយផ្ទាល់ ឬដោយប្រយោលក្នុងការអនុវត្តអំណាចនីតិបញ្ញត្តិ ហើយក៏មិនអាចហាមឃាត ឬព្យួរការអនុវត្តក្រឹត្យនៃអង្គនីតិបញ្ញត្តិដែរ នៅពេលដែលយល់ព្រមដោយព្រះ មហាក្សត្រហើយ បើពុំនោះទេនឹងទទួលទោសល្មើសមុខងារសាធារណៈ"។

[44] Paolo Alvazzi del Frate, les principes généraux sur la juridiction dans la Constitution de 1791 (អត្ថបទចុះផ្សាយនៅក្នុងសៀវភៅ Constitution & Révolution aux Etats-Unis d´Amérique et en Europe (1776-1850), p. 475-482 ; Xavier Delgrange et Sébastien Van Drooghenbroeck, *Est-ce toujours dans les vieilles casseroles que l´on fait les meilleures soupes ? A propos des relations entre pouvoir politique et pouvoir juridictionnel,* p.4-5 (អត្ថបទដកស្រង់ចេញពីទំព័រវែបសាយៈ http://dev.ulb.ac.be/droitpublic/fileadmin/telecharger/theme_2/contributions/DELGRANGE_et_VAN_DROOGHENBROECK-2-20070430.pdf

[45] Michel Morin, Portalis v. Bentham? The Objectives Pursued by the Codification of Civil and Criminal Law in France, England and Canada, papers sponsored by Law Commission of Canada, et al., (Faculty of Law, Civil Law, University of Ottawa, 1999), 129-130. (https://papyrus.bib.umontreal.ca/xmlui/bitstream/handle/1866/1468/Portalis%20v.%20Bentham%201.pdf?sequence=2&isAllowed=y )

[46] Claire M. Germain, Approaches to Statutory Interpretation and Legislative History in France, (Duke Journal of Comparative & International Law, Vol 13, Special Issue 2003), 197.

ដែលប្រកាសដោយអង្គនីតិបញ្ញត្តិ (មានន័យថាច្បាប់បកស្រាយ) ត្រូវមានអានុភាពទៅលើរឿងក្ដីដែលនឹងកើតទៅមុខ មិនមែនលើរឿងបច្ចុប្បន្ន ឬមានអានុភាពប្រតិសកម្មឡើយ[47] ។

បន្ថែមលើមូលដ្ឋានច្បាប់ដែលបើកឱ្យចៅក្រមបកស្រាយច្បាប់បាន ក្រមរដ្ឋប្បវេណីដាក់ទោសដល់ចៅក្រមដែលគេចវៀសមិនទទួលវិនិច្ឆ័យដោយសារ ច្បាប់មិនច្បាស់ ឬខ្វះចន្លោះ។ មាត្រា៤ នៃក្រមរដ្ឋប្បវេណីបារាំងដែលចាប់កំណើតនៅក្នុងឆ្នាំ១៨០៤ បានចែងថា ៖

> ចៅក្រមដែលបដិសេធមិនធ្វើការវិនិច្ឆ័យ ដោយអាងលេសថាច្បាប់មិនបាននិយាយ ច្បាប់មិនច្បាស់ ឬគ្មានច្បាប់ អាចត្រូវបានចោទប្រកាន់និងដាក់ទោសពីបទយុត្តិនិសេធ។

ម៉្យាងវិញទៀត មាត្រា ៥ នៃក្រមដដែលចែងថា ៖

> ហាមមិនឱ្យចៅក្រមប្រកាសសេចក្ដីសម្រេចរបស់ខ្លួន តាមរបៀបជាបញ្ញត្តិទូទៅ និងជាបទបញ្ជាចំពោះរឿងក្ដីដែលដាក់ឱ្យខ្លួនវិនិច្ឆ័យ។

## គ. តុលាការវិនិច្ឆ័យបារាំងក្នុងពេលបច្ចុប្បន្ន

តុលាការវិនិច្ឆ័យបារាំងបច្ចុប្បន្នបានប្រែក្លាយទៅជា ស្ថាប័នមួយប្លែកឆ្ងាយពីតុលាការនៅក្នុងសតវត្សទី១៩។ សមត្ថកិច្ចនៃតុលាការនេះមានការខុសគ្នាច្រើនជាងមុន តែយើងមិនលើករឿងនេះមកពិភាក្សាលំអិតនៅទីនេះទេ។ ក្រៅពីរឿងជម្រះបណ្ដឹងសាទុក្ខ តុលាការនេះមានសមត្ថកិច្ចលើរឿងបណ្ដឹងជិតចិត្តតុលាការ ជម្រះបណ្ដឹងពីការទទួលខុសត្រូវក្នុងវិជ្ជាជីវៈរបស់មេធាវីនៅក្រុមប្រឹក្សារដ្ឋ និងតុលាការវិនិច្ឆ័យ ជម្រះលើបណ្ដឹងតវ៉ានឹងសេចក្ដីសម្រេចរបស់អាជ្ញាធររៀបចំបញ្ជីអ្នកជំនាញកោសល្យវិច័យ។ល។

តុលាការវិនិច្ឆ័យចែកចេញជាការិយាល័យនៃតុលាការវិនិច្ឆ័យ, និងសភាប្រាំមួយ។ សភាទាំងប្រាំមួយនោះគឺ សភាព្រហ្មទណ្ឌ, សភាពាណិជ្ជកម្ម សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, សភាសង្គម និងសភារដ្ឋប្បវេណីបី ដែលគេ ហៅគេហៅជាទូទៅថា សភាទីមួយ សភាទីពីរ និងសភាទីបី។ សភានីមួយៗមានប្រធានមួយនាក់ ព្រឹទ្ធចៅក្រមមួយនាក់ និងចៅក្រមប្រឹក្សា និងចៅក្រមជំនួយមួយចំនួន (ចៅក្រមជំនួយមិនចូលរួមក្នុងការបោះឆ្នោតសម្រេចទេ ប៉ុន្តែគាត់អាចធ្វើជាចៅក្រមរបាយការណ៍ធ្វើជាអ្នកស្រាវជ្រាវ និងអ្នកព្រាងសាលក្រម)។ នៅក្នុងសភានីមួយៗមានចែកចេញជាផ្នែកផ្សេងៗទៅទៀត។ ចំនួនចៅក្រមប្រឹក្សាទាំងអស់មាន១១០នាក់ និងចៅក្រមជំនួយ៧២នាក់។ សភានីមួយៗមានចៅក្រមច្រើនណាស់ ឧទាហរណ៍ សភារដ្ឋប្បវេណីទីមួយមានចៅក្រម១៧នាក់ (ចៅក្រមជំនួយ១៥នាក់) ទីពីរ ២២នាក់ (ជំនួយ ១៥ នាក់) និងទីបី ១៨ នាក់ (ជំនួយ ៩នាក់) និងសភា ព្រហ្មទណ្ឌមានចៅក្រម ៣២ នាក់និងជំនួយ ៨ នាក់។

---

[47] ប្រភពដដែល, ទ. ១៣០។

ប្រធាន ឬចាងហ្វាងទីមួយជាចៅក្រមធំជាងគេនៅ តុលាការវិនិច្ឆ័យ និងនៅប្រទេសបារាំង។ គាត់មានតួនាទីនៅក្នុងរឿងកាត់ក្ដីផង និងក្នុងរឿងរដ្ឋបាលផង។ គាត់មានការិយាល័យរបស់គាត់ និងមានបុគ្គលិកមួយចំនួនធំដើម្បីជួយធ្វើកិច្ចការជាច្រើន។

**ផ្លូវដែលបើកឱ្យប្ដឹងសាទុក្ខបាន៖** ជាគោលការណ៍ទូទៅ កំហុសរបស់តុលាការថ្នាក់ក្រោម ដែលអាចប្ដឹងតវ៉ាបានទៅតុលាការវិនិច្ឆ័យគឺ ការរំលោភច្បាប់។ ដូច្នេះ ផ្លូវដែលបើកឱ្យតវ៉ាបានមិនខុសគ្នាពីបញ្ញត្តិដែលមាននៅក្នុងប្រវត្តិនៃសាលា ឬតុលាការវិនិច្ឆ័យបារាំងពីសម័យមុនៗនោះទេ។ ការរំលោភច្បាប់ក្នុងន័យនៃការសម្រេចរឿងក្ដីនៅក្នុងតុលាការនេះ គឺការបកស្រាយច្បាប់មិនត្រឹមត្រូវ ហើយការរំលោភនេះគ្របដណ្ដប់លើការបំពានលើវិធានគតិយុត្តណាមួយ។

តមកទៀត មានការសម្រេចសេចក្ដីដោយ តុលាការមួយដែលគ្មានសមត្ថកិច្ចលើករណីមួយ។ ឧទាហរណ៍ តើរឿងដែលកើតនៅប្រទេសមួយត្រូវចូលក្នុងសមត្ថកិច្ចតុលាការបារាំងដែរឬទេ?។ តើរឿងមួយត្រូវដោះស្រាយ នៅតុលាការរដ្ឋបាល ឬតុលាការធម្មតា? ទាំងអស់នេះចោទជាបញ្ហាសមត្ថកិច្ចដែលតុលាការមានការបកស្រាយខុសគ្នា ជាពិសេសរឿងដែលកើតនៅក្នុងប្រព័ន្ធអ៊ីនធឺណែត ដែលតុលាការត្រូវកំណត់សមត្ថកិច្ចនៃតុលាការប្រទេសណា។

ការបំពានអំណាចក៏ជាហេតុអាចនាំឱ្យមានការប្ដឹងសាទុក្ខដែរ។ ការបំពានអំណាចកើតមាននៅពេល តុលាការមួយប្រើអំណាចហួសពីច្បាប់បើកឱ្យមាន។

ដូចគ្នានឹងតុលាការសម័យមុនដែរ ការរំលោភលើទម្រង់ណាមួយនៃនីតិវិធីនាំឱ្យមានការប្ដឹងសាទុក្ខ។ នេះសម្រាប់តែទម្រង់ណាដែលច្បាប់កំណត់ថាត្រូវគោរព បើពុំនោះទេនឹងត្រូវទុកជាមោឃៈ។ សាលក្រមដែលមិនគោរពតាមទម្រង់ ក៏ជាមូលហេតុនៃការប្ដឹងសាទុក្ខដែរ ដូចជាសាលក្រមដែលមិនថែងពីសំអាងហេតុ ឬសំអាងហេតុនោះមិនគ្រប់គ្រាន់ដើម្បីគាំទ្រសេចក្ដីសម្រេច។

**ប្រភេទនៃសេចក្ដីសម្រេចដែលអាចប្ដឹងសាទុក្ខបាន៖** នៅក្នុងរឿងរដ្ឋប្បវេណី ជាគោលការណ៍ទូទៅ បណ្ដឹងសាទុក្ខអាចធ្វើបានចំពោះតែសេចក្ដីសម្រេចណាដែលជាសេចក្ដីសម្រេចដល់ចុងក្រោយ (décision rendue en dernier ressort)។ ប៉ុន្តែនៅពេលខ្លះ សេចក្ដីសម្រេចខ្លះ ដែលមិនចាំបាច់ដល់ចុងក្រោយ ក៏អាចប្ដឹងសាទុក្ខបានដែរ។ ឧទាហរណ៍ នៅក្នុងផ្នែកនៃសេចក្ដីសម្រេចរបស់ខ្លួន សាលក្រមមួយដែលសម្រេចដល់អង្គសេចក្ដីលើបញ្ហាធំចម្បង ប៉ុន្តែសម្រេចបង្គាប់ឱ្យចាត់វិធានការបណ្ដោះអាសន្ន ឬឱ្យមានការស៊ើបអង្កេតលើចំណុចបញ្ហាផ្សេងទៀត សាលក្រមបែបនេះក៏អាចប្ដឹងសាទុក្ខបានដែរ។ រីឯបញ្ហាដែលនៅសល់ទុកឱ្យស៊ើបអង្កេត ឬចាត់វិធានការបណ្ដោះអាសន្នតទៅទៀតនោះ នៅពេលតុលាការសម្រេចរឿងនោះដល់អង្គសេចក្ដី

ហើយ គេអាចប្ដឹងសាទុក្ខជាក្រោយទៀតបាន[48]។ សាលក្រមបែបនេះ ជាសាលក្រមចម្រុះ (jugement mixte) ដែលស្ថិតនៅចន្លោះ សាលក្រមសម្រេចជាចុងក្រោយ (jugement définitif) និង សាលក្រមសម្រេចបញ្ហាបន្ទាន់បង្ខំ (jugement avant dire droit) រីឯបណ្ដឹងសាទុក្ខបែបនេះ គេហៅថាជា "បណ្ដឹងសាទុក្ខបន្ទាន់" ដោយមិនចាំបាច់រង់ចាំ សេចក្ដីសម្រេចលើរឿងដទៃទៀត[49]។

នៅក្នុងរឿងព្រហ្មទណ្ឌ សាលដីកានៃសភាស៊ើបសួរ និងសាលដីកាសម្រេចជាចុងក្រោយលើរឿងឧក្រិដ្ឋ មជ្ឈិម និងលហុ អាចត្រូវបានប្ដឹងសាទុក្ខបានលើបញ្ហាអង្គច្បាប់។ សេចក្ដីសម្រេចណាដែលមានលក្ខណៈជាសេចក្ដីសម្រេចរដ្ឋបាលមិនអាចប្ដឹងសាទុក្ខបានទេ[50]។ ចំពោះសេចក្ដីសម្រេចលើបញ្ហាបន្ទាន់បង្ខំរបស់តុលាការថ្នាក់ក្រោម គេអាចប្ដឹងសាទុក្ខបន្ទាន់បាន ដោយធ្វើពាក្យសុំអនុញ្ញាតពីប្រធានសភាព្រហ្មទណ្ឌនៃតុលាការវិនិច្ឆ័យ។ ករណីដែលអាចប្ដឹងសាទុក្ខបាននោះមានពីរប្រភេទ គឺសេចក្ដីសម្រេចដែលបញ្ចប់នីតិវិធី និងសេចក្ដីសម្រេចដែលមិនបញ្ចប់នីតិវិធី[51]។

សាលក្រមដែលសម្រេចបញ្ចប់នីតិវិធី មានដូចជាសាលក្រមសម្រេចពីអសមត្ថកិច្ចតុលាការ ពីការមិនទទួលបណ្ដឹង(ដូចជាហួសអាជ្ញាយុកាល ឬការលើកលែងទោសជាសាធារណៈជាដើម)។ រីឯសាលក្រមឬ សាលដីកាដែលមិនសម្រេចបញ្ចប់នីតិវិធី ដូចជាសាលក្រមបង្គាប់ឱ្យស៊ើបសួរ សាលក្រមសម្រេចមោឃភាពនីតិវិធីមួយជាដើម។ សាលក្រមពីរប្រភេទនេះ អាចតុលាការចេញដាច់ដោយឡែកពីសាលក្រមលើអង្គសេចក្ដី។

ប្រធានសភាព្រហ្មទណ្ឌពិនិត្យថា តើបណ្ដឹងសាទុក្ខនោះទាក់ទងនឹងការសម្រេចបញ្ចប់នីតិវិធីដូចការអះអាងរបស់អ្នកប្ដឹងដែរឬទេ។ បើមានហេតុផលពិតមែនសភាព្រហ្មទណ្ឌទទួលយកទៅវិនិច្ឆ័យ។ បើមិនពិត គាត់អាចសម្រេចមិនទទួលបណ្ដឹងសាទុក្ខតែម្ដង ឬគាត់ប្រកាសទទួលជាបន្ទាន់ បើរឿងសាទុក្ខនោះមានផលប្រយោជន៍ដល់សណ្ដាប់ធ្នាប់សាធារណៈ ឬអភិបាលកិច្ចល្អនៃយុត្តិធម៌[52]។

ចំពោះបណ្ដឹងទាក់ទងនឹងការសម្រេចដែលមិនបញ្ចប់នីតិវិធី គេមិនត្រូវទទួលទេ ប៉ុន្តែច្បាប់អនុញ្ញាតឱ្យទទួលក្នុងលក្ខខណ្ឌដែល បណ្ដឹងនោះមានការចាំបាច់ខ្ពស់ដល់យុត្តិធម៌[53]។ ក្នុងករណីនេះ ប្រធានសភាព្រហ្មទណ្ឌ ត្រូវធ្វើសេចក្ដីសម្រេចទទួល ឬមិនទទួលក្នុងរយៈពេល ៨ថ្ងៃ ចាប់ពីថ្ងៃទទួលសំណុំរឿង។ បើប្រធានសភាទទួលនៅក្នុងរយៈពេលដែលច្បាប់កំណត់

---

48 http://www.courdecassation.fr/institution_1/savoir_plus_institution_2845/presentation_cour_cassation_11982.html មើលនៅថ្ងៃទី ២៣ ធ្នូ ២០១០។

49 Gérard Couchez, Procédure civile, (Armand Colin, 11e édition, 2000) p. 312-313.

50 Jean PRADEL, Procédure Pénale, (Editions Cujas, 6e édition 1992), p. 627.

51 មាត្រា ៥៧០ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

52 មាត្រា ៥៧០ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

53 Jean PRADEL, Procédure Pénale, (Editions Cujas, 6e édition 1992), p. 628.

សម្រាប់បណ្តឹងសាទុក្ខនេះ សេចក្តីសម្រេចដែលមិនបញ្ចប់នីតិវិធីនេះ មិនអាចអនុវត្តបានទេ ហើយតុលាការក្រោមមិនត្រូវសម្រេចដល់អង្គសេចក្តីទេ រហូតទាល់តែសភាព្រហ្មទណ្ឌសម្រេចសេចក្តីលើបណ្តឹងសាទុក្ខនោះក្នុងរយៈពេល២ខែសិន។

គេមិនអាចប្តឹងសាទុក្ខទល់នឹង សាលដីការបស់សាលាឧក្រិដ្ឋដែលសម្រេចឱ្យជនជាប់ចោទរួចពីការចោទប្រកាន់បានទេ។ ការហាមឃាត់នេះអនុវត្តចំពោះបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាអមតុលាការនេះផងដែរ[54]។

**តំណាងផ្លូវច្បាប់៖** តំណាងផ្លូវច្បាប់សម្រាប់ភាគីដើមបណ្តឹង និងចុងចម្លើយ គឺជាកាតព្វកិច្ចនៅមុខតុលាការវិនិច្ឆ័យ លើកលែងតែក្នុងរឿងព្រហ្មទណ្ឌ និងរឿងបោះឆ្នោត។ មានគណៈមេធាវីមួយនៅអមតុលាការវិនិច្ឆ័យ និងក្រុមប្រឹក្សារដ្ឋដែលមានសមាជិកទាំងអស់៩៣ នាក់ក្នុង៦០ការិយាល័យនៅពេលបច្ចុប្បន្ន។ មានតែមេធាវីដែលចុះបញ្ជីនៅក្នុងគណៈមេធាវីនេះទេដែលអាចប្រកបវិជ្ជាជីវៈនៅមុខតុលាការនេះបាន។ មេធាវីទាំងនេះត្រូវទទួលបានការយល់ព្រមឱ្យចុះឈ្មោះ ស្របតាមលក្ខណៈវិនិច្ឆ័យពិសេសនិងតឹងរឹងបំផុត[55]។

មេធាវីទាំងនេះជាអ្នកឱ្យយោបល់ និងធ្វើជាតំណាងខាងច្បាប់។ គេនឹងជួយពិនិត្យបណ្តឹង និងឱ្យយោបល់ថា តើបណ្តឹងនោះមានឱកាសសមល្មមនឹងបានតុលាការបដិសេធសាលក្រមដែលរងបណ្តឹងនោះដែរ ឬទេ។ បើមើលឃើញបរាជ័យទាំងស្រុង គេនឹងឃាត់មិនឱ្យភាគីបន្តបណ្តឹងទេ។ ប៉ុន្តែបើភាគីចង់បន្ត គាត់ជាអ្នកធ្វើតំណាង និងរៀបចំការវែកញែកគាំទ្រជំហររបស់ភាគីដើម្បីដាក់ជូនទៅតុលាការ។ ក្រៅពីនេះ មេធាវីនេះជួយគូក្តីនៅគ្រប់នីតិវិធីទាំងអស់នៃតុលាការ។

គេត្រូវបង់ថ្លៃសេវារបស់មេធាវី ប៉ុន្តែរដ្ឋអាចផ្តល់ជំនួយហិរញ្ញវត្ថុដើម្បីទូទាត់សេវាមេធាវីបានដែរ បើភាគីនោះមានធនធានហិរញ្ញវត្ថុមិនគ្រប់គ្រាន់។

**ការដាក់បណ្តឹងសាទុក្ខ៖** ពាក្យបណ្តឹងសាទុក្ខត្រូវចុះហត្ថលេខាដោយមេធាវីជាតំណាង។ ពាក្យបណ្តឹងនោះត្រូវបញ្ជូនទៅឱ្យភាគីចុងចម្លើយ។ នៅក្នុងរឿងរដ្ឋប្បវេណី ក្រោយពីចុះបញ្ជីបណ្តឹងហើយ ភាគីប្តឹងសាទុក្ខត្រូវធ្វើសារណាទាមទារមួយ ដែលបរិយាយពីចំណុចច្បាប់នានាដែលគាត់អះអាងថា តុលាការថ្នាក់ក្រោមអនុវត្តមិនត្រឹមត្រូវ និងបង្ហាញនិងវែកញែកពីចំណុចច្បាប់ដែលគាត់យល់ថាត្រឹមត្រូវដើម្បីគាំទ្រការទាមទាររបស់គាត់។ សារណានោះត្រូវជូនភ្ជាប់មកជាមួយនូវសេចក្តីចម្លងសាលក្រមដែលសុំឱ្យបដិសេធផងដែរ។ រីឯចុងចម្លើយអាចដាក់សារណាការពារដើម្បីឆ្លើយតបទៅនឹងការអះអាងរបស់ដើមបណ្តឹងសាទុក្ខ។ រយៈពេលសម្រាប់ដាក់

---

[54] មាត្រា ៥៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំងចែងថា ៖ "សេចក្តីសម្រេចលើកលែងចោទប្រកាន របស់សាលាឧក្រិដ្ឋអាចជំទាសបាន តាមរយៈបណ្តឹងសាទុក្ខអាចធ្វើបាន កាលណាបណ្តឹងនេះធ្វើឡើងក្នុងគោលបំណងតែមួយគឺដើម្បីផលប្រយោជន៍នៃច្បាប់ ហើយមិនអាចធ្វើឱ្យខូចប្រយោជន៍នៃភាគីដែលត្រូវបានរួចខ្លួននោះហើយបានទេ។"

[55] ចំពោះព័ត៌មានលំអិតស្តីពីគណៈមេធាវី Ordre des Avocats au Conseil d'État et à la Cour de Cassation សូមមើលទំព័រវែបសាយ www.ordre-avocats-cassation.fr/histoire_fr.html

ជូនសារណាទាមទារគឺ ៤ ខែចាប់ពីថ្ងៃដាក់បណ្តឹង និងសម្រាប់សារណាការពារគឺរយៈពេល ២ ខែ ចាប់ពីថ្ងៃដែលតុលាការវិនិច្ឆ័យជូនដំណឹងឱ្យដាក់សារណាទាមទារ។ បើគ្មានសារណាទេ តុលាការនឹងមិនពិនិត្យរឿងក្តីនោះទេ។

**អានុភាពនៃបណ្តឹងសាទុក្ខ៖** ដូចតុលាការសម័យមុនៗដែរ នៅក្នុងរឿងរដ្ឋប្បវេណីការដាក់ពាក្យបណ្តឹងសាទុក្ខ ជាទូទៅមិននាំឱ្យមានការបង្អង់ ការអនុវត្តសេចក្តីសម្រេចរបស់តុលាការដែលរងបណ្តឹងសាទុក្ខនោះទេ[56]។ ប៉ុន្តែមានច្បាប់ដោយឡែកដែលហាមឃាត់ការអនុវត្តសាលក្រម កាលណាមានបណ្តឹងសាទុក្ខ។ ឧទាហរណ៍ មាត្រា១០៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីតម្រូវឱ្យបង្អង់ការអនុវត្តសាលដីកាដែលសម្រេចរឿងសញ្ជាតិ នៅពេលណាមានបណ្តឹងសាទុក្ខ។ មាត្រា១១២១ ក៏តម្រូវឱ្យបង្អង់ការអនុវត្តសាលក្រមលែងលះដែរ ប៉ុន្តែមិនអាចបង្អង់ការអនុវត្តកាតព្វកិច្ចមេបាបានទេ។

នៅក្នុងរឿងព្រហ្មទណ្ឌ មាត្រា៥៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា បើមានបណ្តឹងសាទុក្ខ ការអនុវត្តសាលដីកាផ្នែកខាងព្រហ្មទណ្ឌ ត្រូវបង្អង់នៅក្នុងរយៈពេលកំណត់សម្រាប់ទុកឱ្យភាគីប្តឹងសាទុក្ខ ឬរហូតដល់តុលាការវិនិច្ឆ័យប្រកាសសាលដីកា លើកលែងតែក្នុងលក្ខខណ្ឌមួយចំនួន។ ប៉ុន្តែសាលដីកាផ្នែកខាងរដ្ឋប្បវេណីមិនអាចបង្អង់ការអនុវត្តបានទេ។

លក្ខខណ្ឌដែលមិនបង្អង់ការអនុវត្តសាលក្រមនោះមានដូចជា កាលណាតុលាការឧទ្ធរណ៍យល់ស្របតាមសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ដើម្បីបន្តការឃុំឃាំងដោយសារកាលៈទេសៈណាមួយ និងក្នុងរឿងមជ្ឈិម នោះតុលាការវិនិច្ឆ័យក៏សំរេចយល់ស្របទៅតាមនោះដែរ។

រឿងមួយទៀតគឺ ការត្រួតពិនិត្យដោយតុលាការត្រូវបញ្ចប់ បើតុលាការឧទ្ធរណ៍មិនសម្រេចបន្ត។ ក៏ប៉ុន្តែ បើតុលាការថ្នាក់ក្រោមសម្រេចលើកលែងចោទប្រកាន់ ឬចេញសាលក្រមព្យួរទោសឬសាកល្បង នោះជនជាប់ចោទត្រូវតែបានដោះលែងជាបន្ទាន់ ទោះបីមានអ្នកណាប្តឹងសាទុក្ខក៏ដោយ។ បើជនជាប់ចោទត្រូវបានជាប់ឃុំឃាំងបណ្តោះអាសន្ន ហើយរយៈពេលឃុំឃាំងដែលបានទទួលស្មើនឹងចំនួនទោសដែលបានដាក់ នោះជនជាប់ចោទក៏ត្រូវដោះលែងជាបន្ទាន់ដែរ ទោះបីមានបណ្តឹងសាទុក្ខក៏ដោយ (មាត្រា ៥៦៩ ក្រមនីតិវិធីព្រហ្មទណ្ឌ)។

**ការទទួលយកបណ្តឹងសាទុក្ខ៖** កាលពីសម័យមុនតុលាការវិនិច្ឆ័យបារាំងមានការិយាល័យពិនិត្យបណ្តឹងសាទុក្ខ តមកហៅថាសភាពិនិត្យបណ្តឹងសាទុក្ខ ដែលមាននាទីសម្រេចពិនិត្យនិងសម្រេចថា ត្រូវទទួលឬមិនត្រូវទទួលបណ្តឹងសាទុក្ខមួយដែលបានដាក់មក។ នៅឆ្នាំ ១៩៤៧ សភាពិនិត្យបណ្តឹងនេះត្រូវបានលុបចោល។ ការលុបចោលសភាត្រួតពិនិត្យបណ្តឹង

---

[56] មាត្រា ១០០៩-១ នៃក្រមនីតិវិធីរដ្ឋប្បវេណីចែងថា ប្រធានតុលាការវិនិច្ឆ័យ បើមានការស្នើសុំពីចុងចម្លើយ នឹងសម្រេចឱ្យដករឿងក្តីពីបញ្ជីបណ្តឹង បើដើមបណ្តឹងសាទុក្ខគ្មានភស្តុតាងបង្ហាញថា គាត់បានអនុវត្តសេចក្តីសម្រេចដែលរងសាទុក្ខនោះ លើកលែងតែក្នុងរឿងខ្លះ ដែលច្បាប់កំណត់ថា បណ្តឹងសាទុក្ខបង្អង់ការអនុវត្តសេចក្តីសម្រេច។

សាទុក្ខនេះនាំឱ្យមានការហូរចូលបណ្តឹងដោយគ្មានការច្រោះ។

បណ្តឹងសាទុក្ខនៅក្នុងតុលាការវិនិច្ឆ័យបារាំងត្រូវឆ្លងប្រព័ន្ធច្រោះមួយ ដើម្បីទប់ទល់នឹងចំនួនកាន់តែច្រើនឡើងនៃបណ្តឹង។ ផលវិបាកនៃការហូរចូលបណ្តឹងដោយសេរីគឺ ការយឺតយ៉ាវក្នុងការចេញសាលដីកាថ្វីបើចំនួនសភានិងចៅក្រមត្រូវបានបង្កើន និងការកើនឡើងនៃចំនួនដ៏សន្ធឹកសន្ធាប់នៃ សេចក្តីសេចក្តីសម្រេច ដែលជាមូលហេតុនាំឱ្យមានការប្រឈមនឹងហានិភ័យនៃការបែកខ្ញែក និងភាពមិននឹងនរនៃយុត្តិសាស្ត្រ[57]។ នៅឆ្នាំ២០០១ ប្រព័ន្ធច្រោះត្រូវបានស្តារឡើងវិញ ដោយច្បាប់រៀបចំអង្គការតុលាការកំណត់ឱ្យសភានីមួយៗនៃតុលាការវិនិច្ឆ័យចាត់ចៅក្រមបីនាក់ឱ្យពិនិត្យបណ្តឹង ក្រោយពីភាគីបានដាក់សារណា។ ចៅក្រមទាំងនេះអាចចេញសេចក្តីសម្រេចមិនទទួលយកបណ្តឹងសាទុក្ខ ដោយសារបណ្តឹងនោះគ្មានលក្ខណៈអាចទទួលយកបាន ឬគ្មានមូលដ្ឋានជាដុំកំភួនដែលត្រូវសាទុក្ខ។

បណ្តឹងសាទុក្ខគ្មានលក្ខណៈឱ្យទទួលបាន (pourvois irrécevables) គឺជាប្រភេទបណ្តឹងដែលបទបញ្ញត្តិច្បាប់ហាមឃាត់តែម្តង ដូចជាបណ្តឹងសាទុក្ខដែលហួសកំណត់ត្រូវប្តឹង, ប្រភេទសាលក្រមដែលច្បាប់ហាមឃាត់មិនឱ្យទទួលប្តឹងសាទុក្ខ។ ប្រធានផ្នែកនៃសភាជូនដំណឹងដោយឆន្ទៈខ្លួនគាត់ពីមូលហេតុនៃការមិនទទួលបណ្តឹងបែបនេះ(មាត្រា១០១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីបារាំង)។

បណ្តឹងសាទុក្ខដែលគ្មានមូលដ្ឋានជាដុំកំភួន (pourvois non fondés sur un ou des moyens sérieux) គឺជាបណ្តឹងដែលគ្មានលទ្ធភាពនឹងទទួលបានជោគជ័យទាល់តែសោះ។ ឧទាហរណ៍ បណ្តឹងសាទុក្ខដែលមិនបានថ្លែងពីមូលហេតុនៃការសាទុក្ខ បណ្តឹងសាទុក្ខដែលផ្តោតតែទៅលើបញ្ហាអង្គហេតុ និងមិនមែនលើអង្គច្បាប់ សាច់រឿងដែលប្តឹងសាទុក្ខនោះជាកម្មវត្ថុនៃការសម្រេចជាអធិបតេយ្យនៃចៅក្រមជំនុំជម្រះអង្គហេតុដែលត្រូវដោះស្រាយ ដូចជាអំណាចអធិបតេយ្យរបស់ចៅក្រមជំនុំជម្រះដើម្បីធ្វើមូលវិចារណ៍ ឬការវិនិច្ឆ័យដើម្បីកំណត់ពីចេតនារបស់ភាគីនៃកិច្ចសន្យាជាដើម។ ម៉្យាងវិញទៀត បណ្តឹងសាទុក្ខដែលនឹងមិននាំទៅរកការបង្កើតយុត្តិសាស្ត្រថ្មី ឬការកែប្រែយុត្តិសាស្ត្រចាស់[58]អាចចាត់ទុកថា គ្មានមូលហេតុជាដុំកំភួនដែរ។

[57] http://www.courdecassation.fr/institution_1/autres_publications_discours_2039/publications_2201/admission_pourvois_cassation_8424.html (ទំព័រ១) មើលនៅថ្ងៃទី ២៣ ធ្នូ ២០១០។

[58] ប្រភពដូចខាងលើ ទ.៣។ ចំពោះមូលហេតុផ្សេងៗទៀតដែលតុលាការវិនិច្ឆ័យបដិសេធមិនទទួលបណ្តឹងសាទុក្ខ សូមមើលទំព័រវេបសាយរបស់តុលាការនេះ http://www.courdecassation.fr/colloques_activites_formation_4/2010)3159/lacabarats_president_15274.html?idprec=13939

ក្នុងបណ្តាបណ្តឹងសាទុក្ខដែលចូលទៅសភានីមួយៗដូចតទៅ បណ្តឹងសាទុក្ខដែលសភានីមួយៗសម្រេចមិនទទួលយកនៅឆ្នាំ២០០៨ គឺ៤៣% នៅសភារដ្ឋប្បវេណីទីមួយ ៣៩% នៅសភាពាណិជ្ជកម្ម និង ១៩ % នៅសភាផ្នែកសង្គម[59]។

ការអនុវត្តនៅក្នុងការសម្រេចពីការមិនទទួលបណ្តឹងសាទុក្ខ គឺនៅពេលបណ្តឹងចូលទៅសភាណាមួយហើយ ចៅក្រមរបាយការណ៍ជាអ្នកសិក្សា និងចម្រាញ់សំណុំរឿងជាមុនឃើញថារឿងណាហាក់ដូចជាមិនត្រូវទទួល។ បើរឿងមួយមិនត្រូវទទួល ចៅក្រមរបាយការណ៍ស្នើចុះបញ្ជីរឿងនោះនៅក្នុងបញ្ជីសម្រាប់សវនាការ ដែលពិនិត្យលើរឿងគ្មានលក្ខណៈឱ្យទទួលបាន និងរឿងគ្មានមូលដ្ឋានជាដុំកំភួន[60]។ ចៅក្រមរបាយការណ៍ចែងនៅក្នុងសាលាកប័ត្រមួយបញ្ជាក់ពីហេតុផលពីបណ្តឹងដែលគ្មានលក្ខណៈអាចទទួលបាន ឬគ្មានមូលដ្ឋានជាដុំកំភួន។ សាលាកប័ត្រនេះត្រូវបានបញ្ជូនទៅមហាអយ្យការដែរ។ តមកទៀត បណ្តឹងសាទុក្ខនោះត្រូវបានដាក់បញ្ចូលក្នុងសវនាការ ដែលជាទូទៅត្រូវជំនុំជម្រះដោយ ក្រុមប្រឹក្សាមានកម្រិត (formation restreinte) និងមានករណីខ្លះដោយ ក្រុមប្រឹក្សាសភាធម្មតា ឬរហូតដល់តុលាការពេញអង្គទៅតាមភាព ស្មុគស្មាញក្នុងការសម្រេច[61]។

**ការចាត់ការបណ្តឹងសាទុក្ខ៖** នៅពេលដែលបណ្តឹងសាទុក្ខត្រូវបានទទួលយកដើម្បីវិនិច្ឆ័យហើយ ប្រធានសភាដែលពាក់ព័ន្ធចាត់តាំងចៅក្រមរបាយការណ៍ម្នាក់ឱ្យទទួលយកសំណុំរឿងដែលសាទុក្ខ។

ចៅក្រមរបាយការណ៍នេះ (conseiller rapporteur) រៀបចំធ្វើរបាយការណ៍ដែលបញ្ជាក់ពីអង្គហេតុ, នីតិវិធីនៃតុលាការថ្នាក់ក្រោម, ការវិភាគទៅលើសេចក្តីវែកញែករបស់ភាគី, ការកំណត់ពីបញ្ហាច្បាប់នៅក្នុងរឿងក្តីនោះ ការយោងទៅលើយុត្តិសាស្ត្រដែលអាចអនុវត្តមកលើរឿងក្តី ព្រមទាំងធ្វើសេចក្តីព្រាងសាលដីកាជាជម្រើសនានា អាស្រ័យទៅលើដំណោះស្រាយនានាដែលចៅក្រមរបាយការណ៍នោះយល់ថាអាចមានចំពោះរឿងនេះ។ ចៅក្រមរបាយការណ៍ធ្វើអនុសាសន៍ស្តីពីប្រភេទក្រុមប្រឹក្សាដែលនឹងត្រូវជំនុំជម្រះផងដែរ ដូចជា ក្រុមប្រឹក្សាមានកម្រិត (formation restreinte) អង្គជំនុំតាមផ្នែក (formation de section) ឬសភាពេញអង្គ (formation plénière)[62]។ របាយការណ៍នេះត្រូវបញ្ជូនទៅចៅក្រមដែលត្រូវពិចារណារឿងនេះ ដើម្បីជាយោបល់ប៉ុណ្ណោះ ដោយមិនមានអានុភាពត្រូវតែធ្វើតាមនោះទេ។ ក្រៅពីរបាយការណ៍ ចៅក្រមរបាយការណ៍សរសេរកំណត់ពីមតិ

---

[59] ប្រភពដូចគ្នាខាងលើ។

[60] Guy Canivet, La procedure d’admission des pourvois en cassation, 2002: http://courdecassation.fr/institution_1/autres_publications_discours_2039/publications_2201/admission_pourvois_cassation_8424.html

[61] ប្រភពដូចខាងលើ។

[62] http://www.courdecassation.fr/institution_1/savoir_plus_institution_2845/presentation_cour_cassation_11982.html

របស់ខ្លួនផ្ទាល់ទៅលើរឿងក្តីនោះ។ កំណត់នេះជាឯកសារសម្ងាត់ដែលបញ្ជូនទៅតែចៅក្រមជំនុំជម្រះរឿងនោះប៉ុណ្ណោះ។

របាយការណ៍របស់ចៅក្រមត្រូវបញ្ជូនទៅឱ្យអគ្គរដ្ឋអាជ្ញាអមតុលាការវិនិច្ឆ័យដែរ ដើម្បីឱ្យគាត់ធ្វើមូលវិចារណ៍និងបញ្ជាក់ពីទស្សនៈរបស់គាត់នៅឯសវនាការ។ ភាគីក៏អាចទទួលព័ត៌មានស្តីពី ខ្លឹមសារនៃរបាយការណ៍ មតិរបស់អគ្គរដ្ឋអាជ្ញាដែរ ដែលទាំងនេះត្រូវបានបញ្ជូនតាមរយៈមេធាវី។

បន្ទាប់មកប្រធានសភា និងព្រឹទ្ធចៅក្រមបើកការប្រជុំមួយ ដើម្បីពិនិត្យនិងកំណត់បញ្ហានានាដែលក្រុមប្រឹក្សាជំនុំជម្រះត្រូវយកចិត្តទុកដាក់ជាពិសេស ព្រមទាំងកំណត់ពីប្រភេទក្រុមប្រឹក្សាដែលត្រូវជំនុំជម្រះ។ បើពិនិត្យទៅឃើញថាបណ្តឹងនោះតម្រូវឱ្យមានដំណោះស្រាយត្រឹមជាការច្រានចោលបណ្តឹងសាទុក្ខ ការបដិសេធ សាលក្រម ឬសាលដីកា ឬការមិនទទួលយកបណ្តឹង នោះក្រុមប្រឹក្សាដែលត្រូវជំនុំជម្រះមានសមាជិកតែ ៣រូប ប៉ុណ្ណោះ[63]។ ក្រៅពីនោះ ក្រុមប្រឹក្សាជំនុំជម្រះត្រូវមានសមាជិកយ៉ាងហោច ៥រូប។

**សវនាការ៖** ដោយសារតុលាការវិនិច្ឆ័យជាតុលាការផ្នែកខាងអង្គច្បាប់ តុលាការនេះមិនជជែករឿងអង្គហេតុឡើងវិញទេ ហើយក៏មិនបាច់ផ្ទៀងផ្ទាត់ថាអង្គហេតុនោះពិត ឬមិនពិតដែរ។ អង្គហេតុត្រូវតែបានសម្រេចដាច់ស្រេចរួចរាល់ហើយ នៅឯតុលាការថ្នាក់ក្រោម។ តុលា-ការវិនិច្ឆ័យវែកញែកតែលើការអះអាងខាងអង្គច្បាប់ ដែលអនុវត្តទៅលើអង្គហេតុដែលបានសម្រេចដាច់ស្រេចមកហើយនេះ[64]។ សវនាការត្រូវធ្វើជាសាធារណៈ។

សវនាការនិងសេចក្តីសម្រេចអាចធ្វើដោយសភានីមួយៗ ឬសភារួម(ដែលមានយ៉ាងតិចបីសភា) ឬដោយតុលាការពេញអង្គ[65]។ ជាទូទៅ នីតិវិធីនៃការជំនុំជម្រះនៅតុលាការវិនិច្ឆ័យបារាំង គឺជានីតិវិធីដែលផ្អែកលើការសរសេរ។

ការជំនុំជម្រះដោយសភានីមួយៗត្រូវធ្វើឡើងដោយក្រុមប្រឹក្សាមួយ ដែលមានចៅក្រមយ៉ាងហោច ៥នាក់ (ទៅតាមប្រភេទរឿង) ឬសភាទាំងមូល ដែលនៅក្នុងនោះប្រធានសភាធ្វើជាអធិបតី។

ការជំនុំជម្រះដោយសភាពេញអង្គ (formation plénière) កើតឡើងនៅពេលប្រធានសភាសម្រេចឱ្យធ្វើពេញអង្គ ដោយសាររឿងដែលប្តឹងសាទុក្ខមកមានលក្ខណៈរំញោច ឬពេលណាគាត់មើលទៅឃើញថា សេចក្តីសម្រេចទៅលើបណ្តឹងសាទុក្ខនឹងនាំឱ្យមានការប្រែប្រួលយុត្តិសាស្ត្រមុនៗ[66] ឬមួយទៀត បើសិនជាតំណាងមហាអយ្យការស្នើសុំឱ្យជំនុំជម្រះបែបនេះនៅពេលបើកសវនាការ។

63 ប្រភពដូចខាងលើ សូមមើលផ្នែក « L´instruction et le jugement du pourvoi »

64 www.courdecassation.fr/about_the_court_9256.html

65 ព័ត៌មានលំអិតដែលបរិយាយជាបន្តបន្ទាប់តទៅទៀតនេះត្រូវបានដកស្រង់ពីប្រភពដូចខាងលើ។

66 http://www.courdecassation.fr/institution_1/savoir_plus_institution_2845/presentation_cour_cassation_11982.html

ការជំនុំជម្រះដោយសភាចម្រុះ (chambres mixtes) ដែលធ្វើជាអធិបតីដោយប្រធានតុលាការ និងសមាសភាពចៅក្រម ៤រូប ពីសភានីមួយៗដែលពាក់ព័ន្ធ (ប្រធានសភា, ព្រឹទ្ធ-ចៅក្រម, និងចៅក្រមពីរនាក់)។ បើរឿងត្រូវជម្រះដោយសភាបី នោះចំនួនចៅក្រមត្រូវមាន ១៣នាក់។ ការជំនុំជម្រះដោយសភាចម្រុះត្រូវបានសម្រេចឱ្យធ្វើ នៅពេលណារឿងណាមួយធ្លាក់ក្នុងសមត្ថកិច្ចច្រើនសភា ឬដោយសារដំណោះស្រាយអាចធ្វើឱ្យមានការមតិគ្នាផ្ទុយគ្នាលើយុត្តិសាស្ត្រ ឬមួយទៀត បើសិនជាតំណាងមហាអយ្យការស្នើសុំឱ្យជំនុំជម្រះបែបនេះ នៅពេលបើកសវនាការ[67]។

ការជំនុំជម្រះដោយតុលាការពេញអង្គ (assemblées plénières) មានសមាសភាព ១៩រូប គឺ ប្រធានតុលាការជាអធិបតី, ប្រធានសភានីមួយៗ (ទាំងអស់ ៦នាក់) ព្រឹទ្ធចៅក្រមនីមួយៗមកពីគ្រប់សភា (៦នាក់) និងចៅក្រមប្រឹក្សាមកពីសភានីមួយៗ (ទាំងអស់ ៦នាក់)។ ការជំនុំជម្រះដោយតុលាការពេញអង្គធ្វើឡើងកាលណាបណ្ដឹងសាទុក្ខ លើកទីពីរត្រូវបានដាក់មកម្ដងទៀតលើការអះអាងដដែល ឬនៅពេលដែលអគ្គរដ្ឋអាជ្ញាអមតុលាការវិនិច្ឆ័យទាមទារឱ្យធ្វើការជំនុំជម្រះពេញអង្គមុនពេលតុលាការបើកសវនាការ[68]។

នៅក្នុងសវនាការ ចៅក្រមរបាយការណ៍ឡើងថ្លែងពីចំណុចសំខាន់ៗនៃរឿងក្ដីព្រមទាំងទស្សនៈរបស់គាត់។ បន្ទាប់មក តាមលំដាប់អតីតភាព ព្រឹទ្ធចៅក្រម និងចៅក្រមប្រឹក្សាឡើងថ្លែងយោបល់របស់គាត់ ហើយជាចុងក្រោយបង្អស់ប្រធានសភាថ្លែងមតិរបស់គាត់។

មេធាវីរបស់ភាគីអាចឡើងថ្លែងពន្យល់បន្ថែមទៅលើសារណារបស់ខ្លួនបានដែរ បើសិនជាគេបានសុំឡើងថ្លែង និងត្រូវបានអនុញ្ញាតដោយប្រធានសភា ក៏ប៉ុន្តែនៅក្នុងការអនុវត្តកម្រមានការឡើងវែកញែកដោយមេធាវីណាស់[69]។

គូភាគីមិនអាចថ្លែងអ្វីនៅក្នុងសវនាការនេះទេ ព្រោះនាទីវែកញែករឿងច្បាប់ជាភារកិច្ចផ្ដាច់មុខរបស់មេធាវី។ អគ្គរដ្ឋអាជ្ញាឡើងថ្លែងពីមតិរបស់គាត់ក៏បាន ឬក៏យោងទៅលើយោបល់ដែលគាត់បានសរសេរ និងដាក់ជូនតុលាការរួចហើយក៏បាន។

**ការពិចារណា៖** ការពិចារណាត្រូវធ្វើដោយសម្ងាត់ និងដឹកនាំដោយប្រធាន និងចូលរួមដោយចៅក្រមប្រឹក្សា។ សេចក្ដីសម្រេចត្រូវធ្វើជាអនាមិក ដោយសម្លេងភាគច្រើន និងគ្មានបង្ហាញពីមតិជំទាស់ទេ។

**អានុភាពនៃសេចក្ដីសម្រេចនៃតុលាការវិនិច្ឆ័យ៖** សេចក្ដីសម្រេចរបស់តុលាការវិនិច្ឆ័យមានលទ្ធផលពីរយ៉ាងគឺការច្រានចោលបណ្ដឹងសាទុក្ខ (rejeter, dismiss) និងការបដិសេធសាលក្រម ឬសាលដីកា (casser, quash)។

---

[67] ដូចប្រភពដូចខាងលើ។

[68] ដូចប្រភពដូចខាងលើ។

[69] Gérard Couchez, Procédure civile, (Armand Colin, 11e édition, 2000) p. 369.

ការច្រានចោលកើតឡើងដោយសារបណ្តឹងនោះគ្មានលក្ខណៈគួរឱ្យទទួលបាន ឬគ្មានមូលដ្ឋានជាដុំកំភួន ដូចបានបរិយាយនៅក្នុងផ្នែកខាងលើ។ សេចក្តីសម្រេចច្រានចោលនេះមិនអាចប្តឹងសាទុក្ខឡើងវិញបានទេ (មាត្រា ៦២១ ក្រមនីតិវិធីរដ្ឋប្បវេណី)។ ការប្តឹងសាទុក្ខដោយបំពានអាចទទួលពិន័យជាប្រាក់ទៀតផង យ៉ាងច្រើនបំផុត ៣ ពាន់អឺរ៉ូ (មាត្រា ៨២៨ ក្រមនីតិវិធីរដ្ឋប្បវេណី)។

ការបដិសេធសាលក្រម ឬសាលដីកាកើតឡើងដោយសារ តុលាការមើលឃើញថា អ្នកប្តឹងមានហេតុផលត្រឹមត្រូវ ដូច្នេះតុលាការបដិសេធសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមទាំងមូល ឬមួយផ្នែក។ មាត្រា ៦២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីចែងថា ៖

> ចំពោះចំណុចដែលប៉ះពាល់ ការបដិសេធដាក់ភាគីឱ្យស្ថិតនៅក្នុងសភាពដែលគាត់មាន មុនសេចក្តីសម្រេចដែលត្រូវបានបដិសេធនោះឡើងវិញ។

មាត្រានេះមានន័យថា បើភាគីមួយចាញ់ក្តី រួចហើយបានប្តឹងឧទ្ធរណ៍ បន្ទាប់មកគាត់ចាញ់ក្តីនៅថ្នាក់ឧទ្ធរណ៍ទៀត នៅពេលដែលតុលាការវិនិច្ឆ័យបដិសេធសេចក្តីសម្រេចសាលាឧទ្ធរណ៍ នោះភាគីទាំងពីរស្ថិតមកនៅត្រឹមសភាពដំណាក់កាលដែលសាលាឧទ្ធរណ៍មិនទាន់សម្រេចសេចក្តី។ តុលាការដែលទទួលរឿងបង្វិលអាចជម្រះបានតែកម្មវត្ថុណាដែលតុលាការវិនិច្ឆ័យបានបដិសេធប៉ុណ្ណោះ រីឯចំណុចដែលតុលាការវិនិច្ឆ័យមិនប៉ះពាល់ត្រូវទុកនៅដដែលដូចពីមុនមានការប្តឹងសាទុក្ខ។

ការបដិសេធសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម នាំឱ្យមានស្ថានការណ៍ពីរកើតឡើង។ ទីមួយ ក្នុងករណីភាគច្រើន តុលាការវិនិច្ឆ័យបង្វិលរឿងទៅតុលាការថ្នាក់ក្រោមណាមួយផ្សេងទៀត ដែលមានថ្នាក់ និងប្រភេទដូចគ្នានឹងតុលាការដែលចេញសេចក្តីសម្រេចដែលត្រូវបដិសេធ (ដូចជា សភាពាណិជ្ជកម្មនៃតុលាការមួយ) ឬតុលាការថ្នាក់ក្រោមដដែលតែសមាសភាពចៅក្រមផ្សេង (មាត្រា៦២៦ ក្រមនីតិវិធីរដ្ឋប្បវេណី)។ ទីពីរ តុលាការវិនិច្ឆ័យបដិសេធដោយមិនបាច់បង្វិលរឿងទៅតុលាការថ្នាក់ក្រោម (មាត្រា ៦២៧ ក្រមដដែល)។

នៅក្នុងស្ថានការណ៍ទីមួយ តុលាការថ្នាក់ក្រោមត្រូវជម្រះសារឡើងវិញ ដោយទទួលយកក៏បាន ឬមិនទទួលយកក៏បាននូវទ្រឹស្តីដែលតុលាការវិនិច្ឆ័យបានណែនាំនៅក្នុងសាលដីការបស់ខ្លួន។ ប៉ុន្តែបើសាលដីកាបដិសេធត្រូវបានចេញ ដោយសវនាការនៃអង្គតុលាការទាំងមូល តុលាការថ្នាក់ក្រោមត្រូវតែប្រតិបត្តិតាមទ្រឹស្តីដែលណែនាំដោយ តុលាការវិនិច្ឆ័យ។ នៅពេលជំនុំជម្រះដោយតុលាការទទួលរឿងបង្វិលនេះ ភាគីត្រូវជជែកដេញដោលរឿងក្តីឡើងវិញ ទាំងអង្គហេតុ ទាំងអង្គច្បាប់ (លើកលែងតែចំណុចដែលតុលាការវិនិច្ឆ័យមិនបានបដិសេធ)។

ក្នុងស្ថានការណ៍ទីពីរ តុលាការវិនិច្ឆ័យអាចសម្រេចយកវិធីពីរ។ វិធីទីមួយ តុលាការអាចចេញសេចក្តីសម្រេចដោយ ខ្លួនឯងដោយមិនបាច់បង្វិល ព្រោះអង្គហេតុដែលបានកំណត់

ស្រេចបាច់ហើយដោយតុលាការថ្នាក់ក្រោមនោះ បើកឱ្យតុលាការអាចអនុវត្តវិធានច្បាប់ដោយត្រង់ៗទៅលើអង្គហេតុនោះតែម្តង។ ឧទាហរណ៍ តុលាការថ្នាក់ក្រោមអនុវត្តមាត្រាច្បាប់មួយមិនត្រឹមត្រូវ ដូច្នេះ តុលាការវិនិច្ឆ័យគ្រាន់តែយកមាត្រាមួយទៀតមកជំនួសតែម្តងនៅក្នុងសាលដីការបស់ខ្លួន។ ជម្លោះរបស់ភាគីត្រូវបានបញ្ចប់នៅត្រឹមចំណុចនេះតែម្តង (មាត្រា ៦២៧ ក្រមនីតិវិធីរដ្ឋប្បវេណី)។

វិធីមួយទៀត គឺតុលាការវិនិច្ឆ័យអាចយល់ឃើញថា ត្រូវសម្រេចរឿងដោយខ្លួនឯងដោយមិនបាច់បង្វិល ដោយសារសេចក្តីសម្រេចនោះនឹងមិននាំឱ្យមានការកាត់ក្តីសារជាថ្មីលើអង្គសេចក្តី (មាត្រា ៦២៧ ក្រមនីតិវិធីរដ្ឋប្បវេណី)។ ឧទាហរណ៍ អង្គហេតុមិនបង្ហាញឱ្យឃើញថាដើមបណ្តឹងបានធ្វើកំហុសអ្វីមួយស្របតាមការសម្រេចរបស់តុលាការថ្នាក់ក្រោម ដូចជាអង្គហេតុបង្ហាញថា ការចោទប្រកាន់នៅក្រោមបញ្ញត្តិច្បាប់មួយមិនចូលជាបទល្មើសមួយ។

**នីតិវិធីនៃការប្តឹងសាទុក្ខសម្រាប់រឿងព្រហ្មទណ្ឌ៖** នីតិវិធីសម្រាប់រឿងព្រហ្មទណ្ឌ ជាមូលដ្ឋានមិនខុសគ្នាពីនីតិវិធីសម្រាប់រឿងរដ្ឋប្បវេណីទេ។ មានការខុសគ្នាខ្លះត្រង់ចំណុចរយៈពេលកំណត់សម្រាប់ប្តឹងសាទុក្ខ និងតំណាងផ្លូវច្បាប់។

រយៈពេលសម្រាប់ប្តឹងសាទុក្ខគឺ ៥ថ្ងៃ រាប់ចាប់ពីថ្ងៃប្រកាសសេចក្តីសម្រេចចំពោះមុខ ឬពីថ្ងៃជូនដំណឹងពីសេចក្តីសម្រេចកំបាំងមុខអ្នកប្តឹងសាទុក្ខ។ ដោយសារនីតិវិធីនៅតុលាការវិនិច្ឆ័យជានីតិវិធីសរសេរ អ្នកប្តឹងត្រូវដាក់សារណារបស់ខ្លួនដែលតាក់តែងដោយខ្លួនឯង ឬដោយតំណាងណាមួយតាមការជ្រើសរើសរបស់ដើមបណ្តឹង រួមមានមេធាវីនៅតុលាការថ្នាក់ក្រោម ឬមេធាវីអមតុលាការវិនិច្ឆ័យដែលបានបញ្ជាក់នៅខាងលើ។ សារណានោះត្រូវតែចុះហត្ថលេខាដោយអ្នកប្តឹង ទោះបីជាអ្នកផ្សេងតាក់តែងឱ្យក៏ដោយ បើពុំដូច្នោះទេ បណ្តឹងនោះមិនអាចទទួលយកបានទេ។ សារណានោះត្រូវដាក់ក្នុងរយៈពេលយ៉ាងយូរ១០ថ្ងៃ ប៉ុន្តែបើអ្នកប្តឹងជាជនដែលត្រូវបានផ្តន្ទាទោស គេត្រូវដាក់សារណាក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីការដាក់បណ្តឹង។ ពេលវេលានេះត្រូវតែគោរពជាដាច់ខាត។

សារណាការពារគ្មានរយៈពេលកំណត់ទេ តែចុងចម្លើយត្រូវតែដាក់ឱ្យបានឆាប់ដែលអាចធ្វើទៅបាន ដើម្បីកុំឱ្យខូចផលប្រយោជន៍របស់ខ្លួន។ សារណាការពារត្រូវតែដាក់នៅការិយាល័យមេធាវីអមតុលាការវិនិច្ឆ័យ។

**មតិរបស់តុលាការវិនិច្ឆ័យ៖** ក្រៅពីធ្វើការវិនិច្ឆ័យលើបណ្តឹងឧទ្ធរណ៍ តុលាការវិនិច្ឆ័យមានអំណាចផ្តល់មតិដល់តុលាការថ្នាក់ក្រោមនៅក្នុងអំឡុងនៃការដំណើរការក្តីរបស់គេដែរ[70]។

[70] មាត្រា ១៥១-១ នៃច្បាប់លេខ ៩១-៤៩១ ចុះថ្ងៃទី ១៥ ឧសភា ១៩៩១។ សូមមើលនៅក្នុងទំព័រ https://www.legifrance.gouv.fr/affichTexte.do?cidTexte=JORFTEXT000000526330។

មតិទាំងនោះមិនមានអានុភាពចងកាតព្វកិច្ចទេ មានន័យថា តុលាការដែលស្នើសុំមតិរបស់តុលាការវិនិច្ឆ័យនោះអាចយល់ស្របតាមមតិនោះ ឬបោះចោលក៏បាន។

ដើម្បីឱ្យតុលាការវិនិច្ឆ័យអាចផ្តល់មតិរបស់ខ្លួនបាន លុះត្រាតែមានការស្នើសុំពីតុលាការថ្នាក់ក្រោមឱ្យបកស្រាយច្បាប់ដែលពាក់ព័ន្ធនឹងរឿងកំពុងចាត់ការ ហើយបញ្ហាច្បាប់នោះទៀតសោតជាបញ្ហាថ្មីដែលមិនដែលមានយុត្តិសាស្ត្រពីមុនបំភ្លឺ។ បញ្ហាច្បាប់ដែលចោទសួរជារឿងពិបាកហើយកើតនៅក្នុងជម្លោះមួយចំនួន ហើយជាបញ្ហាដែលមិនទាន់មាន ឬកំពុងត្រូវបានគេប្តឹងសាទុក្ខ។ ការផ្តល់យោបល់នេះត្រូវធ្វើនៅក្នុងរយៈពេល៣ខែ ចាប់ពីថ្ងៃស្នើសុំ[71]។ ការស្នើសុំនេះអនុវត្តចំពោះតែរឿងរដ្ឋប្បវេណីប៉ុណ្ណោះ។

## ឃ. តួនាទីរបស់មហាអយ្យការអមតុលាការវិនិច្ឆ័យបារាំង

ប្រវត្តិដើមនៃមហាអយ្យការនៃប្រទេសបារាំង ចេញមកពីស្នងការព្រះមហាក្សត្រនៅអមសាលាវិនិច្ឆ័យ(commissaire du roi) ។ ស្នងការនេះមានករណីយកិច្ចរក្សាការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ។ គាត់មានសិទ្ធិធ្វើបណ្តឹងសាទុក្ខដូចជាភាគីនៃវិវាទដែរ។ នៅក្នុងរឿងរដ្ឋប្បវេណីបើគាត់បានដឹងថា តុលាការចុងក្រោយបានចេញសាលក្រមដែលផ្ទុយនឹងច្បាប់ ឬទម្រង់ណាមួយហើយ(នីតិវិធី) ទោះបីភាគីមិនបានប្តឹងសាទុក្ខក៏ដោយ គាត់ត្រូវលើករឿងនោះទៅសាលាវិនិច្ឆ័យ។ បើគាត់បង្ហាញឱ្យឃើញថាទម្រង់ ឬច្បាប់ណាមួយត្រូវបានរំលោភ នៅក្នុងការវិនិច្ឆ័យរបស់សាលាជម្រះក្តីចុងក្រោយនោះ សាលាវិនិច្ឆ័យអាចសម្រេចបដិសេធសាលក្រមនោះ[72]។

ក្រោយពីការទម្លាក់រាជានិយមនៅឆ្នាំ១៧៩២មក គេផ្លាស់ឈ្មោះស្នងការព្រះមហាក្សត្រទៅជា "ស្នងការនៃអំណាចប្រតិបត្តិ"(commissaire du pouvoir exécutif)។ នៅឆ្នាំ១៨០២ គេប្តូរឈ្មោះមកជាស្នងការរដ្ឋាភិបាល (commissaire du gouvernment) ។ បន្ទាប់មកទៀត នៅឆ្នាំ១៨១០ តំណែងនេះមាន ឈ្មោះជាអគ្គរាជអាជ្ញា (procureur général)។

បច្ចុប្បន្ន មហាអយ្យការអមតុលាការវិនិច្ឆ័យមាន អគ្គរដ្ឋអាជ្ញា និងសហការី ៥០រូប ក្នុងនោះមានអគ្គមេធាវីព្រឹទ្ធបុរស ៥រូប (premiers avocats généraux) អគ្គមេធាវី (avocat général) ៤០រូប និងអគ្គមេធាវីជំនួយ (avocat général référendaires) ៥នាក់។ អគ្គរដ្ឋអាជ្ញាមិនចំណុះឱ្យរដ្ឋមន្ត្រីយុត្តិធម៌ទេ ហើយអគ្គមេធាវីធ្វើការដោយឯករាជ្យពីអគ្គរដ្ឋអាជ្ញា គឺអគ្គរដ្ឋអាជ្ញាមិនអាចបង្គាប់អគ្គមេធាវីនៅពេលគេបំពេញករណីយកិច្ចរបស់គេទេ[73]។

---

[71] www.courdecassation.fr/about_the_court_9256.html

[72] មាត្រា ២៥ ច្បាប់ស្តីពីការបង្កើតសាលាវិនិច្ឆ័យលើកដំបូង ២៧ វិច្ឆិកា ១៧៩០។

[73] http://www.courdecassation.fr/institution_1/savoir_plus_institution_2845/presentation_cour_cassation_11982.html

មហាអយ្យការនៅអមតុលាការវិនិច្ឆ័យមិនមែនជាភាគីមួយនៃវិវាទទេ។ ស្ថាប័ននេះអាចធ្វើបណ្តឹងសាទុក្ខនៅគ្រប់រឿង ទាំងរដ្ឋប្បវេណី ទាំងព្រហ្មទណ្ឌ។ បណ្តឹងសាទុក្ខនេះ គេហៅថាបណ្តឹងសាទុក្ខក្នុងផលប្រយោជន៍ច្បាប់។ បណ្តឹងសាទុក្ខក្នុងផលប្រយោជន៍នៃច្បាប់មិនដោះស្រាយផលប្រយោជន៍របស់ភាគីនៃជម្លោះទេ។

បេសកកម្មរបស់មហាអយ្យការគឺ ការរក្សាឱ្យមានភាពឯកសណ្ឋាននៅក្នុងការបកស្រាយច្បាប់ នៅក្នុងប្រយោជន៍ទូទៅ និងសណ្តាប់ធ្នាប់សាធារណៈ។ នៅក្នុងរឿងព្រហ្មទណ្ឌ មហាអយ្យការអាចផ្តើមបណ្តឹងសាទុក្ខ ដោយខ្លួនឯងទល់នឹងសាលដីការបស់សភាស៊ើបសួរនៃតុលាការឧក្រិដ្ឋ និងទល់នឹងសាលក្រមសម្រេចជាចុងក្រោយ ក្នុងរឿងឧក្រិដ្ឋ មជ្ឈិម និងលហុ បើគាត់មើលឃើញថាសាលក្រម/សាលដីកាទាំងនោះសម្រេចដោយបំពានលើច្បាប់[74]។ មហាអយ្យការជាឆ្នាំការពារច្បាប់ទល់នឹងការរំលោភលើសិទ្ធិជនជាប់ចោទផង និងការរំលោភសិទ្ធិសាធារណៈផង។ មាត្រា ៦២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ៖

> "នៅពេលតុលាការឧទ្ធរណ៍ ឬតុលាការឧក្រិដ្ឋ តុលាការមជ្ឈិម ឬតុលាការលហុបានចេញសាលក្រមជាចុងក្រោយ ដែលសមរងនឹងការប្តឹងសាទុក្ខ ប៉ុន្តែគ្មានភាគីណាមួយដាក់ពាក្យប្តឹងនៅក្នុងពេលជាកំណត់ អគ្គរដ្ឋអាជ្ញាអមតុលាការវិនិច្ឆ័យអាចប្តឹងសាទុក្ខដោយចិត្តគាត់ផ្ទាល់បាន ទោះបីរយៈពេលជាកំណត់បានកន្លងផុតទៅហើយក្តី ប៉ុន្តែគាត់ធ្វើដូច្នេះ ក្នុងផលប្រយោជន៍នៃច្បាប់ប៉ុណ្ណោះ។ តុលាការវិនិច្ឆ័យត្រូវចេញសេចក្តីសម្រេចលើ បញ្ហាទទួលបណ្តឹង និងលើមូលកភាពនៃបណ្តឹង។ បើពាក្យបណ្តឹងត្រូវបានទទួលយក តុលាការប្រកាសបដិសេធសាលក្រម ប៉ុន្តែភាគីមិនអាចយកឱកាសនេះចេញមុខមកប្តឹងសាទុក្ខបានទេ ហើយគេក៏មិនអាចជំទាស់នឹងការអនុវត្តសេចក្តីសម្រេច [របស់តុលាការថ្នាក់ក្រោម] ដែលត្រូវបានបដិសេធ [ដោយតុលាការវិនិច្ឆ័យ]បានដែរ។"

ថ្វីបើអគ្គរដ្ឋអាជ្ញាបានជោគជ័យ ក្នុងការធ្វើឱ្យតុលាការវិនិច្ឆ័យធ្វើមោឃភាពលើសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមក្តី សាលដីការបស់តុលាការវិនិច្ឆ័យមានន័យត្រឹមតែកែតម្រូវសេចក្តីសម្រេចលើអង្គច្បាប់ប៉ុណ្ណោះ ប៉ុន្តែមិនអាចបញ្ឈប់ការអនុវត្តសេចក្តីសម្រេចដែលបានធ្វើរួចហើយឡើយ។ ការបដិសេធសាលក្រមនេះ មានតែទ្រឹស្តីប៉ុណ្ណោះ តុលាការវិនិច្ឆ័យមិនបង្វិលសំណុំរឿងទៅតុលាការក្រោមដើម្បីជម្រះឡើងវិញទេ[75]។

មាត្រា៦២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បើកឱ្យអគ្គរដ្ឋអាជ្ញាអមតុលាការវិនិច្ឆ័យប្តឹងសាទុក្ខដែរ បើមានបញ្ជាក់ច្បាស់ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលចោទថា សេចក្តីសម្រេចរបស់

---

[74] មាត្រា ៥៦៧ ក្រមនីតិវិធីព្រហ្មទណ្ឌ។

[75] Jean Pradel, Procédure Pénale (édition CUJAS, 6e édition 1992) p.639.

តុលាការណាមួយទាំងថ្នាក់ដំបូង ទាំងថ្នាក់ឧទ្ធរណ៍បានរំលោភលើច្បាប់។ ដីកាសម្រេច ឬសាលក្រមរបស់តុលាការទាំងនោះអាចធ្វើមោឃភាពបាន។ ក្នុងករណីនេះ ថ្វីត្បិតនេះជាបណ្ដឹងសាទុក្ខក្នុងផលប្រយោជន៍នៃច្បាប់ ភាគីអាចទទួលផលពីបណ្ដឹងនេះបាន។ បើសេចក្ដីសម្រេចរបស់តុលាការថ្នាក់ក្រោមជាសេចក្ដីសម្រេចឱ្យរួចការចោទប្រកាន់ ទោះបីតុលាការវិនិច្ឆ័យធ្វើមោឃភាពសេចក្ដីសម្រេចនោះក៏ដោយ ក៏សេចក្ដីសម្រេចរបស់តុលាការវិនិច្ឆ័យនេះស្ថិតនៅជាទ្រឹស្ដីមិនអាចមានផលឱ្យចាប់ជនជាប់ចោទមកឃុំឃាំងវិញទេ[76]។ បើសេចក្ដីសម្រេចរបស់តុលាការថ្នាក់ក្រោមជាសេចក្ដីសម្រេចផ្ដន្ទាទោស ការធ្វើមោឃភាពលើសេចក្ដីសម្រេចនោះដោយតុលា-ការវិនិច្ឆ័យត្រូវបានប្រយោជន៍ដល់ច្បាប់ និងភាគី មានន័យថាតុលាការវិនិច្ឆ័យអាចបង្វិលរឿងឱ្យទៅតុលាការថ្នាក់ក្រោម ហើយតុលាការដែលទទួលរឿងបង្វិលនេះ ត្រូវវិនិច្ឆ័យនៅក្នុងផលប្រយោជន៍របស់ទណ្ឌិត ទៅតាមមតិរបស់តុលាការវិនិច្ឆ័យ[77]។

## ង. សាលាវិនិច្ឆ័យនៃព្រះរាជាណាចក្រកម្ពុជា (១៩១១-១៩៣៧)

សាលាវិនិច្ឆ័យដែលត្រូវបានបង្កើតជាលើកដំបូងក្រោមការអនុម័តក្រមចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩១១ ស្ដីពី ក្រមស៊ើបសួរ(នីតិវិធី)ព្រហ្មទណ្ឌ និងការរៀបចំតុលាការ។ ឈ្មោះជាផ្លូវការនៃសាលានេះគឺ "សាលាវិនិច្ឆ័យាធិបតី"។ ដំណើរការនៃសាលាវិនិច្ឆ័យចាប់ផ្ដើមនៅឆ្នាំ ១៩១២ តាមរយៈព្រះរាជក្រមចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩១២[78]។ តួនាទីនៃសាលាវិនិច្ឆ័យនៅក្រោមក្រមខាងលើនេះអនុវត្តសម្រាប់តែរឿងព្រហ្មទណ្ឌ។ ទើបតែនៅឆ្នាំ១៩២២ ដែលតួនាទីរបស់សាលានេះត្រូវបានពង្រីកដល់រឿងរដ្ឋប្បវេណីផងដែរ។

**រចនាសម្ព័ន្ធៈ** ក្រមនេះមិនបានចែងបញ្ជាក់ថាត្រូវចែកចេញជាប៉ុន្មានផ្នែកទេ ប៉ុន្តែមានសមាសភាព ប្រធាន និងចៅក្រមបួនរូប និងក្រឡាបញ្ជីម្នាក់។ ប្រធានមានឋានន្តរសក្តិ១០ ប៉ាន ស្មើនឹងរដ្ឋមន្ត្រី រីឯចៅក្រមមានសក្តិ ៩ប៉ាន។ ក្នុងចំណោមចៅក្រមទាំងបួន ចៅក្រមពីររូបមានតំណែងអចិន្ត្រៃយ៍ប្រចាំសាលានេះ និងពីរនាក់ទៀតជាចៅក្រមបន្ថែម តែងតាំងនៅពេលណាមានសវនាការតាមរយៈការចាប់ឆ្នោតដោយប្រធានសាលាវិនិច្ឆ័យរើសចេញពីក្នុងចំណោមចាងហ្វាង និងចៅក្រមនៃសាលាឧទ្ធរណ៍ (មាត្រា១៨៥)។

នៅឆ្នាំ ១៩២២ ប្រធានសាលាវិនិច្ឆ័យទទួលបានបៀវត្សប្រាំមួយពាន់(៦,០០០)រៀល រីឯចៅក្រមធម្មតានៃសាលានេះបានពីបីពាន់ប្រាំមួយរយ (៣,៦០០) ទៅបួន(៤,០០០) រៀល

[76] ប្រភពដូចខាងលើ ទ. ៦៣៩។

[77] ប្រភពដូចខាងលើ ទ. ៦៣៩។

[78] Recueil des actes du Gouvernement Cambodgien, p. 94

ទៅតាមអតីតភាព (ប្រកាសថ្ងៃ ទី ៣ ខែតុលា ឆ្នាំ១៩៩២)។ ប្រធានបានប្រាក់រង្វាន់សម្រាប់មុខងារនៅក្នុងក្រុងចំនួន ៧២០រៀល និងប្រាក់ថ្លៃផ្ទះ ៣០០រៀល ។

ចៅក្រមសាលាវិនិច្ឆ័យត្រូវប្រឡងប្រជែងចូលកាន់តំណែង។ នៅឆ្នាំ១៩២២ ការប្រឡងមានវិញ្ញាសារជាឈុត។ វិញ្ញាសារទាំងអស់ត្រូវធ្វើជាភាសាបារាំង[79]។

ឈុតទីមួយមានបីវិញ្ញាសារទ្រឹស្តីគឺ ច្បាប់រដ្ឋប្បវេណី ច្បាប់នីតិវិធីរដ្ឋប្បវេណី ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ។ ក្នុងមួយវិញ្ញាសារត្រូវធ្វើ ៣ ម៉ោងដោយបិទសៀវភៅ។

ឈុតទីពីរ គឺការអនុវត្តសរសេរសាលក្រមរដ្ឋប្បវេណីមួយ និងសាលក្រមព្រហ្មទណ្ឌមួយ។ គេត្រូវធ្វើ ២ ម៉ោងក្នុងមួយមុខ ហើយអាចបើកសៀវភៅបាន។

ឈុតទីបីគឺជាវិញ្ញាសារផ្ទាល់មាត់ ដែលជាការសួរលើមុខវិជ្ជាដែលមាននៅក្នុងឈុតទីមួយ ក្នុងរយៈពេល ២០នាទី។

**សាលាវិនិច្ឆ័យជំនុំតែផ្នែកអង្គច្បាប់៖** យោងតាមព្រះរាជក្រម ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩២២ ដែលបន្ថែម ទៅលើក្រមឆ្នាំ១៩១១ សាលាវិនិច្ឆ័យកាត់ក្តីតែលើបញ្ហាច្បាប់ ហើយមិនកាត់ក្តីលើរឿងអង្គហេតុទេ[80]។ ដូចគ្នានឹងតុលាការវិនិច្ឆ័យបារាំងដែរ សាលានេះបដិសេធបណ្តឹងសាទុក្ខទាក់ទងនឹងភាពមិនប្រក្រតីនៃនីតិវិធី និងសេចក្តីសម្រេចផ្ទុយនឹងច្បាប់។ បន្ថែមលើនេះ សាលាវិនិច្ឆ័យជំនុំជម្រះលើបណ្តឹងសើរើផងដែរ។

សាលាវិនិច្ឆ័យខ្មែរយកលំនាំតាមគម្រូបារាំង។ សាលានេះមានភារកិច្ចបដិសេធសាលដីកា ឬសាលក្រម ដែលជម្រះជាចុងក្រោយដែលរំលោភច្បាប់ សម្រេចដោយតុលាការគ្មានសមត្ថកិច្ច ឬតុលាការដែលសម្រេចលើសពីដែនអំណាចរបស់ខ្លួន (មាត្រា១៧២)។

**នីតិវិធីនៃការប្តឹងសាទុក្ខ៖** បណ្តឹងសាទុក្ខនេះអាចធ្វើបានដោយទណ្ឌិត ភាគីរដ្ឋប្បវេណី ភាគីទទួលខុសត្រូវផ្នែករដ្ឋប្បវេណី។ រដ្ឋមន្ត្រីយុត្តិធម៌ក៏អាចប្តឹងបានដែរ តែធ្វើក្នុងផលប្រយោជន៍ច្បាប់ ដូចគ្នានឹងស្នងការព្រះមហាក្សត្របារាំងដែរ។ ក្រមនេះអនុវត្តចំពោះតែបណ្តឹងសាទុក្ខក្នុងរឿងព្រហ្មទណ្ឌប៉ុណ្ណោះ។

បណ្តឹងសាទុក្ខអាចធ្វើបានក្នុងកម្លុងពេល ៨ថ្ងៃ បន្ទាប់ពីសាលក្រមត្រូវបានប្រកាស។ រដ្ឋមន្ត្រីយុត្តិធម៌មានពេល ២ខែរាប់ចាប់ពីថ្ងៃប្រកាសសាលក្រម។ ការអនុវត្តសាលក្រមត្រូវផ្អាកសិនក្នុងរយៈពេល ៨ថ្ងៃនេះ។

សាមីជនត្រូវដាក់ពាក្យប្តឹងដោយផ្ទាល់នៅការិយាល័យក្រឡាបញ្ជី ហើយពាក្យបណ្តឹងនោះត្រូវធ្វើតាមទម្រង់ដែលប្រើដោយអាជ្ញាការីពិសេស (ទម្រង់ដែលអនុញ្ញាតឱ្យប្រើ)។ គេត្រូវ

[79] ទំព័រ ១០១ (Recueil des actes du Gouvernement Cambodgien 1920-1930, Tome 1)។ គេហៅថាច្បាប់រដ្ឋប្ប-វេណី ឬរដ្ឋប្បវេណីគតិ, មូលគតិរដ្ឋប្បវេណី (នីតិវិធីរដ្ឋប្បវេណី), ច្បាប់ព្រហ្មទណ្ឌ ឬអាជ្ញាគតិ, មូលគតិព្រហ្មទណ្ឌ (នីតិវិធីព្រហ្មទណ្ឌ)។

[80] មាត្រា ៦០ សូមមើលនៅក្នុងទំព័រ ៤៤ Recueil des actes du Gouvernement Cambodgien 1920-1930, Tome 1

ភ្ជាប់មកជាមួយនូវឯកសារនានាភ្ជាប់ជាមួយសាលក្រមដែលរងសាទុក្ខ (មាត្រា១៧៧ និង ១៨៨)។ លើសពីនេះទៀតគេត្រូវដាក់ជូននូវលិខិតដែលសរសេរពីមធ្យោបាយ ឬការវែកញែក គាំទ្រការសាទុក្ខ (មាត្រា១៨៩)។ ដើម បណ្តឹងត្រូវបង់ប្រាក់តម្កល់ ២០រៀល (មាត្រា១៧៤)។

ពាក្យប្តឹងសាទុក្ខនេះត្រូវបានបញ្ជូនទៅរដ្ឋមន្ត្រីយុត្តិធម៌ទៀត។ ច្បាប់មិនបញ្ជាក់ថា ការបញ្ជូននេះ គ្រាន់តែជាការជូនដំណឹងដល់រដ្ឋមន្ត្រី ឬស្នើសុំចំណាត់ការទេ ប៉ុន្តែរដ្ឋមន្ត្រីត្រូវបញ្ជូនបណ្តឹងនេះមកសាលាវិនិច្ឆ័យវិញ។

**ការទទួលបណ្តឹង៖** ការទទួល ឬមិនទទួលបណ្តឹងគឺជាសេចក្តីសម្រេចរបស់សាលា។ បើបណ្តឹងមួយត្រូវច្រានចោល មាត្រា២០៤ នៃក្រមនេះចែងថា "កាលណាពាក្យសុំប្តឹងសាទុក្ខមួយត្រូវបានច្រានចោលរួចហើយ ភាគីដែលបានធ្វើបណ្តឹងលែងអាចប្តឹងសាទុក្ខទល់នឹងសាលដីកា ឬសាលក្រមដដែលបានទៀតទេ ទោះបីក្រោមលេសអ្វីក៏ដោយ ឬដោយការវែកញែកអ្វីក៏ដោយ"។

**សមាសភាពនៃអង្គជំនុំជម្រះ៖** ការជំនុំជម្រះត្រូវធ្វើជាសាធារណៈ ដោយចៅក្រមបីនាក់ និងក្រឡាបញ្ជីម្នាក់។ ក្នុងបណ្តាចៅក្រមបីនាក់នេះ ម្នាក់ជាអធិបតី(មាត្រា៦៣ នៃក្រម ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ១៩២២)។

**អានុភាពនៃការបដិសេធសាលក្រម ឬសាលដីកាសាលាក្រោម៖** កាលណាសាលាវិនិច្ឆ័យធ្វើមោឃភាពលើសាលក្រម ឬសាលដីកាណាមួយហើយ លទ្ធផលគឺរឿងក្តីនោះត្រូវបញ្ជូនទៅចៅក្រម ឬតុលាការផ្សេងពីចៅក្រម ឬតុលាការដែលចេញសាលក្រមដែលត្រូវប្តឹងសាទុក្ខ។ ការប្តឹងសាទុក្ខជាលើកទីពីរ "មិនអាចធ្វើបានទេ"។ តែគេអាចប្តឹងសើរើបានចំពោះ សេចក្តីសម្រេចដែលមានអាជ្ញាអស់ជំនុំដោយសារការកើតឡើងនូវអង្គហេតុថ្មី ឬដោយសារមានវិធាននីតិវិធីថ្មីចេញមកជាធរមានមិនឱ្យគេអនុវត្តបាន (មាត្រា៦១ ព្រះរាជក្រម ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩២២)។

សាលាវិនិច្ឆ័យអាចច្រានចោលបណ្តឹងតែម្តង ឬបើទទួលបណ្តឹង សាលាអាចធ្វើមោឃភាពសាលដីកា ឬសាលក្រម។ អានុភាពនៃមោឃភាពសាលក្រមប្រែប្រួលទៅតាមប្រភេទសាលក្រម។

ចំពោះរឿងលហុ សាលាវិនិច្ឆ័យធ្វើមោឃភាព ហើយកាត់ក្តីរឿងនោះដោយខ្លួនឯង។ ចំពោះមោឃភាពលើរឿងអសមត្ថកិច្ច នោះសាលានឹងបង្វិលរឿងទៅសាលាជម្រះក្តីដែលមានសមត្ថកិច្ច។

នៅក្នុងការធ្វើមោឃភាពសាលក្រម ឬសាលដីកា ដោយសាររឿងក្តីមិនមែនព្រហ្មទណ្ឌ សាលាវិនិច្ឆ័យត្រូវបញ្ជូនរឿងទៅតុលាការរដ្ឋប្បវេណី។ ចំពោះមោឃភាពក្នុងបទល្មើសមជ្ឈិម

សាលាត្រូវបញ្ជូនរឿងទៅសាលាមជ្ឈិមដដែលដែលមានសមាសភាពផ្សេង ឬទៅសាលាមជ្ឈិមណាមួយទៀត (មាត្រា១៩៤)។

ចំពោះមោឃភាពក្នុងរឿងឧក្រិដ្ឋ សាលាត្រូវបញ្ជូនរឿងទៅសាលាឧក្រិដ្ឋផ្សេងទៀត ឬសាលាដែលមានសមត្ថកិច្ចកាត់ក្តីលើរឿងអសមត្ថកិច្ច(មាត្រា១៩៤) ទៅតាមការប្រជុំពិចារណាពិសេសរបស់ចៅក្រមនៃសាលាវិនិច្ឆ័យ។ បើសាលដីកានៃសាលាឧក្រិដ្ឋមួយត្រូវបានធ្វើមោឃភាព ដោយសារមូលហេតុសាលាឧក្រិដ្ឋ នោះអនុវត្តច្បាប់ខុសនឹងប្រភេទបទល្មើស សាលាថ្មីដែលទទួលរឿងពីសាលាវិនិច្ឆ័យត្រូវធ្វើសេចក្តីសម្រេចចេញសាលក្រមតែម្តង ដោយប្រកាសតែពីពិរុទ្ធភាពនៃតុលាការដំបូងប៉ុណ្ណោះ។ ប៉ុន្តែបើមោឃភាពដោយសារមូលហេតុផ្សេងនោះ សាលាថ្មីត្រូវចាប់ផ្តើមសវនាការសាជាថ្មី (មាត្រា១៩៩ និង ២០០)។

នៅក្នុងព្រះរាជក្រមចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩២២ ការបញ្ជូនរឿងក្រោយពីសាលាវិនិច្ឆ័យបានបដិសេធ សាលក្រមហើយនោះត្រូវធ្វើតាមបែបខាងក្រោម៖

១.បណ្តឹងត្រូវបង្វិលទៅតុលាការផ្សេងដែលមានកម្រិតស្មើគ្នានឹងតុលាការដែលចេញសាលក្រមដែលរងបណ្តឹងសាទុក្ខ ឬ

២. បើពុំនោះទេ ទៅតុលាការដដែលតែមានសមាសភាពចៅក្រមផ្សេង។

៣.ក្នុងករណីខាងលើនេះសាលដីការបស់សាលាវិនិច្ឆ័យត្រូវចែងពីឈ្មោះតុលាការដែលត្រូវបង្វិលទៅ និងកំណត់ពីសមាសភាពចៅក្រមដែលត្រូវកាត់រឿងបង្វិល។

**តួនាទីរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌៖** ដូចបានពោលខាងលើ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានតួនាទីជាឆ្មាំច្បាប់។ នៅពេលណាមានការអនុវត្តច្បាប់មិនត្រឹមត្រូវគាត់មានអំណាចចាត់ការកែតម្រូវវិញ។ ចំពោះសាលាវិនិច្ឆ័យដែលប្រកាសសាលដីការួច ហើយដែលរដ្ឋមន្ត្រីចង់តវ៉ានឹងសេចក្តីសម្រេចលើគតិច្បាប់នោះ គាត់អាចប្តឹងទៅសាលាវិនិច្ឆ័យដើម្បីកែប្រែសាលដីកានោះវិញ ដោយដាក់ពាក្យ និងភ្ជាប់ដោយសារណាវែកញែកជំហររបស់គាត់។ គាត់ត្រូវដាក់ពាក្យប្តឹងក្នុងរយៈពេល ៤ខែ ចាប់ពីការប្រកាសសាលដីកាព្រហ្មទណ្ឌទាំងអស់[81]។

នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩២២ មានព្រះរាជក្រមស្តីពី ការរៀបចំវិស័យយុត្តិធម៌មួយទៀតដែលបាន កែប្រែក្រមឆ្នាំ១៩១១។ នៅក្នុងនោះមានការបន្ថែមទាក់ទងនឹងសាលាវិនិច្ឆ័យ។

**អំពីយុត្តិសាស្ត្រនៃសាលាវិនិច្ឆ័យកម្ពុជា ៖** ស្ថិតិនៃបណ្តឹងសាទុក្ខមកសាលាវិនិច្ឆ័យក្នុងរវាងឆ្នាំ១៩២៤-១៩២៦មានចំនួនដូចខាងក្រោមនេះ ៖

[81] មាត្រា២០៦ កែប្រែដោយព្រះរាជក្រមនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩១៣។ Recueil des actes du Gouvernement Cambodgien 1920, p. 231.

| ឆ្នាំ | រដ្ឋប្បវេណី | លហុ | មជ្ឈិម | ឧក្រិដ្ឋ | សារុប |
|---|---|---|---|---|---|
| ១៩២៤ | ២៥៩ | ១១ | ២៧៧ | ១១១ | ៦៦៥ |
| ១៩២៥ | ៣២២ | ១៥ | ១៩៨ | ៤២ | ៥៧៨ |
| ១៩២៦ | ៤៣៦ | ២៣ | ១៤៥ | ៧៩ | ៦៨៣ |

យោងតាមស្ថិតិនេះ សាលាវិនិច្ឆ័យទទួលជាមធ្យម ២រឿងក្នុងមួយថ្ងៃ ដែលជាបន្ទុកមួយយ៉ាងធ្ងន់ សម្រាប់តុលាការមួយដែលមានចៅក្រមតិចជាង ១០នាក់។

មកទល់នឹងឆ្នាំ១៩២៦ សាលាវិនិច្ឆ័យកម្ពុជាបានចេញសាលដីកាដែលមានគុណភាពជាយុត្តិសាស្ត្ររដ្ឋប្បវេណីចំនួន ២២ និងយុត្តិសាស្ត្រព្រហ្មទណ្ឌចំនួន ១៤។

ខ្ញុំសូមលើកឧទាហរណ៍នៃយុត្តិសាស្ត្រព្រហ្មទណ្ឌមួយដែលទាក់ទងនឹងការទទួលផលចោរកម្ម។ សាលាវិនិច្ឆ័យចេញសាលដីកា នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩២៦ ដែលមានសេចក្តីខាងក្រោមនេះ ៖

> ការកាន់កាប់វត្ថុដែលត្រូវបានលួចមិនអាចចាត់ទុកជា ការទទួលផលនៃចោរកម្មដែលត្រូវផ្តន្ទាទោសនោះទេ កាលណាសុទ្ធចិត្តរបស់អ្នកកាន់របស់នោះកើតចេញពីលក្ខខ័ណ្ឌខ្លះនៃភាពស្តែងជាសាធារណៈ (conditions de publicité) ដែលនៅព័ទ្ធជុំវិញការដាក់ឱ្យស្ថិតនៅក្នុងការកាន់កាប់នៃជននោះ។
> ការតាក់តែងលិខិតដែលមានការបញ្ជាក់ពីអាជ្ញាធរឃុំ ដើម្បីបញ្ជាក់ពីអត្ថិភាពនៃកិច្ចសន្យាដែលជាមូលដ្ឋាននៃការដាក់ឱ្យកាន់កាប់នោះ គឺជាការគ្រប់គ្រាន់ដើម្បីផាត់ចោលនូវភាពលួចលាក់ ហើយដូច្នេះគឺជាសុទ្ធចិត្ត។

យុត្តិសាស្ត្រនេះពន្យល់បញ្ជាក់ពីអ្វីដែលគេត្រូវពិចារណា ដើម្បីកំណត់ឱ្យបានពីសភាវៈខាងសតិរបស់អ្នកទទួលផលចោរកម្ម ថាគាត់បានដឹងរបស់នោះបានមកពីការប្រព្រឹត្តបទល្មើសឬយ៉ាងណា។ សាលាវិនិច្ឆ័យបានយក "សុទ្ធចិត្ត" មកធ្វើជាធាតុមួយសម្រាប់សំគាល់ថាជនណាម្នាក់គ្មានចេតនានឹងចូលរួមក្នុងការបណ្តោះទ្រព្យធនរបស់អ្នកដទៃ។ បន្ទាប់មកទៀត សាលានេះពន្យល់ថា សុទ្ធចិត្តអាចកំណត់បាន ដោយសារកាលៈទេសៈនានានៅជុំវិញការកាន់កាប់របស់ ដូចជាការកាន់កាប់នោះត្រូវបានបង្ហាញជាសាធារណៈ។ នេះជាការបកស្រាយច្បាប់ដែលបង្កើតបានជាយុត្តិសាស្ត្រមួយ។ បទបញ្ញត្តិនៃការទទួលផលចោរកម្មនាសម័យនោះមានសេចក្តីដូចតទៅ ៖

> ជនណាមិនបានប្រព្រឹត្តជាមួយ ដោយផ្ទាល់ ឬដោយប្រយោល នូវបទល្មើសណាមួយដែលបណ្តាលឱ្យមានព្យសនកម្មដល់ធនធាន

អ្នកដទៃទេ ប៉ុន្តែបានទទួលដោយចេតនា ឬដោយដឹងច្បាស់នូវផលនៃអំពើល្មើសនោះទាំងអស់ ឬភាគខ្លះ ឬបានជួយសម្រួល ឬជួយខ្នះខ្នែងក្នុងការបណ្តោះផលនៃបទល្មើសនោះ ជននោះត្រូវមានទោសមជ្ឈិមថ្នាក់ទីបី ចៅក្រមអាចនឹងផ្តន្ទាជននោះឱ្យមានអនុទោស ត្រង់ស្ថានបន្ថយសិទ្ធិស៊ីវិក និងគំហាត់លំនៅទៀតក៏បាន។

សេចក្តីបំណងក្នុងបទល្មើសនេះក៏ត្រូវមានទោសដូចបានប្រព្រឹត្តបទល្មើសនោះដែរ។

មានឧទាហរណ៍មួយទៀតនៃយុត្តិសាស្ត្រព្រហ្មទណ្ឌស្តីពី ការការពារជាធម្មានុរូប ដែលមានសេចក្តីដូចតទៅនេះ ៖

មិនអាចធ្វើយុត្តិកម្មបានដោយអាងលើ ការចាំបាច់ត្រូវការពារខ្លួនឯងបានទេ បើអំពើហិង្សាដែលធ្វើនៅក្នុងលក្ខខ័ណ្ឌដែលនាំឱ្យមានផលវិបាកកើតឡើងវិសមាមាត្រ ធៀបទៅនឹងផលវិបាកកើតឡើងដោយសារការរងការវាយប្រហារ។

ការប្រើពូថៅដើម្បីឆ្លើយតបទៅនឹងការវាយដោយ មែកឈើស្តើងមួយមិនអាចចាត់ទុកថា ជាការពារបានទេ ដោយសារទម្ងន់នៃរបួសដែលកើតចេញពីការប្រើអាវុធនេះធៀបទៅនឹងការគ្មានទម្ងន់ដែលកើតដោយសារហិង្សាដែលបានទទួល។

គឺជាការរំលោភលើបញ្ញត្តិនៃមាត្រា១០៣ នៃក្រមព្រហ្មទណ្ឌដែលត្រូវអនុវត្តជាជាងបញ្ញត្តិនៃមាត្រា១០២។

ការវាយប្រហារដែលត្រូវបានរងមានអនុភាពដើម្បីបន្ថយ ប៉ុន្តែមិនត្រូវធ្វើឱ្យសាបសូន្យនូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៃអ្នកបង្កើតរបួសទេ។

(សាលដីកា លេខ ១២៥ ចេញថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩២៦)

ខាងក្រោមជាឧទហរណ៍នៃយុត្តិសាស្ត្រទាក់ទងនឹងការមិនអនុវត្តមួយផ្នែកនូវកិច្ចសន្យាផ្គត់ផ្គង់ដែលមានខមិនជាក់លាក់ ៖

១. ការមិនអនុវត្តមួយផ្នែក នៅឯកាលបរិច្ឆេទណាមួយនូវកាតព្វកិច្ច ដើម្បីប្រគល់ទំនិញដែលកើតចេញពីកិច្ចសន្យាផ្គត់ផ្គង់មានរយៈពេលមានកំណត់មិនមែនជាការយឺតយ៉ាវ ដែលនាំឱ្យការទទួលខុសត្រូវធ្លាក់ទៅលើបន្ទុកនៃអ្នកផ្គត់ផ្គង់ទេ កាលណារយៈពេលនៃ ការពន្យាដែលសន្មតសម្រាប់ការប្រគល់ជាសុក្រិត្យនូវទំនិញមិនបានបញ្ជាក់ឱ្យច្បាស់នៅក្នុងខណាមួយនៃ កិច្ចសន្យាហើយរយៈពេលនេះ មិនអាចទាញសេចក្តីសន្និដ្ឋានពីកិច្ចសន្យា

ទាំងមូល ឬពីកាលៈទេសៈបានទេ ហើយម៉្យាងវិញទៀត ការប្តឹងមកតុលាការនៃអ្នកទិញមិនអាចធ្វើបានមុនមានការដាក់កំហិតរបស់ខ្លួនបានឡើយ។

២. សាលាសម្រេចឱ្យលើសពីសំណូមពរ កាលណាអ្នកផ្គត់ផ្គង់ត្រូវពិន័យ ឱ្យបង់ប្រាក់មួយចំនួនដែលទឹកប្រាក់នោះត្រូវគណនាដោយយោងទៅលើថ្លៃមួយឯកតានៃទំនិញ ដែលគេអនុវត្តនៅក្នុងតំបន់នៅសម័យផ្តើមបណ្តឹង ថ្វីបើពាក្យបណ្តឹងហាក់ដូចជាទាមទារឱ្យសងប្រាក់តិចជាងក្តី ដែលតំណាងឱ្យការសងប្រាក់ដែលបង់មុនដែលអ្នកទិញព្រមឱ្យអ្នកផ្គត់ផ្គង់។

(សាលដីកា លេខ ២៨ ចេញថ្ងៃទី២ ខែមេសា ឆ្នាំ១៩២៥)

## ច. សាលាវិនិច្ឆ័យនៃព្រះរាជាណាចក្រកម្ពុជា (១៩៣៧-១៩៦២)

សមាសភាពនៃសាលាវិនិច្ឆ័យនៅឆ្នាំ១៩៦២ គ្មានការផ្លាស់ប្តូរទេគឺ មានចាងហ្វាងមួយ និងទីប្រឹក្សា ៤រូប។

នៅឆ្នាំ១៩៣៧ ក្រមពិភាក្សាព្រហ្មទណ្ឌ (ក្រមនីតិវិធីព្រហ្មទណ្ឌ)ត្រូវប្រកាសឱ្យប្រើ។ ម្តងនេះទៀត ក្រមនេះបរិយាយតួនាទីរបស់សាលាវិនិច្ឆ័យទាក់ទងនឹងរឿងព្រហ្មទណ្ឌដែរប៉ុណ្ណោះ។ ប៉ុន្តែ ការបរិយាយនេះ មានការលំអិតច្រើនជាងក្រមឆ្នាំ១៩១១។

ក្រមពិភាក្សារដ្ឋប្បវេណី ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៣៨ ក៏មានគ្របដណ្តប់លើ រឿងបណ្តឹងសាទុក្ខដែរ ដែលនៅក្នុងនោះមានចែងជាអាទិ៍ អំពីតួនាទីរបស់សាលាវិនិច្ឆ័យ និងគោលការណ៍នៃបណ្តឹងសាទុក្ខ។

ច្បាប់ចុងក្រោយដែលគ្រប់គ្រងតួនាទី និងការប្រព្រឹត្តទៅនៃសាលាវិនិច្ឆ័យគឺ ក្រមពិភាក្សាព្រហ្មទណ្ឌ ដែលអនុម័តនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៦២។

**ផ្លូវដែលបើកឱ្យប្តឹងសាទុក្ខ៖** ដូចគ្នានឹងក្រមមុនៗដែរ ក្រមពិក្សាព្រហ្មទណ្ឌឆ្នាំ១៩៣៧ (មាត្រា៦៣៨) និងក្រមពិភាក្សារដ្ឋប្បវេណី(មាត្រា ៤២៥) ចែងថាសាលាវិនិច្ឆ័យជំនុំជម្រះតែពីបញ្ហាច្បាប់ និងមិនប៉ះពាល់ដល់ រឿងអង្គហេតុទេ ៖

<u>ក្រមពិភាក្សាព្រហ្មទណ្ឌ</u> ៖ សាលាវិនិច្ឆ័យាធិបតីត្រូវពិនិត្យពីផ្លូវច្បាប់ មិនត្រូវពិនិត្យដល់រូបសេចក្តីទេ។ សានដីកាសាលាវិនិច្ឆ័យត្រូវទុកជាស្រេចថានឹងប្តឹងតវ៉ា ពីសានដីកានេះតទៅទៀតពុំបានឡើយ ក៏ប៉ុន្តែបើនឹងប្តឹងសុំឱ្យរើជំនុំជម្រះជាថ្មីឡើងវិញបាន ឯនឹងប្តឹងសុំឱ្យរើជំនុំជម្រះដូច្នេះបាន លុះត្រាតែប្រកបនឹងលក្ខណៈដែលមានបញ្ញត្តិក្នុងច្បាប់។ (sic)

> <u>ក្រមពិភាក្សារដ្ឋប្បវេណី</u> ៖ តាមធម្មតា សាលាវិនិច្ឆ័យមិនត្រូវមុខក្រសួងជំនុំជម្រះ ដល់អង្គសេចក្ដីឡើយ។ សាលានេះត្រូវទុកអង្គសេចក្ដីជាបានការ ហើយសាលានេះ គ្រាន់តែពិនិត្យជាបានសម្រេចច្បាប់ ដម្រូវទៅលើអង្គសេចក្ដីនោះបានត្រឹមត្រូវនឹង បានម៉ត់ចត់មែនឬទេ។(sic)

នៅក្នុងក្រមពិភាក្សាព្រហ្មទណ្ឌ ១៩៣៧ សាលក្រមរបៀបមិនមែនជាកម្មវត្ថុនៃការប្ដឹងសាទុក្ខទេ លើកលែងតែសាលក្រមដែលសម្រេចពីសមត្ថកិច្ចនៃសាលាជំនុំជម្រះថ្នាក់ក្រោម (មាត្រា ៤៣៦)។ មាត្រា ៤៣៥ នៃក្រមនេះចែងថា ៖

> សាលាវិនិច្ឆ័យនឹងទទួលបណ្ដឹងសាទុក្ខពីសានក្រមរបៀបសាលាជាន់ទាប ឬ សានក្រមរបៀបសាលាជាន់ខ្ពស់ពុំបានឡើយ កាលណាបើពុំទាន់មានសានក្រម សម្រេចពីសាលាទាំងនោះជាស្រេចដាច់ខាតនៅឡើយទេ។(sic)

ហេតុដែលនាំឱ្យភាគីណាមួយអាចប្ដឹងសាទុក្ខបាន លុះត្រាតែសាលក្រមឬសាលដីការបស់តុលាការ រំលោភលើនីតិវិធីច្បាប់និងបទបញ្ញត្តិច្បាប់។ ករណីនីមួយៗដែលជាមូលហេតុនៃបណ្ដឹងសាទុក្ខមានដូចខាងក្រោមនេះ៖

***១. ការបំពានលើនីតិវិធី៖*** ការបំពានលើនីតិវិធី ដែលនៅក្នុងនោះទម្រង់សម្រាប់ដំណើរការនៃនីតិវិធីត្រូវបានបំពាន ហើយច្បាប់ក៏បានបញ្ញត្តិថា បើទម្រង់នោះមិនត្រូវបានធ្វើតាមទេ នោះនឹងទុកជាអាសាឥតការ។

ឧទាហរណ៍នៃទម្រង់ដែលត្រូវតែគោរព ហើយបើមិនគោរពនឹងនាំឱ្យកិច្ចមួយនៃនីតិវិធីត្រូវចាត់ទុកអាសាឥតការគឺមាននៅក្នុងមាត្រា ២៨៩ នៃក្រមពិភាក្សាព្រហ្មទណ្ឌ ១៩៣៧ ជាដើម ៖

> កំណត់ថ្ងៃដែលណាត់ក្នុងដីកាកោះនោះ បើយ៉ាងហោចណាស់ត្រឹម ៣ ថ្ងៃ... ហើយ ក្នុងកំណត់ ៣ ថ្ងៃនោះត្រូវគិតថែម ១ ថ្ងៃទៀតក្នុងចម្ងាយ ១០ គីឡូម៉ែត្រពីនាទី សាលា ...បើពុំប្រនិបត្តិតាមសេចក្ដីបញ្ញត្តិអំពីកំណត់នេះទេ ត្រូវទុកដីកាកោះនោះ ជាអសាឥតការឱ្យសាបសូន្យបាន... (sic)

នៅក្នុងការបំពានលើនីតិវិធីនេះ ច្បាប់មិនបានចែងថាតើនីតិវិធីនោះត្រូវចាប់ផ្ដើមនីតិវិធីឡើងវិញពីចំណុចដែលមានការរំលោភដូចច្បាប់បារាំង ឬត្រូវដំណើរការនីតិវិធីសារឡើងវិញទាំងអស់។

២. ***ការជំនុំជម្រះដោយតុលាការដែលគ្មានសមត្ថកិច្ច៖*** ឧទាហរណ៍ បើរឿងមួយដែលត្រូវជំនុំជម្រះដោយតុលាការរដ្ឋបាល តែផ្ទុយទៅវិញបែរជាជម្រះនៅតុលាការស៊ីវិល នោះសាលក្រមនៃតុលាការស៊ីវិលនោះត្រូវតែបានបដិសេធដោយសាលាវិនិច្ឆ័យ។

៣. ***ការមិនទទួលសំណូមពររបស់ភាគី*** ៖ នៅក្នុងរឿងព្រហ្មទណ្ឌ នៅពេលដែលភាគី ឬតំណាងអយ្យការ ធ្វើសំណូមពរដែលច្បាប់អនុញ្ញាត ហើយចៅក្រមដែលសម្រេចរឿងក្តីបែរជាមិនព្រមធ្វើសេចក្តីសម្រេចលើ សំណូមពរនោះ នេះក៏ជាមូលហេតុនៃការបើកផ្លូវឱ្យមានការប្តឹងសាទុក្ខបានដែរ។ ក្នុងនេះដែរ គេមិនដឹងថាតើ តុលាការដែលទទួលរឿងបង្វិលត្រូវចាប់ផ្តើមទទួល និងសម្រេចសំណូមពរនោះឡើងវិញ រួចសើរើនីតិវិធីរបស់ខ្លួនឡើងវិញ។

៤. ***ចៅក្រមមិនគ្រប់ចំនួន ឬមានចំនួនមិនស្ថិតស្ថេរតាមច្បាប់កំណត់៖*** ករណីទីមួយគឺការជំនុំជម្រះ ដោយចៅក្រមមិនគ្រប់ចំនួនតាមច្បាប់កំណត់។ ករណីមួយទៀតគឺ តែងកើតមានចំពោះតុលាការដែលជំនុំជម្រះជាក្រុម ដូចជានៅក្នុងរឿងឧក្រិដ្ឋជាដើម ដែលច្បាប់តម្រូវឱ្យមានចៅក្រម ៣ នាក់ និង ក្រុមប្រឹក្សាប្រជារាស្ត្រ ២ នាក់ (មាត្រា ៥១១)។ បើនៅក្នុងអំឡុងពេលនៃការជំនុំជម្រះ នៅថ្ងៃខ្លះមានចៅក្រម ៣ នាក់ ថ្ងៃខ្លះទៀត ២ នាក់ នោះការនេះក៏ជាមូលហេតុនៃការបើកផ្លូវបណ្តឹងសាទុក្ខដែរ (មាត្រា ៦៤៧ ក្រមពិភាក្សាព្រហ្មទណ្ឌ ១៩៣៧)។

៥. ***ការជំនុំជម្រះអសាធារណ:៖*** មានការលើកលែងខ្លះដែរចំពោះករណីការជំនុំជម្រះអសាធារណៈ ដែលយើងមិនបាច់លើកមកនិយាយនៅក្នុងទីនេះ។

៦. ***សាលក្រមផ្ទុយគ្នា៖*** នេះជាករណីដែលនៅក្នុងរឿងតែមួយ(ភាគីដូចគ្នា អង្គហេតុដូចគ្នា) ដែលសាលក្រមពីរចេញដោយសាលាពីរ តែលទ្ធផលចេញមកពីរខុសគ្នា។

៧. ***ការរំលោភលើច្បាប់*** ៖ ករណីបែបនេះធ្លាក់ក្នុងសមត្ថកិច្ចចំបងនៃសាលាវិនិច្ឆ័យ។

**លក្ខខណ្ឌខ្លះៗសម្រាប់អ្នកប្តឹងសាទុក្ខ** ៖ ផ្ទុយពីករណីប្រទេសបារាំង ជនជាប់ចោទដែលមានទោសគុកពី ៦ ខែឡើងទៅ បើចង់ប្តឹងសាទុក្ខត្រូវចូលគុកជាមុនសិន (មាត្រា ៦៦០ ក្រមពិភាក្សាព្រហ្មទណ្ឌ)។ បើជនជាប់ចោទចង់នៅក្រៅឃុំ គេអាចធ្វើពាក្យទៅសាលាក្រុមចោទដើម្បីសុំឱ្យសម្រេចពាក្យសុំនេះ។

សម្រាប់ប្រជាពលរដ្ឋទូទៅ ពាក្យប្តឹងសាទុក្ខមិនចាំបាច់ធ្វើតាមទម្រង់ពិសេសទេ ដោយនៅក្នុងពាក្យបណ្តឹងនោះគេត្រូវថែងពីរឿងហេតុដែលកើតឡើង និងបើអាចធ្វើបាន គេត្រូវរំឭកវែកញែកក្តីខាងផ្លូវច្បាប់ផង (មាត្រា ៦៦១ ក.ព.៣)។ ប៉ុន្តែបើបណ្តឹងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌វិញ ត្រូវតែមានការថែងនិងការពន្យល់ ពីខច្បាប់ដែលត្រូវបានរំលោភ។

ពាក្យសុំប្តឹងសាទុក្ខត្រូវដាក់នៅក្រឡាបញ្ជីនៃតុលាការដែលសាលក្រមរបស់ខ្លួនត្រូវបានរងសាទុក្ខ ហើយសាលានេះជាអ្នកបញ្ជូនទៅឱ្យចាងហ្វាងសាលាវិនិច្ឆ័យ។

**ការពិនិត្យបណ្ដឹងសាទុក្ខ ៖** ចាងហ្វាងចាត់ឱ្យចៅក្រមម្នាក់ពិនិត្យពាក្យសុំប្ដឹងសាទុក្ខ។ ការពិនិត្យនេះ ខុសពីរបៀបចម្រាញ់បណ្ដឹងរបស់បារាំង ដែលអ្នកប្ដឹងត្រូវរៀបចំរូបមន្តបណ្ដឹងច្បាស់លាស់ដើម្បីឱ្យតុលាការវិនិច្ឆ័យទទួលយកបណ្ដឹងទៅវិនិច្ឆ័យ។ នៅប្រទេសខ្មែរ ក្នុងរឿងព្រហ្មទណ្ឌ ថ្វីបើបណ្ដឹងសាទុក្ខមួយជាបណ្ដឹងទូទៅ(ឬដែលហៅថា"ប្ដឹងសាទុក្ខជាឱវាល់") ដែលគ្មានដៅចំពោះចំណុចណានៃសាលក្រមដែលរងសាទុក្ខក្ដី ក៏ចៅក្រមត្រូវតែពិនិត្យមើលគ្រប់ខទោះបីដើមបណ្ដឹងសាទុក្ខយល់ថា សាលាខាងក្រោមបានកាត់សេចក្ដីត្រឹមត្រូវហើយក៏ដោយ (មាត្រា ៦៦៧ ក.ព.ព)។ បើដើមបណ្ដឹងច្បិចយកតែចំណុចណាមួយមកប្ដឹងនោះ សាលាវិនិច្ឆ័យនឹងជម្រះតែចំណុចទាំងនោះមកវិនិច្ឆ័យ។ ការសម្រេចរបស់សាលាវិនិច្ឆ័យ ទោះបដិសេធមិនយកបណ្ដឹងទៅវិនិច្ឆ័យក្ដី ឬបដិសេធសាលក្រមដែលប្ដឹងមកក្ដី ត្រូវតែមានសំអាងហេតុ (មាត្រា ៦៦៩ ក.ព.ព)។

**អានុភាពនៃសាលដីការបស់សាលាវិនិច្ឆ័យ៖** ដូចគ្នានឹងនីតិវិធីមុនឆ្នាំ១៩៣៧ដែរ សាលាវិនិច្ឆ័យ នៅពេលរំលាយ (បដិសេធ)សាលក្រមដែលកាត់ផ្ទុយនឹងច្បាប់ ត្រូវបង្វិលរឿងទៅសាលាថ្នាក់ក្រោមផ្សេងដែលសមមូល ឬសាលាដដែលតែសមាសភាពចៅក្រមផ្សេង ដោយចុះនៅក្នុងសាលដីការបស់ខ្លួននូវសេចក្ដីអធិប្បាយអំពីផ្លូវច្បាប់ ដើម្បីជាមគ្គុទ្ទេសក៍សម្រាប់ការកាត់សេចក្ដីឡើងវិញ។ សេចក្ដីអធិប្បាយនោះត្រូវពិភាក្សា និងពន្យល់ឱ្យបានច្បាស់លាស់អំពីបញ្ញត្តិច្បាប់ដែលអនុវត្តខុសទៅនឹងអង្គហេតុ។

នៅក្នុងរឿងព្រហ្មទណ្ឌ បណ្ដឹងសាទុក្ខធ្វើបានតែម្ដងគត់ចំពោះសាលដីកា ឬសាលក្រមនៃតុលាការដើម (មាត្រា ៦៦៩ ក.ព.ព)។

ប៉ុន្តែ ក្រមពិភាក្សារដ្ឋប្បវេណី ១៩៣៨ អនុញ្ញាតឱ្យភាគីប្ដឹងសាទុក្ខបានម្ដងទៀត នៅពេលដែលតុលាការដែលទទួលរឿងបង្វិលមិនព្រមគោរពតាមការពន្យល់របស់សាលដីការបស់សាលាវិនិច្ឆ័យ ហើយតម្កល់សាលក្រមលើកទីមួយ។ នៅពេលសាទុក្ខលើកទីពីរនេះ សាលាវិនិច្ឆ័យប្រមូលចៅក្រមពីក្រុម[សភា] "រដ្ឋប្បវេណីគតិ"[សភារដ្ឋប្បវេណី] និង "ក្រុមអាជ្ញាគតិ" [សភាព្រហ្មទណ្ឌ]ដើម្បីជំនុំជម្រះរួមគ្នា (មាត្រា ៤២៩ ក.ព.រ)។ ប៉ុន្តែសាលដីកាលើកទីពីរនេះជាសាលដីកាស្ថាពរមិនអាចសើរើបានទេ។ នៅក្នុងច្បាប់នេះ គេពុំបានចែងថា ការជំនុំជម្រះលើកទីពីរនៃសាលាវិនិច្ឆ័យត្រូវជម្រះទាំងលើអង្គហេតុនិងអង្គច្បាប់ទេ។ ក៏ប៉ុន្តែគេអាចសន្និដ្ឋានបានថា នៅលើកទីពីរនេះ ការជំនុំជម្រះមិនធ្វើលើអង្គហេតុទេ ព្រោះថាមាត្រា ៤២៥ នៃក្រមនេះបញ្ជាក់ថា "...សាលាវិនិច្ឆ័យមិនត្រូវមុខក្រសួងជំនុំជម្រះដល់អង្គសេចក្ដីឡើយ។ សាលានេះត្រូវទុកអង្គសេចក្ដីជាបានការ..." និងមាត្រា ៤៣១ ហាមឃាត់សាលាវិនិច្ឆ័យមិនឱ្យកាត់សេចក្ដីដោយខ្លួនឯងដោយមិនបាច់បង្វិល ដោយសំអាងថា សំណុំរឿងមានអង្គហេតុមូលសព្វគ្រប់អស់ហើយ។

ក្រមថ្មីទាំងពីរអនុញ្ញាតឱ្យសាលាវិនិច្ឆ័យចេញសាលដីកា ដោយមិនបាច់បង្វិលរឿងទៅសាលាថ្នាក់ក្រោមជម្រះសាជាថ្មីបាន ក៏ប៉ុន្តែមិនមែនគ្រប់រឿងទាំងអស់ទេ។ មានរឿងខ្លះៗ ដែលសាលាវិនិច្ឆ័យមិនបាច់បង្វិលៈ

*១. ក្នុងរឿងរដ្ឋប្បវេណី* ៖ បើសាលាវិនិច្ឆ័យសម្រេច ដោយមិនបានកែប្រែខ្លឹមសារនៃសាលក្រមដែលត្រូវបានប្ដឹងសាទុក្ខ។ ឧទាហរណ៍មួយគឺ សាលាឧទ្ធរណ៍ជំនុំជម្រះខុស ដោយសារពាក្យប្ដឹងឧទ្ធរណ៍ហួសកំណត់ ឬធ្វើពុំបានត្រឹមត្រូវ។ ក្នុងករណីនេះ សាលាវិនិច្ឆ័យសម្រេចថាសាលាឧទ្ធរណ៍ជំនុំជម្រះខុស ហើយអាចតម្កល់សាលក្រមរបស់សាលាដំបូង (មាត្រា ៤៣០ ក.ព.រ)។

*២. ក្នុងរឿងព្រហ្មទណ្ឌ៖* ការសម្រេចដោយមិនបាច់បង្វិលរឿងអាចធ្វើបានចំពោះការសម្រេចខុសអំពីទោសបន្ថែម ដោយកែតម្រូវអនុទោសនោះវិញ។ រឿងមួយទៀត បើតុលាការថ្នាក់ក្រោមផ្ដន្ទាទោសជនណាមួយក្នុងកម្រិតមួយ ប៉ុន្តែប្រើមាត្រាច្បាប់មិនត្រូវនឹងអង្គហេតុ នោះសាលាវិនិច្ឆ័យគ្រាន់តែអាចកែឈ្មោះបទល្មើសនោះ ដោយតម្កល់ទុកបរិមាណទោស និងសំណងដែលតុលាការថ្នាក់ក្រោមបានសម្រេច (មាត្រា ៦៧៣ ក.ព.ព)។ ផ្ទុយទៅវិញ ការបង្វិលត្រូវតែធ្វើជាដាច់ខាត បើសាលាវិនិច្ឆ័យរកឃើញថា ទោសដែលត្រូវដាក់នោះ មានទម្ងន់ធ្ងន់ជាង ឬស្រាលជាងទោសដែលតុលាការថ្នាក់ក្រោមបានដាក់ (មាត្រា ៦៧៤ ក.ព.ព)។

## ឆ. សាលាវិនិច្ឆ័យនៃប្រទេសកម្ពុជា(១៩៦២-១៩៧៥)

**ការប្រែតួនាទីនៃសាលាវិនិច្ឆ័យពីសាលាជម្រះអង្គច្បាប់មកអង្គហេតុផងដែរ៖** តួនាទីរបស់សាលានេះ បានផ្លាស់ប្តូរយ៉ាងគំហុកនៅក្នុងឆ្នាំ ១៩៦២។ ក្រមពិភាក្សាព្រហ្មទណ្ឌឆ្នាំ ១៩៦២ បានបន្ថែមអំណាចដល់សាលាវិនិច្ឆ័យ ដើម្បីជម្រះពីអង្គហេតុផងដែរ។ មាត្រា ៥០៣ ចែងថា ៖

> សាលាវិនិច្ឆ័យអារកាត់ក្នុងសាច់ច្បាប់ ហើយមិនអារកាត់ក្នុងសាច់បទប្រព្រឹត្តទេ ក៏ប៉ុន្តែជាសាលាជម្រះក្នុងសាច់បទប្រព្រឹត្តផងដែរ ក្នុងករណីដែលមានបណ្ដឹងសាទុក្ខជាលើកទី២ ទៅសាលាវិនិច្ឆ័យ ក្នុងលក្ខខណ្ឌទាំងឡាយ ដូចមានចែង បញ្ជាក់ខាងក្រោម។
> សេចក្ដីសម្រេចរបស់សាលាវិនិច្ឆ័យ ជាសេចក្ដីសម្រេចខ្ពស់ផុតឧទ្ធរណ៍ សេចក្ដីម៉្យាងទៀតថា ចំពោះសេចក្ដីសម្រេចនេះ គឺគ្មានផ្លូវធ្វើបណ្ដឹងអ្វីមួយបានតទៅទៀតឡើយ វៀរលែងតែបណ្ដឹងសាទុក្ខសុំរើពិនិត្យ ក្នុងករណីយ៍ទាំងឡាយដែលច្បាប់បានចែងកំណត់ទុកស្រាប់ហើយ។

## ជ. តុលាការកំពូលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

តុលាការនេះមានឈ្មោះថា "តុលាការប្រជាជនកំពូល" ហើយត្រូវបានអនុម័តបង្កើតដោយរដ្ឋសភានៃ សាធារណរដ្ឋប្រជាមានិតកម្ពុជានៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៨៥។

បេសកកម្មរបស់តុលាការប្រជាជនកំពូលមិនដូចតុលាការវិនិច្ឆ័យបារាំង ដែលសំដៅដល់ការធ្វើឱ្យមានភាពឯកសណ្ឋាន ក្នុងការអនុវត្តច្បាប់នៅក្នុងរង្វង់ស្ថាប័នតុលាការនោះទេ។ បើយោងតាមមាត្រា ១ នៃក្រឹត្យ-ច្បាប់លេខ ៣៤ ក្រ.ច ថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៨៧ ស្តីពីការចាត់តាំង និងសកម្មភាពរបស់តុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល បេសកកម្មនៃតុលាការកំពូលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាមានលក្ខណៈនយោបាយ និងសីលធម៌សង្គមច្រើនជាងការពង្រឹងនីតិរដ្ឋ[82] និងផ្អែកលើគោលការណ៍សង្គមនិយម។ នៅក្នុងសេចក្តីថ្លែងនៃបេសកកម្មនេះ តុលាការកំពូលមានបេសកកម្មដំបូងត្រូវពង្រឹងនីត្យានុកូល ហើយពាក្យនេះត្រូវបានប្រើនៅក្នុងអត្ថបទច្បាប់ជាច្រើនចាប់ពីឆ្នាំ ១៩៨១ ដល់ ១៩៨៧ ដែលពេលខ្លះយោងដល់ពាក្យនីត្យានុកូលប្រជាធិបតេយ្យ និងពេលខ្លះទៀតជាពាក្យនីត្យានុកូលទទេ។ អ្នកតាក់តែងច្បាប់ប្រហែលជាចង់និយាយដល់នីត្យានុកូលភាពសង្គមនិយម ព្រោះនៅក្នុងអត្ថបទដទៃទៀតមានការយោងដល់ពាក្យនេះ ឧទាហរណ៍ ដូចជាច្បាប់ស្តីពី "ការពិនិត្យនិងដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ" ដែលអនុម័ត នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៨២ ជាដើម[83]។ នីត្យានុកូលភាពសង្គមនិយមគឺជា "គោលការណ៍គតិយុត្ត" ដែលធានាថាច្បាប់ និងប្រព័ន្ធគតិយុត្តិបម្រើផលប្រយោជន៍របស់រដ្ឋ និងរបប ជាជាងការពារសិទ្ធិបុគ្គលនៅចំពោះមុខរដ្ឋ។ អំណាចត្រួតពិនិត្យធំបំផុតលើប្រព័ន្ធគតិយុត្តិ ស្ថិតក្នុងដៃគណៈដឹកនាំបក្សដែលមិនមែនជ្រើសតាំងដោយវិធីប្រជាធិបតេយ្យ ហើយដែលមិនទទួលខុសត្រូវចំពោះសាធារណជនទូទៅ"[84]។

តុលាការកំពូលមានសមាសភាពប្រធាន អនុប្រធាន និងចៅក្រម។ ប្រធានត្រូវបានបោះឆ្នោតជ្រើសតាំងដោយរដ្ឋសភាសម្រាប់អាណត្តិ ៥ឆ្នាំ។

---

[82] មាត្រា១ ចែងថា៖ "សកម្មភាពរបស់តុលាការប្រជាជនកំពូលមានទិសដៅពង្រឹងនីត្យានុកូលភាព ពង្រឹង សណ្តាប់ធ្នាប់សង្គម ការពារផលប្រយោជន៍របស់សង្គម ការពារសិទ្ធិសេរីភាពនិងផលប្រយោជន៍ស្របច្បាប់របស់ពលរដ្ឋ និងធានាឲ្យមានការអនុវត្តន៍យ៉ាងត្រឹមត្រូវ និងឯកភាពទូទាំងប្រទេសក្នុងក្របខ័ណ្ឌតុលាការ ព្រមទាំងទិសដៅអប់រំពលរដ្ឋទូទៅឲ្យមានស្មារតីស្មោះត្រង់ចំពោះមាតុភូមិ និងរបបប្រជាធិបតេយ្យរបស់ប្រជាជន ឲ្យមានឆន្ទៈគោរពយ៉ាងម៉ឺងម៉ាត់និងត្រឹមត្រូវនូវរដ្ឋធម្មនុញ្ញនិងច្បាប់របស់រដ្ឋ ឲ្យគោរពវិន័យពលកម្ម ទ្រព្យសម្បត្តិសាធារណៈ សិទ្ធិសេរីភាពអ្នកដទៃ និងបទដ្ឋាននៃការរស់នៅក្នុងសង្គម"។

[83] មាត្រា ១ នៃច្បាប់នេះថា "ត្រូវបង្កើតឲ្យមានការត្រួតពិនិត្យរបស់ប្រជាជនចំពោះ អង្គការរដ្ឋ...និងចំពោះបុគ្គលនៃអង្គការទាំងនោះសំដៅ-កសាងទំនាក់ទំនងដ៏ត្រឹមត្រូវរវាងបក្ស រដ្ឋអំណាច និងប្រជាជន-ពង្រឹងនីត្យានុកូលភាពសង្គមនិយម-ការពារផលប្រយោជន៍រដ្ឋនិងសមូហភាពនិងផលប្រយោជន៍ស្របច្បាប់របស់ពលរដ្ឋ-..."។

[84] http://www.fas.org/irp/world/russia/su_glos.html#socialist

តុលាការប្រជាជនកំពូលមិនមែនជាតុលាការវិនិច្ឆ័យអង្គច្បាប់ទេ ប៉ុន្តែជាតុលាការដែលវិនិច្ឆ័យរឿងក្តីទាំងមូល។ មាត្រា ៣ នៃច្បាប់នោះចែងថា តុលាការនេះ "ជំនុំជម្រះជាលើកទីមួយ និងជាចុងក្រោយបង្អស់" នូវរឿងទាំងឡាយដែលធ្ងន់ធ្ងរស្មុគស្មាញ។ ក្រៅពីជំនុំជម្រះរឿងក្តីដោយខ្លួនឯង តុលាការកំពូលពិនិត្យតាមដានការងាររបស់តុលាការក្រុង-ខេត្ត និងតុលាការយោធា និងចេញសេចក្តីណែនាំអំពីការអនុវត្តច្បាប់ដល់តុលាការទាំងនេះ។ តុលាការនេះពិនិត្យមើលសាលក្រមប្រហារជីវិត ដើម្បីផ្តល់យោបល់ឱ្យក្រុមប្រឹក្សារដ្ឋសម្រេច។

តុលាការនេះត្រូវរាយការណ៍ពីការងាររបស់ខ្លួនដល់រដ្ឋសភា ហើយប្រធានតុលាការត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋសភា (មាត្រា ៧ និង ៤)។ ដូច្នេះ តុលាការកំពូលមិនមែនជាតុលាការឯករាជ្យពីអំណាចផ្សេងទៀតទេ។ ថ្វីបើសាលាវិនិច្ឆ័យបារាំងនៅសម័យបដិវត្តត្រូវរាយការណ៍ជារៀងរាល់ឆ្នាំទៅសភានៅលើបញ្ហាការអនុវត្តច្បាប់ក្តី តុលាការកំពូលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាប្រហែលជាមិនមានភារកិច្ចដូចសាលាវិនិច្ឆ័យបារាំងទេ។

**រចនាសម្ព័ន្ធ៖** តុលាការកំពូលចែកចេញជា ក្រុមប្រឹក្សាចៅក្រមដែលមាន ប្រធានតុលាការកំពូល អនុប្រធាន និងចៅក្រមមួយចំនួនដែលត្រូវកំណត់ដោយក្រុមប្រឹក្សារដ្ឋ ព្រមទាំងសភាតុលាការ។

ក្រុមប្រឹក្សាចៅក្រមមាននាទីហាក់ដូចជាក្រុមប្រឹក្សាភិបាលរបស់តុលាការ ដែលទទួលភារៈគ្រប់គ្រង ផ្នែករដ្ឋបាលផង និងផ្នែកយុត្តាធិការផង។ សភាតុលាការចែកចេញជាបីផ្នែក ៖ សភារដ្ឋប្បវេណី, សភាព្រហ្មទណ្ឌ, សភាផ្នែកយោធា។

**នីតិវិធីនៃការចាត់ការរឿងក្តី៖** គេចាត់ទុករឿងក្តីជាពីរប្រភេទ។ ប្រភេទទីមួយជារឿងមិនធ្ងន់ធ្ងរ និងរឿងទីពីរជារឿងធ្ងន់ធ្ងរ។ អ្នកដែលមានអំណាចអនុវត្តសិទ្ធិធ្វើបណ្តឹងសាទុក្ខមានតែពីរនាក់ប៉ុណ្ណោះ គឺប្រធានតុលាការប្រជាជនកំពូល និងអគ្គរដ្ឋអាជ្ញាអមតុលាការនេះ។ បណ្តឹងសាទុក្ខធ្វើប្រឆាំងនឹងសាលក្រមរបស់តុលាការខេត្ត-ក្រុង ឬសាលក្រមរបស់សភាណាមួយនៃតុលាការប្រជាជនកំពូល។

ជាទ្រឹស្តី បណ្តឹងត្រូវដាក់ដោយភាគីមកនាយកដ្ឋានទទួលបណ្តឹង (មាត្រា ២៧ ក្រឹត្យ-ច្បាប់ លេខ ៣៤ ក្រ.ច) តវ៉ាពីសាលក្រមរបស់តុលាការខេត្ត-ក្រុង។ ជួនកាលទៀត ភាគីប្តឹងពីសាលក្រមរបស់សភាតុលាការកំពូលដែរ។ បណ្តឹងទាំងនេះត្រូវបញ្ជូនទៅប្រធានតុលាការកំពូល។ ប្រធានតុលាការកំពូលពិនិត្យមើលពាក្យបណ្តឹងព្រមទាំងសំណុំរឿងរបស់តុលាការ ឬរបស់សភានោះ។ បើយល់ថាសាលក្រមរបស់តុលាការ ឬរបស់សភាមានការភ័ន្តច្រឡំ ប្រធានតុលាការតាំងខ្លួនជាដើមបណ្តឹងសាទុក្ខដោយខ្លួនឯង។

ប្រធានជាអ្នកញ៉ាំងឱ្យបណ្តឹងសាទុក្ខមានចលនា ហេតុដូច្នេះ ការចាត់ការវិនិច្ឆ័យរឿងក្តីកើតឡើង ដោយសារការផ្តើម "បណ្តឹងសាទុក្ខរបស់ប្រធាន" មិនមែនដោយសារភាគីដូចដែលយើងបាន

យល់នៅក្នុងប្រព័ន្ធច្បាប់បារាំង និងប្រព័ន្ធច្បាប់ខ្មែរមុនៗនោះទេ។ បណ្តឹងសាទុក្ខរបស់ប្រធានអាចកើតចេញពីការដែលភាគីនាំបណ្តឹងមកតុលាការកំពូល និងដោយសារការផ្តើមរបស់ប្រធាន ក្រោយពីពេលគាត់ពិនិត្យឃើញសាលក្រមរបស់តុលាការថ្នាក់ក្រោមមិនត្រឹមត្រូវ[85]។ លើសពីនេះ ប្រធានតុលាការកំពូលមានអំណាចត្រួតមើលលើសាលក្រមរបស់សភានៃតុលា-ការកំពូលខ្លួនឯងទៀត។ បើសាលក្រមរបស់សភាមិនត្រឹមត្រូវ គាត់អាចធ្វើបណ្តឹងសាទុក្ខទល់នឹងសាលក្រមរបស់សភាទៀតផង (មាត្រា ៦.ខ និង ១៧.ឃ)។ រយៈពេលកំណត់សម្រាប់បណ្តឹងសាទុក្ខ របស់ប្រធានតុលាការគឺ ១ ឆ្នាំ គិតពីថ្ងៃដែលសាលក្រមមានអានុភាពអនុវត្ត។

បន្ទាប់មក ប្រធានតុលាការកំពូលដាក់បណ្តឹងជូនក្រុមប្រឹក្សាចៅក្រមដែលមានរូបគាត់ជាអធិបតីដើម្បីពិនិត្យ និងសម្រេចលើបណ្តឹងសាទុក្ខរបស់គាត់។ ប្រធានបើកអង្គប្រជុំក្រុមប្រឹក្សាចៅក្រម ដើម្បីពិនិត្យ និងសម្រេច ថាសំណុំរឿងនោះមានលក្ខណៈធ្ងន់ធ្ងរស្មុគស្មាញ ឬយ៉ាងណា (មាត្រា ១៧.ខ និង ៦.ក)។

បើរឿងនោះធ្ងន់ធ្ងរ សំណុំរឿងត្រូវដាក់ជូនសភាដែលពាក់ព័ន្ធដើម្បីសម្រេចជាលើកទីមួយ និងជាលើកចុងក្រោយ មានន័យថាសាលក្រមដែលសម្រេចដោយសភាមិនបង្វិលទៅតុលាការក្រោមវិញទេ។ ប្រធានតុលាការអាចសើរើនីតិវិធីបណ្តឹងសាទុក្ខរបស់ខ្លួនឡើងវិញ បើកាលណាគាត់មើលឃើញថា សភាសម្រេចដោយមានការភ័ន្តច្រឡំ (មាត្រា ៩.ខ) ដែលក្នុងករណីនេះសភាត្រូវជម្រះឡើងវិញ។

ចំពោះបណ្តឹងសាទុក្ខទល់នឹងតុលាការខេត្ត-ក្រុង ឬយោធា សភាអាចសម្រេចបញ្ចប់រឿងតែម្តង ឬក៏បង្វិលរឿងទៅតុលាការក្រោមដើម្បីជម្រះសាឡើងវិញក៏បាន (មាត្រា៩ កថាខណ្ឌចុងក្រោយ)។

ការជំនុំជម្រះធ្វើឡើងដោយក្រុមប្រឹក្សាជំនុំជម្រះដែលមានសមាសភាពចៅក្រម៣នាក់ និងទីប្រឹក្សាប្រជាជន[86] ២នាក់ (សម្រាប់ការជំនុំជម្រះជាលើកទីមួយ និងចុងក្រោយបង្អស់) និងសមាសភាពចៅក្រម ៤នាក់ និងទីប្រឹក្សាប្រជាជន ៣នាក់ (សម្រាប់ការជំនុំជម្រះលើបណ្តឹងសាទុក្ខរបស់ប្រធានតុលាការទល់នឹងសាលក្រម របស់សភាតុលាការកំពូលដែលសម្រេចជាលើកទីមួយ និងជាចុងក្រោយបង្អស់)។

នៅក្នុងការជំនុំជម្រះរបស់សភាលើ បណ្តឹងសាទុក្ខរបស់ប្រធានទល់នឹងសាលក្រមរបស់តុលាការខេត្ត-ក្រុង ក្រុមប្រឹក្សាជំនុំជម្រះមានសមាសភាពចៅក្រម៣នាក់ និងទីប្រឹក្សាប្រជាជន ២នាក់។ សេចក្តីសម្រេចត្រូវធ្វើ ដោយមតិភាគច្រើនរួមទាំងមតិរបស់ទីប្រឹក្សាប្រជាជន។

---

[85] មាត្រា ១៧ នៃក្រឹត្យ-ច្បាប់លេខ ៣៤ ចែងថា "...ឃ-ចាត់តាំងត្រួតពិនិត្យសាលក្រមនិងការងារសភាតុលាការប្រជាជនកំពូល តុលាការខេត្ត-ក្រុង និងតុលាការយោធា"។

[86] ទីប្រឹក្សាប្រជាជនជាប្រជាពលរដ្ឋសាមញ្ញដែលចូលរួមនៅក្នុងសវនាការនិងការសម្រេចរបស់តុលាការ។

ថ្វីត្បិតតែប្រធានតុលាការកំពូលជាដើមបណ្តឹងសាទុក្ខ គាត់ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះផងដែរ។

**ការបកស្រាយច្បាប់** ៖ តុលាការកំពូលគ្មានអំណាចបកស្រាយច្បាប់ទេ។ រាល់ការខ្វែងគំនិតលើបញ្ហាច្បាប់ ក្រុមប្រឹក្សាចៅក្រមស្នើទៅក្រុមប្រឹក្សារដ្ឋ ដើម្បីបកស្រាយចំណុចច្បាប់ (មាត្រា ៦.ច)។

## ឈ. មហាអយ្យការអមតុលាការកំពូលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

បេសកកម្មរបស់មហាអយ្យការអមតុលាការកំពូលគឺ ការការពារនីត្យានុកូលភាព ការការពាររបបប្រជាធិបតេយ្យរបស់ប្រជាជន ការការពារសណ្តាប់ធ្នាប់សង្គម និងទ្រព្យសម្បត្តិសាធារណៈធានាឱ្យមានការគោរពអាយុជីវិត ទ្រព្យសម្បត្តិ សិទ្ធិសេរីភាពរបស់ពលរដ្ឋ។

មហាអយ្យការមានអគ្គរដ្ឋអាជ្ញាមួយរូប អគ្គរដ្ឋអាជ្ញារង (ទទួលខុសត្រូវលើកិច្ចការយោធា) និងរដ្ឋអាជ្ញាមួយចំនួន។

ការទទួលខុសត្រូវរបស់មហាអយ្យការរួមមាន ការត្រួតពិនិត្យ និងគ្រប់គ្រងការងាររបស់អយ្យការទូទាំងប្រទេស និងតាំងខ្លួនជាដើមបណ្តឹងសាទុក្ខស្មើគ្នានឹងប្រធានតុលាការកំពូលដែរ។ មហាអយ្យការទទួលខុសត្រូវ ចំពោះមុខរដ្ឋសភានិងក្រុមប្រឹក្សារដ្ឋ។

ការងារសំខាន់មួយទៀតគឺ មហាអយ្យការមានអំណាចត្រួតពិនិត្យលើការស៊ើបអង្កេតដើម្បីធានាឱ្យការស៊ើបអង្កេតមានភាពសត្យានុម័តទាំងលើភស្តុតាងដាក់បន្ទុកនិងភស្តុតាងដោះបន្ទុក (មាត្រា ២៣ ក្រឹត្យ-ច្បាប់ ៣៤ ក្រ.ច)។ បើយោងទៅតាមមាត្រា ២៣ នៃក្រឹត្យ-ច្បាប់នេះការពាក់ព័ន្ធរបស់មហាអយ្យការ ក្នុងការស៊ើបអង្កេតអាចលាតសន្ធឹងរហូតទៅដល់រឿងនៅក្នុងដៃរបស់តុលាការខេត្ត-ក្រុង និងយោធា។ មាត្រានោះចែងថា មហាអយ្យការមានអំណាចត្រួតពិនិត្យនីត្យានុកូលភាពនៃការស៊ើបអង្កេតចាប់ពី ដំណាក់ការដំបូងរហូតដល់ដំណាក់កាលចុងក្រោយ ត្រួតពិនិត្យលិខិតផ្តើមចោទប្រកាន់របស់ស្ថាប័នស៊ើបអង្កេតដើម្បីតាមដាន និងសហការបដិសេធសេចក្តីសម្រេចរបស់អយ្យការតុលាការថ្នាក់ក្រោម និងស៊ើបអង្កេតដោយខ្លួនឯង។ មហាអយ្យការមានសិទ្ធិចោទប្រកាន់ ឬមិនចោទប្រកាន់ និងធ្វើលិខិតចោទប្រកាន់ និងបញ្ជូនជនជាប់ចោទទៅតុលាការ។ មហាអយ្យការមានសិទ្ធិចេញដីកានាំខ្លួន ចាប់ខ្លួន ឃុំខ្លួនបណ្តោះអាសន្ន ដោះលែងជាបណ្តោះអាសន្ន ឬជាស្ថាពរ។

រឿងមួយដែលប្លែកពីករណីនៃមហាអយ្យការនៅក្នុងប្រព័ន្ធតុលាការខ្មែរមុនៗ គឺថាតំណាងមហាអយ្យការនេះជាអ្នកផ្តើមចោទ និងដេញដោលនៅក្នុងសវនាការព្រហ្មទណ្ឌនៃ

តុលាការប្រជាជនកំពូល[87]។ មហាអយ្យការអមតុលាការប្រជាជនកំពូលជាស្ថាប័នអនុវត្តសាលក្រមផងដែរ។

## ៣. តុលាការកំពូលបច្ចុប្បន្ន

### ប្រវត្តិដើម

តុលាការប្រជាជនកំពូលបានប្រែក្លាយខ្លួនឯងទៅជាតុលាការកំពូលនៅឆ្នាំ១៩៩២ នៅក្រោមបទបញ្ញត្តិស្តីពី ប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលអនុម័តនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ (ដែលគេហៅជាទូទៅថា "ច្បាប់អ៊ុនតាក់")។ ច្បាប់អ៊ុនតាក់នេះគ្រាន់តែចែងនូវគោលការណ៍មូលដ្ឋានសម្រាប់ស្ថានភាពគតិយុត្តនៃតុលាការនេះ និងសិទ្ធិទាក់ទងនឹងការតវ៉ាទៅតុលាការកំពូល តែមិនបានផ្តល់នូវគ្រោងការ និងដំណើរការប្រព្រឹត្តទៅនៃតុលាការនេះទេ។

គោលការណ៍ជាមូលដ្ឋានសម្រាប់តុលាការនេះគឺថា តុលាការកំពូលជាតុលាការជំនុំជម្រះអង្គច្បាប់នៅក្នុងពេលជំនុំជម្រះបណ្តឹងសាទុក្ខជាលើកទីមួយ និងជាតុលាការដែលជំនុំជម្រះដល់អង្គសេចក្តី នៅពេលជំនុំជម្រះបណ្តឹងសាទុក្ខជាលើកទីពីរលើរឿងដដែល និងមធ្យោបាយ (មូលដ្ឋានតវ៉ា)ដដែល (មាត្រា៥ នៃច្បាប់អ៊ុនតាក់)។ គោលការណ៍មួយទៀតទទួលស្គាល់អន្តរាគមន៍របស់អគ្គរដ្ឋអាជ្ញានៅឯតុលាការកំពូលក្នុងការនាំរឿងឱ្យតុលាការ នេះជំនុំជម្រះក្នុងផលប្រយោជន៍នៃច្បាប់ (មាត្រា ២ នៃច្បាប់អ៊ុនតាក់)។

ច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌដែលអនុម័តដោយភាគីរដ្ឋកម្ពុជានៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៣ បានចែងលំអិតពីដំណើរការរបស់តុលាការកំពូល។ គោលការណ៍មួយដែលចែងពីបណ្តឹងសាទុក្ខក្នុងផលប្រយោជន៍នៃច្បាប់ដែលត្រូវអនុវត្តដោយ មហាអយ្យការអមតុលាការកំពូលត្រូវបានរំលងចោលនៅក្នុងច្បាប់នេះ។ ប៉ុន្តែ ច្បាប់នេះបានចែងពីបណ្តឹងសាទុក្ខរបស់អគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងផលប្រយោជន៍នៃច្បាប់។ មាត្រា ១៦០ នៃច្បាប់នេះចែងថា ៖

[87] មាត្រា ២៤ នៃក្រឹត្យ-ច្បាប់ ៣៤ ក្រ.ច ចែងថា ៖ "មហាអយ្យការអមតុលាការប្រជាជនកំពូល ប្រើសិទ្ធិអយ្យការក្នុងពេលជំនុំជម្រះ។ ចូលរួមក្នុងសម័យប្រជុំត្រៀមបំរុងរបស់តុលាការប្រជាជនកំពូល។ ចូលរួមក្នុងនីតិវិធីជំនុំជម្រះ។ ក្នុងពេលសវនាការរឿងព្រហ្មទណ្ឌ អានលិខិតចោទប្រកាន់ និងធ្វើសេចក្តីសន្និដ្ឋានក្រោយពីការសួរដេញដោល។ តាំងខ្លួនជាគូក្តីដើមក្នុងរឿងដែលប៉ះពាល់ដល់របៀបរៀបរយសាធារណៈ ដល់ផលប្រយោជន៍របស់រដ្ឋ ឬផលប្រយោជន៍អនីតិជន និងអសមត្ថជន។ ធ្វើសំណូមពរដល់អង្គការរដ្ឋ អង្គការសង្គម ឲ្យចាត់តាំងតំណាងស្របច្បាប់របស់ខ្លួនមកចូលរួមជំនុំជម្រះរឿងរដ្ឋប្បវេណីដែលប៉ះពាល់ដល់ផលប្រយោជន៍របស់រដ្ឋឬ សមូហភាព។"

> មុខងារសំខាន់របស់អគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍គឺធ្វើសេចក្តីសន្និដ្ឋាន នៅពេលសវនាការ និងប្តឹងសាទុក្ខទៅតុលាការកំពូលចំពោះសាលដីកាសាលាឧទ្ធរណ៍ ដែលខ្លួនឃើញថាមានការភ័ន្តច្រឡំ ឬខុសច្បាប់

មាត្រា ១៣ នៃច្បាប់ស្តីពី ការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ដែលបានអនុម័ត នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ក៏ចាត់ទុកអគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ជាដើមបណ្តឹងព្រហ្មទណ្ឌ នៅក្នុងបណ្តឹងសាទុក្ខដែរ។ មាត្រា ១៣ កថាខណ្ឌទីពីរនេះចែងថា ៖

> អ្នកដែលមានសិទ្ធិប្តឹងសាទុក្ខ និងប្តឹងជំទាស់គឺអគ្គរដ្ឋអាជ្ញាសាលាឧទ្ធរណ៍ ឬជនដែលមានផលប្រយោជន៍ក្នុងរឿងទាំងឡាយរួមមាន ៖ គូក្តី ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងបទរដ្ឋប្បវេណី ជនជាប់ទោស មេធាវី អ្នកការពារ។

នៅក្នុងជំពូកដែលចែងពីតុលាការកំពូល អ្នកប្តឹងសាទុក្ខអាចធ្វើបានចំពោះតែអ្នកមានផលប្រយោជន៍នៅក្នុងរឿងក្តី។ មាត្រា២១១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌចែងបន្តទៀតថា ៖

> បណ្តឹងសាទុក្ខត្រូវធ្វើដោយផ្ទាល់ ដោយអ្នកមានផលប្រយោជន៍នៃរឿងក្តី ឬដោយតតិយជនដែលបានទទួលអំណាចជាលាយលក្ខណ៍អក្សរពិសេស ឬដោយបុគ្គលដែល ច្បាប់ទទួលស្គាល់ ជាតំណាងត្រឹមត្រូវតាមច្បាប់ ដូចជាឪពុកតំណាងឱ្យកូនជា អនីតិជនជាដើម។

មានបទបញ្ញត្តិមួយទៀតដែរដែលចែងពីបណ្តឹងសាទុក្ខរបស់អគ្គរដ្ឋអាជ្ញា តែគេមិនដឹងច្បាស់ថាជា បណ្តឹងរបស់អគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ ឬជាអគ្គរដ្ឋអាជ្ញាអមតុលាការកំពូល។ មាត្រា២១៤ កថាខណ្ឌ៣ ចែងថា ៖

> កាលណាបណ្តឹងសាទុក្ខជារបស់អគ្គរដ្ឋអាជ្ញា សេចក្តីសន្និដ្ឋានលើកឡើងរាល់ចំណុចច្បាប់ ត្រូវតែធ្វើជូនតុលាការជាចាំបាច់។

ដូច្នេះ តួនាទីរបស់មហាអយ្យការអមតុលាការកំពូលនៅតែមិនច្បាស់ ព្រោះគ្មានបទបញ្ញត្តិច្បាប់ណាមួយបានចែងជាក់លាក់ទេ។ សំណួរដែលចោទសួរគឺថា តើនៅក្នុងរឿងព្រហ្មទណ្ឌអគ្គរដ្ឋ(រាជ)អាជ្ញាអមតុលាការកំពូលជាគូក្តីដើម ឬជាតួអង្គការពារផលប្រយោជន៍ច្បាប់ព្រោះច្បាប់ស្តីពីការការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តីនៃ រដ្ឋកម្ពុជាចែងថា "ក្រុមអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា និងធ្វើសេចក្តីសន្និដ្ឋានទោសដោយតាំងខ្លួនជាគូក្តីជាដរាប"(មាត្រា ៥ កថាខណ្ឌទី២)។

## រចនាសម្ព័ន្ធនៃតុលាការកំពូលនិងមហាអយ្យការ

នៅឆ្នាំ២០១៤ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការរៀបចំអង្គតុលាការ ដែលកំណត់

រចនាសម្ព័ន្ធ និងសមត្ថកិច្ចរបស់តុលាការគ្រប់ជាន់ថ្នាក់។ យោងតាមច្បាប់នេះ តុលាការកំពូលចែកចេញជាបួនសភាជំនាញគឺ សភាព្រហ្មទណ្ឌ សភារដ្ឋប្បវេណី សភាពាណិជ្ជកម្ម និងសភាការងារ (មាត្រា៥៧)។ សភានីមួយៗត្រូវសម្រេចដោយចៅក្រមប្រាំរូប (មាត្រា ៥៩)។

ក្រៅពីសភាជំនាញដែលមានភារកិច្ចសម្រេចរឿងក្នុងជំនាញរបស់ខ្លួន តុលាការកំពូលនៅមានសភាពេញអង្គដែលបង្កើតឡើងដោយដីកាសម្រេចរបស់ប្រធានតុលាការទៅតាមកាលនៅពេលណាមានបណ្តឹងសាទុក្ខជាលើកទីពីរ និងបណ្តឹងសើរើ (មាត្រា ៦២)។ សភាពេញអង្គនេះត្រូវមានចៅក្រមយ៉ាងតិចប្រាំបួននាក់ ដែលមានសមាសភាពចេញពីគ្រប់សភាទាំងបួន។ កាលណារឿងក្តីមួយពាក់ព័ន្ធនឹងសមត្ថកិច្ចនៃសភាច្រើនជាងមួយ តុលាការកំពូលអាចបង្កើត "សភារួមក្រុម" ដើម្បីដោះស្រាយរឿងក្តីនោះ (មាត្រា ៦៣)។ សភារួមក្រុមនេះមានសមាសភាពចៅក្រមប្រាំបួនរូប ដែលជ្រើសចេញពីសភាពាក់ព័ន្ធ ដែលមានចំនួនស្មើគ្នា។

មហាអយ្យការអមតុលាការកំពូលត្រូវបានគ្រប់គ្រងដោយ អគ្គព្រះរាជអាជ្ញាម្នាក់ (មាត្រា ៧០)។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលធ្វើការតាមឋានានុក្រម មានន័យថា រាល់សេចក្តីសន្និដ្ឋានទាំងអស់របស់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាត្រូវតែទទួលការពិនិត្យដោយអគ្គព្រះរាជអាជ្ញា នៅមុនដាក់ជូនសវនាការ (មាត្រា ៧០)។

## នីតិវិធីនៃបណ្តឹងសាទុក្ខ
## ការវិវត្តនៃតុលាការកំពូលចាប់ពីឆ្នាំ ២០០៧

ច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា និងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ ស្ថិតនៅជាគ្រឹះនៃឋានៈគតិយុត្តនៃតុលាការកំពូលរហូតដល់មានការអនុម័តក្រមនីតិវិធីព្រហ្មទណ្ឌនៅ ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧ និងក្រមនីតិវិធីរដ្ឋប្បវេណីនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៦។

ក្រមនីតិវិធីព្រហ្មទណ្ឌនិងរដ្ឋប្បវេណីបានកែប្រែនីតិវិធី នៃបណ្តឹងសាទុក្ខនៅចំពោះមុខតុលាការកំពូល ដែលចែងនៅក្នុងច្បាប់មុនៗ។

## នីតិវិធីនៃបណ្តឹងសាទុក្ខនៅក្នុងរឿងព្រហ្មទណ្ឌ

នៅក្នុងរឿងព្រហ្មទណ្ឌ ភាគីអាចប្តឹងសាទុក្ខបានលុះត្រាតែមានមូលដ្ឋានដែលមានចែងនៅក្នុងច្បាប់៖ (១) តុលាការដែលធ្វើការជំនុំជម្រះដោយសមាសភាពមិនស្របច្បាប់, (២) តុលាការគ្មានសមត្ថកិច្ចត្រូវដោះស្រាយរឿងក្តីណាមួយ, (៣) ចៅក្រមប្រើអំណាចសម្រេចសេចក្តីហួសពីច្បាប់ផ្តល់ឲ្យ, (៤) ការអនុវត្តច្បាប់មិនត្រូវទៅលើអង្គហេតុដែលបានរកឃើញ, (៥) ការបំពានលើ ឬការភ្លេចមិនបានបំពេញទម្រង់ណាមួយដែលច្បាប់កំណត់ថាការបំពាន ឬការមិនបានបំពេញទម្រង់នោះ

នាំឲ្យមានមោឃភាពនៃនីតិវិធី, (៦) ការបំភ្លៃអង្គហេតុ (៧) ការសម្រេចដោយគ្មានសំអាងហេតុ, និង (៨) សេចក្តីសម្រេចមិនស៊ីសង្វាក់គ្នាជាមួយសំអាងហេតុ[88]។

កម្មវត្ថុដែលអាចប្តឹងសាទុក្ខបានគឺសាលដីកានៃសភាស៊ើបសួរនៃសាលាឧទ្ធរណ៍, សាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ និងរឿងបត្យាប័ន[89]។ បុគ្គលដែលអាចប្តឹងសាទុក្ខបានមាន (១) អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល, (២) អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍, (៣) ជនជាប់ចោទ, (៤) បុគ្គលដែលត្រូវគេទាមទារក្នុងករណីនៃនីតិវិធីបត្យាប័ន, (៥) ដើមបណ្តឹងរដ្ឋប្បវេណី, និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

បណ្តឹងសាទុក្ខត្រូវធ្វើ និងចុះបញ្ជីនៅការិយាល័យក្រឡាបញ្ជីសាលាឧទ្ធរណ៍ រួចមកបណ្តឹងនេះត្រូវបញ្ជូនមកការិយាល័យក្រឡាបញ្ជីនៃតុលាការកំពូល និងចុះបញ្ជីការិយាល័យនេះ[90]។ ក្រោយពីបានទទួលបណ្តឹងសាទុក្ខនេះហើយ ក្រឡាបញ្ជីជូនដំណឹងឲ្យភាគីប្តឹងសាទុក្ខ ឬ/និងមេធាវីរបស់គាត់ដាក់សារណាគាំទ្របណ្តឹងរបស់ខ្លួនមកតុលាការក្នុងរយៈពេល ២០ ថ្ងៃ[91]។ បណ្តឹងសាទុក្ខនេះត្រូវបញ្ជូនដោយក្រឡាបញ្ជីទៅភាគីដែលត្រូវឆ្លើយតបផងដែរ ហើយភាគីនោះមានពេលចំនួន ២០ថ្ងៃ ដើម្បីធ្វើសារណាតបវិញ[92]។ ភាគីដែលត្រូវឆ្លើយតបនេះអាចសុំទៅសភាព្រហ្មទណ្ឌដើម្បីពន្យាពេលបានរហូតដល់១០ថ្ងៃ ប្រសិនរយៈពេល២០ថ្ងៃ ដែលកំណត់នោះមិនគ្រប់គ្រាន់ដើម្បីបញ្ចប់ការរៀបចំសារណាតបរបស់ខ្លួន[93]។

ក្រោយពីពេលទទួលសារណាសព្វគ្រប់ហើយ ឬផុតពេលទទួលសារណាហើយ ប្រធានសភាចាត់តាំងចៅក្រមរបាយការណ៍ម្នាក់ឲ្យរៀបចំការសិក្សាសារណា និងធ្វើរបាយការណ៍អំពីបណ្តឹងសាទុក្ខនោះដើម្បីដាក់ជូនប្រធាន។ របាយការណ៍របស់ចៅក្រមត្រូវសរសេររៀបរាប់អំពីប្រវត្តិនៃនីតិវិធីនៃរឿងក្តី និងអង្គហេតុ ចំណុចច្បាប់ដែលភាគីចោទជាបញ្ហា, និងអនុសាសន៍របស់ចៅក្រមរបាយការណ៍អំពីដំណោះស្រាយដែលមានចំពោះបណ្តឹងសាទុក្ខនោះ[94]។

សំណុំរឿងសាទុក្ខទាំងអស់រួមមានសារណារបស់ភាគី និងរបាយការណ៍របស់ចៅក្រមរបាយការណ៍ត្រូវបញ្ជូនទៅមហាអយ្យការអមតុលាការកំពូល ដើម្បីឲ្យស្ថាប័ននេះធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដែលនឹងត្រូវបញ្ជូនត្រឡប់មកប្រធានសភាព្រហ្មទណ្ឌវិញ[95]។

---

[88] មាត្រា ៤១៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[89] មាត្រា ៤១៧ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧។

[90] ប្រភពដូចគ្នា មាត្រា ៤២២, ៤២៤ និង ៤២៥។

[91] ប្រភពដូចគ្នា មាត្រា ៤២៧។

[92] ប្រភពដូចគ្នា។

[93] ប្រភពដូចគ្នាមាត្រា ៤២៩។

[94] ប្រភពដូចគ្នាមាត្រា ៤៣១។

[95] ប្រភពដូចគ្នាមាត្រា ៤៣៣។

សវនាការជាសាធារណៈត្រូវបានបើកឡើងបន្ទាប់ពីជូនដំណឹងទៅភាគី។ សភាព្រហ្មទណ្ឌជាគោលការណ៍មិនចាំបាច់ស្តាប់ចម្លើយរបស់ភាគីទៀតទេ ព្រោះសវនាការនេះ ជាសវនាការដេញដោលតែលើសាច់ច្បាប់ ប៉ុន្តែប្រធានសភាអាចកោះអញ្ជើញឲ្យភាគីមកឆ្លើយបានដែរ[96]។ នៅក្នុងការអនុវត្តជាក់ស្តែង គេសង្កេតឃើញថា តុលាការកំពូលកោះហៅភាគីមកឆ្លើយនៅមុខតុលាការទាក់ទងនឹងអង្គហេតុផងដែរ ទោះបីមានវត្តមានមេធាវីក្តី ឬអវត្តមានមេធាវីក្តី[97]។ សវនាការត្រូវធ្វើតាមលំដាប់លំដោយ៖ ចៅក្រមរបាយការណ៍ជាអ្នកធ្វើរបាយការណ៍ឲ្យអង្គសវនាការ បន្ទាប់មកអគ្គព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន (ហៅថាសេចក្តីសន្និដ្ឋានសុំ) និងជាចុងក្រោយមេធាវីនៃភាគីទាំងសងខាងធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនរៀងខ្លួន (ហៅថាសេចក្តីសន្និដ្ឋានការពារ)។

សេចក្តីសម្រេចរបស់តុលាការកំពូល អាចជាសាលដីកាបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ដោយមិនបាច់បង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះឡើងវិញ ឬអាចជាសាលដីកាដែលបដិសេធដោយបង្វិលសំណុំរឿងទៅឲ្យសាលាឧទ្ធរណ៍ជំនុំជម្រះ ដោយសមាសភាពក្រុមប្រឹក្សាផ្សេង[98]។ ការបដិសេធប្រភេទទីមួយអាចធ្វើបាននៅពេលណាតុលាការកំពូលរកឃើញថាបទល្មើសដែលចោទប្រកាន់នោះគ្មានភស្តុតាង និងធាតុផ្សំដើម្បីកំណត់អត្ថិភាពនៃបទល្មើសនោះ ឬពេលណាតុលាការកំពូលរកឃើញថា ការកំណត់បទល្មើសរបស់សាលាឧទ្ធរណ៍មិនត្រូវ ប៉ុន្តែទោះជាយ៉ាងណាក្តី ទោសពិន័យនៅតែស្មើនឹងបទល្មើសដែលតុលាការកំពូលរកឃើញ។ ការបដិសេធប្រភេទទីពីរអាចធ្វើបាន នៅពេលណាតុលាការកំពូលរកឃើញថាការកំណត់បទល្មើសរបស់តុលាការថ្នាក់ក្រោមខុសពីប្រភេទបទល្មើសដែលតុលាការកំពូលរកឃើញ។

នៅពេលបង្វិលសំណុំរឿងទៅវិញ កាលណាសាលឧទ្ធរណ៍សម្រេចមិនស្របតាមគោលគំនិតរបស់តុលាការកំពូលទេនោះ ហើយរឿងនោះត្រូវប្តឹងសាទុក្ខមកតុលាការកំពូលជាលើកទីពីរនោះតុលាការកំពូលនឹងសម្រេចរឿងនេះ ក្នុងទម្រង់នៃសវនាការពេញអង្គ (ដែលលើនេះតុលាការកំពូលសម្រេចទាំងលើអង្គច្បាប់ ទាំងលើអង្គហេតុ។

## នីតិវិធីនៃបណ្តឹងសាទុក្ខនៅក្នុងរឿងរដ្ឋប្បវេណី

រឿងក្តីរដ្ឋប្បវេណីអាចត្រូវបានប្តឹងសាទុក្ខបាន ដោយមានមូលហេតុ។ មូលហេតុដែល

---

[96] ប្រភពដូចគ្នាមាត្រា ៤៣៤ និង ៤៣៦។

[97] ព័ត៌មាននេះបានមកពីការអានកម្រងសាលដីកា ១៩៩៦-២០០៦ ដែលបោះផ្សាយដោយតុលាការកំពូល និងមហាអយ្យការ។ គេអាចរកកម្រងសាលដីកាតុលាការកំពូលនៅក្នុងទំព័រ http://www.supremecourt.gov.kh/index.php/km/judgements/criminal-judgements (ចំពោះសាលដីកាព្រហ្មទណ្ឌ) និង http://www.supremecourt.gov.kh/index.php/km/judgements/civil-judgements (ចំពោះសាលដីការដ្ឋប្បវេណី)

[98] មាត្រា ៤៤០ និង ៤៤១ ក្រមនីតិវិធីព្រហ្មទណ្ឌ។

កំណត់ដោយក្រមនីតិវិធីរដ្ឋប្បវេណីគឺជាមូលហេតុផ្នែកច្បាប់ ដូចជា សេចក្តីសម្រេចរបស់តុលាការមិនស្របនឹងរដ្ឋធម្មនុញ្ញ ច្បាប់ និងបទដ្ឋានគតិយុត្តនានា។ មូលហេតុដទៃទៀតគឺជាមូលហេតុទាក់ទងនឹងភាពត្រឹមត្រូវ/សមរម្យនៃកិច្ចដំណើរការនីតិវិធីរដ្ឋប្បវេណី មានដូចជា តុលាការគ្មានសមត្ថកិច្ចតាមផ្លូវច្បាប់លើរឿងក្តីណាមួយ, ចៅក្រមដែលគ្មានសម្បទានៅក្នុងការសម្រេចរឿងក្តី, តុលាការដែលគ្មានសមត្ថកិច្ចផ្តាច់មុខលើរឿងដែលត្រូវជំនុំជម្រះដោយតុលាការដែលគ្មានសមត្ថកិច្ចផ្តាច់មុខ, បុគ្គលដែលគ្មានសិទ្ធិតំណាងនៅក្នុងការដំណើរការរឿងក្តី, សវនាការមិនបានប្រព្រឹត្តទៅស្របតាមគោលការណ៍ចំពោះមុខ និងសាធារណៈ សាលក្រម/សាលដីកាគ្មានសំអាងហេតុ ឬមានសំអាងហេតុមិនស៊ីសង្វាក់គ្នានឹងសេចក្តីសម្រេច[99]។ ការប្តឹងសាទុក្ខត្រូវតែចែងមូលហេតុដូចបានពោលខាងមុខនេះ បើពុំនោះទេ បណ្តឹងនោះត្រូវតុលាការកំពូលលើកចោល[100]។ ប៉ុន្តែប្រសិនបើបណ្តឹងចែងមូលហេតុមិនជាក់ច្បាស់តែការមិនជាក់ច្បាស់នោះអាចកែតម្រូវវិញបាន នោះតុលាការមិនលើកចោលតែម្តងទេ តែសុំឲ្យម្ចាស់បណ្តឹងសាទុក្ខកែតម្រូវបណ្តឹងរបស់ខ្លួន[101] ហើយបើម្ចាស់បណ្តឹងមិនកែប្រែតាមពេលដែលកំណត់ដោយតុលាការទេ នោះទើបតុលាការលើកបណ្តឹងសាទុក្ខនោះចោល។ តុលាការកំពូលអាចធ្វើការវិនិច្ឆ័យតែលើ ចំណុចដែលស្នើសុំនៅក្នុងបណ្តឹងសាទុក្ខតែប៉ុណ្ណោះ ហើយមិនអាចពង្រីកការវិនិច្ឆ័យសេចក្តីលើចំណុចដែលម្ចាស់បណ្តឹងមិនបានស្នើសុំទេ ទោះជាតុលាការបានឃើញចំណុចដែលត្រូវដោះស្រាយលើសពីអ្វីដែលម្ចាស់បណ្តឹងបានស្នើសុំក៏ដោយ[102]។ ប៉ុន្តែ ចំពោះចំណុចដែលមានផលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ដូចជាភាពស្របច្បាប់នៃសមាសភាពតុលាការជាដើម តុលាការកំពូលអាចប្រើឆន្ទានុសិទ្ធិដើម្បីពង្រីកការពិនិត្យលើបញ្ហាបែបនេះ[103]។ ការប្តឹងសាទុក្ខអាចធ្វើបានមិនចំពោះតែសាលដីកាសាលាឧទ្ធរណ៍ប៉ុណ្ណោះទេ តែអាចបានចំពោះសាលក្រមតុលាការដំបូងផងដែរ។ ឧទាហរណ៍ តុលាការដំបូងបានចេញសាលក្រមរួច ប៉ុន្តែភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ តែរក្សាសិទ្ធិប្តឹងសាទុក្ខទៅតុលាការកំពូលតែម្តង(ប្តឹងផ្លោះ)[104]

អង្គហេតុដែលកំណត់ត្រឹមត្រូវដោយតុលាការថ្នាក់ក្រោមរួចហើយ អង្គហេតុនោះនឹងក្លាយទៅជាអង្គហេតុផ្តាច់ព្រ័ត្រសម្រាប់តុលាការកំពូល និយាយម្យ៉ាងទៀត តុលាការកំពូលមិនត្រូវជម្រះ

[99] មាត្រា ២៨៤ និង ២៨៥ ក្រមនីតិវិធីរដ្ឋប្បវេណី។

[100] មាត្រា ២៨៩, ២៩០, ២៩៤ ក្រមនីតិវិធីរដ្ឋប្បវេណី។

[101] មាត្រា ២៩០ និង ២៩១ ក្រមរដ្ឋប្បវេណី។

[102] មាត្រា ២៩៥ ក្រមនីតិវិធីរដ្ឋប្បវេណី។

[103] សូមមើលអត្ថាធិប្បាយនៃមាត្រា ២៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[104] មាត្រា ២៨៣ ក្រមនីតិវិធីរដ្ឋប្បវេណី។

រកអង្គហេតុសាជាថ្មីទេ[105]។ កិច្ចការដែលនៅសល់សម្រាប់តុលាការកំពូលគឺភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការអនុវត្តច្បាប់របស់តុលាការថ្នាក់ក្រោមទៅលើអង្គហេតុផ្តាច់ព្រ័ត្រនោះ។

ដូចគ្នានឹងរឿងព្រហ្មទណ្ឌដែរ តុលាការកំពូលអាចចេញសាលដីកាបដិសេធ និងបង្វិលរឿងទៅតុលាការដើម ឬតុលាការផ្សេងដែលមានឋានៈស្មើគ្នា ឬអាចចេញសាលដីកាបដិសេធ និងវិនិច្ឆ័យរឿងដោយខ្លួនឯងតែម្តង[106]។

ចំពោះការបដិសេធសាលក្រម/សាលដីកានៃតុលាការដើម និងវិនិច្ឆ័យដោយខ្លួនឯង តុលា-ការកំពូលអាចធ្វើដូច្នេះបាន កាលណាអង្គហេតុនៃរឿងក្តីត្រូវបានកំណត់ច្បាស់លាស់មិនមានអ្វីដែលតុលាការកំពូលត្រូវពិនិត្យពិចារណាបន្ថែម (facts that are no longer disputed) នោះតុលាការកំពូលកំណត់យកបទបញ្ញត្តិច្បាប់ណាមួយមកអនុវត្ត និងវិនិច្ឆ័យសេចក្តីឲ្យចប់តែម្តងដោយមិនបាច់បង្វិលរឿងទៅតុលាការថ្នាក់ក្រោម ឬកាលណាតុលាការកំពូលគ្មានសមត្ថកិច្ចជម្រះរឿងក្តីដែលសាទុក្ខមក[107]។ ចំពោះករណីផ្សេងក្រៅពីនេះ តុលាការកំពូលត្រូវចេញសាលដីកាសម្រេចបដិសេធ និងបង្វិលរឿងមកតុលាការថ្នាក់ក្រោមវិញ។ តុលាការដែលត្រូវទទួលរឿងបង្វិលមកវិញនេះ ត្រូវគោរពតាមសំអាងហេតុដែលតុលាការកំពូលបានចង្អុលបង្ហាញទាក់ទងនឹងអង្គហេតុ និងអង្គច្បាប់ និងត្រូវបើកសវនាការចំពោះមុខ (ទាញហេតុផលផ្ទាល់មាត់) ឡើងវិញ ដើម្បីពិនិត្យមើលការខុសឆ្គង ឬការខ្វះចន្លោះក្នុងការកំណត់អង្គហេតុ និងអង្គច្បាប់នៅពេលចេញសាលក្រម/សាលដីកាដែលបានរងបណ្តឹងសាទុក្ខ។

## ទំហំនៃរឿងក្តីដែលចូលតុលាការកំពូល

តុលាការកំពូលស្ថិតនៅលើកំពូលពីរ៉ាមីត នៃឋានានុក្រមតុលាការនៃប្រទេសមួយ ដូច្នេះ រឿងក្តីទាំងអស់ដែលសម្រេចដោយតុលាការទាំងអស់ (មានតុលាការខេត្ត-ក្រុង និងឧទ្ធរណ៍) មិនអាចត្រូវបានប្តឹងសាទុក្ខទាំងអស់មកតុលាការកំពូលបានទេ។ បើគ្រប់រឿងក្តីទាំងអស់ត្រូវបានសាទុក្ខមកតុលាការកំពូលទាំងអស់ នោះប្រព័ន្ធតុលាការនឹងត្រូវជាប់គាំងដោយគំនររឿងក្តីដែលមិនអាចរកផ្លូវដោះស្រាយបាន។

ដោយសារតុលាការកំពូលស្ថិតនៅលើកំពូលពីរ៉ាមីត ចំនួនរឿងក្តីដែលចូលតុលាការនេះ ត្រូវតែសម្រាំងដោយប្រព័ន្ធច្រោះរឿងក្តីមួយ។ ទាំងក្រមនីតិវិធីរដ្ឋប្បវេណី ទាំងក្រមនីតិវិធីព្រហ្មទណ្ឌ សុទ្ធតែបានបង្កើតប្រព័ន្ធច្រោះបណ្តឹងសាទុក្ខ។ ប្រព័ន្ធនោះគឺមូលហេតុនៃបណ្តឹងសាទុក្ខ និងការលើកចោលបណ្តឹងសាទុក្ខ ដោយមិនបាច់ឆ្លងសវនាការចំពោះមុខ/ទាញហេតុ

[105] មាត្រា ២៩៦ ក្រមនីតិវិធីរដ្ឋប្បវេណី។

[106] មាត្រា ២៩៩ ក្រមនីតិវិធីរដ្ឋប្បវេណី។

[107] មាត្រា ៣០០ ក្រមនីតិវិធីរដ្ឋប្បវេណី។

ផលផ្ទាល់មាត់។ តុលាការកំពូលមានធនធានមានកំណត់ដើម្បីដោះស្រាយបណ្ដឹង។ ដូច្នេះ មានតែបណ្ដឹងដែលមានមូលហេតុត្រឹមត្រូវទេ ទើបត្រូវបានដោះស្រាយដោយតុលាការនេះ។

អ្នកនិពន្ធមិនបានទទួលបច្ចុប្បន្នភាពនៃស្ថិតិនៃរឿងក្ដីដែលចូល និងត្រូវបានដោះស្រាយដោយតុលាការកំពូលទេ ប៉ុន្តែទទួលបានតួលេខស្ថិតិមួយចំណែកតូចគ្រាន់ពិចារណាពីទំហំរឿងក្ដីដែលតុលាការកំពូលបានទទួល និងដោះស្រាយនៅឆ្នាំ ២០១០។

| | រឿងសល់ពីឆ្នាំមុនៗ | រឿងទទួលថ្មី | សរុបឆ្នាំ២០១០ | សរុបដោះស្រាយរួច ឆ្នាំ២០១០ | រឿងសល់សម្រាប់ឆ្នាំ ២០១១ | %នៃរឿងដែលបាន ដោះស្រាយហើយ |
|---|---|---|---|---|---|---|
| សិទ្ធិកម្មសិទ្ធិ | 772 | 243 | 1015 | 305 | 710 | 30% |
| កិច្ចសន្យា និង ក្រៅកិច្ចសន្យា | 528 | 121 | 649 | 149 | 500 | 23% |
| រឿងគ្រួសារ | 126 | 56 | 182 | 55 | 127 | 30% |
| វិធានការរក្សាការពារ | 93 | 10 | 103 | 16 | 87 | 16% |
| សវនាការឡើងវិញ | 65 | 70 | 135 | 27 | 108 | 20% |
| *សរុប* | *1584* | *500* | *2084* | *552* | *1532* | *26%* |

| | | |
|---|---|---|
| តម្កល់សាលដីកា | 221 | 40% |
| បដិសេធ | 189 | 34% |
| ដកចេញពីបញ្ជីបណ្ដឹង | 65 | 12% |
| ដកចេញពីបញ្ជីបណ្ដឹងសាទុក្ខ | 43 | 8% |
| ដីកាសម្រេចរក្សាការពារ | 34 | 6% |
| *សរុប* | *552* | |

*ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ ២០១០ នៃសភាពាណិជ្ជកម្មវរណី*

បើយើងសង្កេតលើតារាងនេះ ក្នុងឆ្នាំ២០១០ តុលាការកំពូលដោះស្រាយរឿងបានមិនដល់ពាក់កណ្ដាលទេ។ រឿងក្ដីចេះតែគរច្រើនឡើងក្នុងមួយឆ្នាំៗ។ ឧទាហរណ៍ ក្នុងរឿងសិទ្ធិកម្មសិទ្ធិហាក់ដូចជានៅសល់ចំនួនដដែល មិនបានរំលោះទេ (សល់ពីឆ្នាំមុន ៧៧២រឿង តែនៅសល់ ៧១០ រឿង ក្នុងឆ្នាំបន្ទាប់)។